ឆ្នាំ២០២៤

# សៀវភៅណែនាំស្តីពី សុវត្ថិភាពកាន់កាប់ដីធ្លី និងធនធានធម្មជាតិ នៅតំបន់ឆ្នេរ

## (សម្រាប់អ្នកចូលរួម)



សហការគាំទ្រមូលនិធិដោយ៖ ផលិតនិងបោះពុម្ពដោយ រួមសហការអនុវត្តគម្រោងដោយ

Co-funded by the European Union

Cambodian Center for Human Rights

Transparency International Cambodia

The NGO Forum on Cambodia

Open Development Cambodia Organization

CWDCC

actionaid

# អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិកម្ពុជា (“ម.ស.ម.ក”) ជាអង្គការមិនមែនរដ្ឋាភិបាល មិនចូលបក្សសម្ព័ន្ធ ឯករាជ្យដែលធ្វើការដើម្បីលើកកំពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ចក្ខុវិស័យរបស់ ម.ស.ម.ក ចង់ឲ្យកម្ពុជាក្លាយជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលក្នុងនោះប្រជាពលរដ្ឋទទួលបាន សិទ្ធិជាមូលដ្ឋាន មានសមភាព ត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួល បានផលប្រយោជន៍ពីការអភិវឌ្ឍប្រទេស។ ម.ស.ម.ក. ចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាពចង់បានស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងចង់បានសង្គមពហុនិយមដោយក្នុងនោះភាពចម្រុះ បែបនៃសង្គមត្រូវបានទទួលយក និងសាទរជាជាងព្រងើយកន្តើយ ឬដាក់ទណ្ឌកម្ម។ ស្លាកសញ្ញារបស់ ម.ស.ម.ក រំលេចឲ្យឃើញរូបសត្វព្រាបសហើរចេញពីរង្វង់មូលនៃផ្ទៃមេឃពណ៌ខៀវ ដែលនេះគឺជានិមិត្តរូប នៃការទាមទារសេរីភាពរបស់កម្ពុជា។

សៀវភៅណែនាំស្តីពី "**សុវត្ថិភាពកាន់កាប់ដីធ្លី និងធនធានធម្មជាតិនៅតំបន់ឆ្នេរ**" ត្រូវបានធ្វើបច្ចុប្បន្នភាពពីមេរៀនស្តីពី "**សិទ្ធិដីធ្លីក្នុងច្បាប់ភូមិបាលឆ្នាំ២០០១**" ដែលបានចងក្រងឡើងដោយ ម.ស.ម.ក ក្នុងឆ្នាំ២០១៤។ សៀវភៅណែនាំនេះបានធ្វើបច្ចុប្បន្នភាពលើកទី១ កាលពីឆ្នាំ២០២០ ត្រូវបានកែសម្រួលបន្ថែមខ្លឹមសារមួយចំនួនដកស្រង់ពីច្បាប់ស្តីពីជលផល ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន អនុក្រឹត្យស្តីពីការបង្កើត និងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស និងគោលការណ៍ស្ម័គ្រចិត្តជាអន្តរជាតិស្តីពីអភិបាលកិច្ចដោយទទួលខុសត្រូវលើវិស័យដីធ្លី ជលផល និងព្រៃឈើ (ហៅកាត់ VGGT)។ ម.ស.ម.ក បានធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំនេះជាលើកទី២ នៅឆ្នាំ២០២៤ ដោយបានកែសម្រួលប្រធានបទមួយចំនួន ដែលជាច្បាប់ និងបទប្បញ្ញត្តិពីមុនពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិត្រូវបានអនុវត្តហើយផ្ទុយនឹងបទប្បញ្ញត្តិនៃក្រមបរិស្ថាន និងធនធានធម្មជាតិថ្មី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣។ យោងតាមមាត្រា៨៦៥ នៃក្រមបរិស្ថាន និងធនធានធម្មជាតិថ្មី ក្រមនេះត្រូវយកទៅអនុវត្តក្នុងរយៈពេល១ (មួយ) ឆ្នាំ ក្រោយការចូលជាធរមាននៃក្រមនេះ។

សៀវភៅណែនាំស្តីពី "**សុវត្ថិភាពកាន់កាប់ និងគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិនៅតំបន់ឆ្នេរ**" គឺជាសៀវភៅមេរៀនសម្រាប់អ្នកសម្របសម្រួលសហគមន៍នេសាទ និងសហគមន៍តំបន់ការពារធម្មជាតិនៅតំបន់ឆ្នេរ ដែលអាចប្រើប្រាស់បានដើម្បីផ្ទេរចំណេះដឹងដល់ប្រជាពលរដ្ឋនិងសមាជិកសហគមន៍ដទៃទៀត ដែលរងផលប៉ះពាល់ដោយសារទំនាស់ដីធ្លី និងការទាញយកផលពីធនធានធម្មជាតិនៅតំបន់ឆ្នេរ យល់ដឹងអំពីភាពស្របច្បាប់ និងភាពមិនស្របច្បាប់ក្នុងការកាន់កាប់ និងគ្រប់គ្រង ដី ផ្ទះ និងធនធានធម្មជាតិនៅតំបន់ឆ្នេរ ដើម្បីធ្វើសេចក្តីសម្រេចចិត្តដោយត្រឹមត្រូវ ឈានដល់ការស្វែងរកដំណោះស្រាយដោយអហិង្សា ប្រកបដោយការគាំទ្រដើម្បីការពារដី ផ្ទះ ដី សហគមន៍ និងធនធានធម្មជាតិរបស់ពួកគាត់ដោយភាពស្របច្បាប់ និងមានសក្តានុពល។

## សេចក្តីថ្លែងអំណរគុណ

សៀវភៅណែនាំស្តីពី **"សុវត្ថិភាពកាន់កាប់ដីធ្លី និងធនធានធម្មជាតិនៅតំបន់ឆ្នេរ"** កើតជារូបរាងឡើង នៅឆ្នាំ២០២០ ក្រោមកិច្ចឧបត្ថម្ភគាំទ្ររបស់សហភាពអឺរ៉ុប ("EU") ដោយមានកិច្ចសហការណ៍ពីអង្គការ អាក់សិនអេតកម្ពុជា (AAC) និងមជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រីនៅកម្ពុជា (CWDCC) ក្នុងប្រតិបត្តិការនៃគម្រោងសុវត្ថិភាព សិទ្ធិកាន់កាប់ និងគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ សម្រាប់សហគមន៍នេសាទងាយរងគ្រោះនៅតំបន់ឆ្នេរនៃប្រទេសកម្ពុជា។ សៀវភៅណែនាំស្តីពី **"សុវត្ថិភាពកាន់កាប់ដីធ្លី និងធនធានធម្មជាតិនៅតំបន់ឆ្នេរ"** ដែលត្រូវបានកែសម្រួលក្នុងឆ្នាំ២០២៤នេះ គឺត្រូវបានធ្វើឡើងក្នុងអំឡុងពេលប្រតិបត្តការនៃគម្រោង "ពង្រឹងសមត្ថភាពសង្គមស៊ីវិលដើម្បីចូលរួមក្នុងអភិបាលកិច្ចសេដ្ឋកិច្ច" សហការគាំទ្រមូលនិធិដោយសហភាពអឺរ៉ុប ("EU") និងដោយមានកិច្ចសហការពីអង្គការ អាក់សិនអេតកម្ពុជា (AAC) អង្គការតម្លាភាពកម្ពុជា (TIC) អង្គការទិន្នន័យអំពីការអភិវឌ្ឍ (ODC) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGOF) មជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌ (MPC) អង្គការមជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រីកម្ពុជា (CWDCC) និង អង្គការស្រឡាញ់ធនធានធម្មជាតិកម្ពុជា (CNRO)។

ម.ស.ម.ក ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អង្គការ អាក់សិនអេតកម្ពុជា អង្គការតម្លាភាពកម្ពុជា អង្គការទិន្នន័យអំពីការអភិវឌ្ឍ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា មជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌ អង្គការមជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រីកម្ពុជា និងអង្គការស្រឡាញ់ធនធានធម្មជាតិកម្ពុជា ដែលបានចូលរួមសហការផ្តល់យោបល់ចងក្រង និងកែសម្រួលសៀវភៅណែនាំនេះឡើង។

ខ្លឹមសារនៃសៀវភៅណែនាំនេះគឺជាការទទួលខុសត្រូវទាំងស្រុងរបស់ ម.ស.ម.ក និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបនោះទេ។

## ចម្ងល់ និងមតិចូលរួម

ប្រសិនបើលោកអ្នកមានសំណួរឬត្រូវការព័ត៌មានបន្ថែមពាក់ព័ន្ធនឹងសៀវភៅណែនាំនេះ ឬមានបំណងចង់ផ្តល់ជាមតិយោបល់ សូមសរសេរមកកាន់ ម.ស.ម.ក តាមរយៈអ៊ីម៉ែល info@cchrcambodia.org ។ ម្យ៉ាងទៀត លោកអ្នកអាចទាក់ទងម.ស.ម.ក តាមរយៈ ៖

អាសយដ្ឋាន៖ ផ្ទះលេខ៧៩៨ ផ្លូវ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

អ៊ីមែល ៖ info@cchrcambodia.org

ទូរសព្ទ៌ ៖ ៨៥៥ (0) ២៣ ៧២៦ ៩០១

ទូរសារ ៖ ៨៥៥ (0) ២៣ ៧២៦ ៩០១

វែបសាយ ៖ www.cchrcambodia.org

រូបគម្របមុខ ៖ ទីតាំងតំបន់ឆ្នេរសមុទ្រមួយកន្លែងនៅខេត្តកំពត។ រូបភាពថតដោយ ម.ស.ម.ក (CC) CCHR

CC BY NC SA

# មាតិកា


មេរៀនទី១ ៖ សុវត្ថិភាពកាន់កាប់ដីធ្លី និងធនធានធម្មជាតិនៅតំបន់ឆ្នេរគឺជាសិទ្ធិមនុស្ស ..... ១
១.១. និយមន័យសិទ្ធិមនុស្ស ..... ១
១.២. ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ..... ២
មេរៀនទី២ ៖ សុវត្ថិភាពកាន់កាប់ដីធ្លី និងធនធានធម្មជាតិនៅតំបន់ឆ្នេរ ..... ៤
២.១. និយមន័យ ..... ៤
២.២. សំយោគ ..... ៥
មេរៀនទី៣ ៖ ច្បាប់ភូមិបាលឆ្នាំ២០០១ ..... ៦
៣.១. ការធ្វើចំណាត់ថ្នាក់ដីធ្លី ..... ៦
៣.១.១. ដីសាធរណៈរបស់រដ្ឋ ..... ៧
ក) និយមន័យ ..... ៧
ខ) ប្រភេទដីសាធារណៈរបស់រដ្ឋ ..... ៧
គ) សិទ្ធិលើដី/ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ..... ៧
៣.១.២. ដីឯកជនរបស់រដ្ឋ ..... ៨
ក) និយមន័យ ..... ៨
ខ) សិទ្ធិលើដីឯកជនរបស់រដ្ឋ ..... ៨
គ) ការហាមឃាត់សិទ្ធិលើដីឯកជនរបស់រដ្ឋ ..... ៨
៣.១.៣. ដីឯកជន/បុគ្គល ..... ៨
ក) និយមន័យ ..... ៨
ខ) សិទ្ធិលើដីឯកជន ឬបុគ្គល ..... ៨
៣.២. លទ្ធកម្មនៃកម្មសិទ្ធិ ..... ៩
៣.២.១. សិទ្ធិធម្មានុរូប ..... ៩
ក) និយមន័យ ..... ៩
ខ) គោលបំណង ..... ៩
គ) ការកំណត់អត្តសញ្ញាណរបស់អ្នកកាន់កាប់ធម្មានុរូបក្នុងវិស័យដីធ្លីនិងជលផល ..... ១០
៣.២.២. ភោគៈត្រឹមត្រូវតាមច្បាប់ ..... ១១
ក) តើភោគៈជាអ្វី? ..... ១១
ខ) តើភោគីជាអ្វី? ..... ១១
គ) តើភោគៈយ៉ាងម៉េចដែលអាចក្លាយទៅជាកម្មសិទ្ធិស្ថាពរបាន? ..... ១១
ឃ) តើលក្ខណៈអ្វីខ្លះដើម្បីបានភោគៈស្របច្បាប់? ..... ១១
ង) សិទ្ធិលើដីភោគៈ ..... ១២

ច) ការដកហូតដីភោគៈដោយរដ្ឋ ..... ១២
មេរៀនទី៤ ៖ សម្បទានដី ..... ១៣
៤.១. តើសម្បទានដីជាអ្វី? ..... ១៣
៤.២. សម្បទានដីសង្គមកិច្ច ..... ១៣
៤.៣. សម្បទានដីសេដ្ឋកិច្ច ..... ១៤
៤.៤. តើអ្វីជាតំបន់សេដ្ឋកិច្ចពិសេស? ..... ១៥
៤.៤.១. គោលបំណងនៃការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ..... ១៥
៤.៤.២. ស្ថាប័នទទួលខុសត្រូវលើតំបន់សេដ្ឋកិច្ចពិសេស ..... ១៦
៤.៤.៣. លក្ខខណ្ឌដើម្បីទទួលបានតំបន់សេដ្ឋកិច្ចពិសេស ..... ១៦
៤.៤.៤. យន្តការដាក់ពាក្យទាក់ទងតំបន់សេដ្ឋកិច្ចពិសេស ..... ១៧
ក) ទំនាស់នៅលើដីធ្លី ..... ១៧
ខ) ទំនាស់លើផ្ទៃទឹក/ដែននេសាទ ..... ១៩
មេរៀនទី៥ ៖ ច្បាប់ជលផល ..... ២០
៥.១. តើអ្វីជាសហគមន៍នេសាទ? ..... ២០
៥.១.១. គោលបំណងនៃការបង្កើតសហគមន៍នេសាទ ..... ២០
៥.២. កិច្ចព្រមព្រៀងសហគមន៍នេសាទ ..... ២១
៥.៣. ផែនការគ្រប់គ្រងសហគមន៍នេសាទ ..... ២២
៥.៤. តួនាទី ភារកិច្ច សិទ្ធិរបស់សហគមន៍នេសាទ និងសិទ្ធិរបស់សមាជិក ..... ២៣
៥.៥. បទល្មើសជលផល និងទោសប្បញ្ញត្តិ ..... ២៣
៥.៥.១. និយមន័យ ..... ២៣
៥.៥.២. បទល្មើសជលផល និងទោសប្បញ្ញត្តិ ..... ២៤
៥.៥.៣. ដំណោះស្រាយវិវាទ ..... ២៦
ក) នៅក្នុងផែនការគ្រប់គ្រងសហគមន៍គេត្រូវគិតគូរទុកជាមុនអំពីការដោះស្រាយវិវាទ ..... ២៦
ខ) យន្តការដោះស្រាយវិវាទគួររួមបញ្ចូលនូវ ..... ២៦
គ) ក្នុងករណីវិវាទនីមួយៗគេគួរកំណត់នូវ ..... ២៦
មេរៀនទី៦ ៖ ក្រមបរិស្ថាន និងធនធានធម្មជាតិ ..... ២៨
៦.១. ការប្រកាសឱ្យប្រើ ..... ២៨
៦.២. គោលបំណង ការអនុវត្ត និងនិរាករណ៍ ..... ២៨
៦.៣. តំបន់ការពារធម្មជាតិ ..... ២៩
៦.៤. ប្រភេទនៃតំបន់ការពារធម្មជាតិ ..... ២៩
៦.៥. ការកំណត់ និងការចាត់ចែងតំបន់គ្រប់គ្រង ..... ៣០
ក) តំបន់ស្នូល ..... ៣០

ខ) តំបន់អភិរក្ស ............................................................................................................ ៣០
គ) តំបន់ប្រើប្រាស់ដោយចីរភាព ............................................................................................ ៣០
ឃ) តំបន់សហគមន៍ ............................................................................................................ ៣០
៦.៦. សិទ្ធិចូលរួមចូលរួមផ្តល់មតិរបស់បុគ្គលដែលរងផលប៉ះពាល់ ........................................ ៣១
៦.៧. សិទ្ធិទទួលបានព័ត៌មានអំពីបរិស្ថាន និងធនធានធម្មជាតិ ............................................... ៣១
៦.៨. សហគមន៍តំបន់ការពារធម្មជាតិ និងសិទ្ធិ ....................................................................... ៣១
ក) ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ........................................................................ ៣១
ខ) ការចូលរួមរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ដោយលើកទឹកចិត្តទាំងសប្បុរសជន វិស័យឯកជន និងសង្គមស៊ីវិល ........................................................................................ ៣២
គ) ការចូលរួម និងសិទ្ធិបរបស់សហគមន៍មូលដ្ឋាន សាធារណជន និង សង្គមស៊ីវិល....... ៣២
ឃ) ការប្រើប្រាស់ធនធានធម្មជាតិ ........................................................................................ ៣៣
ង) សកម្មភាពហាមឃាត់សម្រាប់សហគមន៍តំបន់ការពារធម្មជាតិ .......................................... ៣៣
៦.៩. ការហាមឃាត់សកម្មភាពបង្កផលប៉ះពាល់ដល់ធនធានធម្មជាតិ ........................................ ៣៤
៦.១០. ការអប់រំ ការផ្សព្វផ្សាយ ការស្តារ និងការកែលម្អតំបន់ការពារធម្មជាតិ ........................... ៣៥
៦.១១. ការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការគ្រប់គ្រងធនធានធម្មជាតិតំបន់ឆ្នេរ តំបន់កោះ និង សមុទ្រ ............................................................................................................................ ៣៦
ក) ស្ថាប័នទទួលខុសត្រូវ ..................................................................................................... ៣៦
ខ) ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ......................................................... ៣៦
គ) រដ្ឋបាលថ្នាក់ក្រោមជាតិ .................................................................................................. ៣៧
៦.១២. ការគ្រប់គ្រងជលផល ..................................................................................................... ៣៩
ក) ស្ថាប័នទទួលខុសត្រូវ ..................................................................................................... ៣៩
ខ) តួនាទីនិងភារកិច្ច .......................................................................................................... ៣៩
គ) កិច្ចគាំពារនិងការអភិរក្សជលផល .................................................................................... ៤០
ឃ) សកម្មភាពដែលត្រូវហាមឃាត់ .......................................................................................... ៤០
ង) សកម្មភាពដែលត្រូវអនុញ្ញាត ............................................................................................ ៤០
ច) ការគ្រប់គ្រងការនេសាទក្នុងតំបន់សហគមន៍ និងតំបន់ប្រើប្រាស់ដោយចីរភាព......... ៤១
ច/១ សិទ្ធិប្រជាពលរដ្ឋ ..................................................................................................... ៤១
ច/២ ប្រភេទនៃការធ្វើនេសាទ ............................................................................................ ៤១
ច/៣ ការធ្វើនេសាទ ......................................................................................................... ៤១
៦.១៣. ទេសចរណ៍ធម្មជាតិ ....................................................................................................... ៤២
ក) ក្រួងស្ថាប័នទទួលខុសត្រូវ ............................................................................................... ៤២
ខ) តួនាទី និងភារកិច្ច ......................................................................................................... ៤២

គ) កាតព្វកិច្ចរបស់គម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិ..............................៤២
ឃ) ការយកថ្លៃចូលទស្សនាសហគមន៍ទេសចរណ៍ធម្មជាតិ..................................៤៣
ង) សកម្មភាពដែលត្រូវហាមឃាត់.........................................................................៤៣
៦.១៤. បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ...........................................៤៤
មេរៀនទី៧ ៖ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម....................................................៤៦
៧.១. ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ........................................................................ ៤៦
ក) គោលបំណងនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ............................................ ៤៦
ខ) ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ...................................................... ៤៦
គ) តើអ្វីជាធនធានធម្មជាតិ? ................................................................................៤៧
ឃ)ស្ថាប័នទទួលខុសត្រូវក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ ................................ ៤៨
ង) វិសាលភាពនៅក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ.......................................... ៤៨
ច) គម្រោងលើកលែងក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ........................................ ៤៨
ឆ) ការពិគ្រោះយោបល់ជាមុនក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ............................ ៤៨
៧.២. ការចូលរួមជាសាធារណៈក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន........................... ៤៩
ក) គោលបំណងនៃការចូលរួមជាសាធារណៈ ........................................................... ៤៩
ខ) សិទ្ធិរបស់អ្នកចូលរួមជាសាធារណៈក្នុងការធ្វើសកម្មភាព ........................................ ៤៩
គ) គន្លឹទី៩ នៃក្រមបរិស្ថាន និងធនធានធម្មជាតិ អំពីការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ............................................................................................................. ៥០
ឃ) គោលការណ៍ផ្សព្វផ្សាយជាសាធារណៈក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ .......... ៥២
មេរៀនទី៨ ៖ ការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ និងការទប់ស្កាត់សកម្មភាពអសកម្ម.................................... ៥៣
៨.១. សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជា ................................៥៣
៨.១.១. ឆ្នេរសមុទ្រ ...................................................................................................៥៣
៨.១.២. ដែនទឹកសមុទ្រ និងការនេសាទ.......................................................................... ៥៤
៨.២. គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរប្រទេសកម្ពុជា................................. ៥៤
៨.២.១. សមាសភាព................................................................................................. ៥៤
៨.២.២. តួនាទី......................................................................................................... ៥៥
ឯកសារយោង........................................................................................................................៥៧

# ១. សុវត្ថិភាពកាន់កាប់ដីធ្លី និងធនធានធម្មជាតិ នៅតំបន់ឆ្នេរគឺជាសិទ្ធិមនុស្ស

ធនធានធម្មជាតិនៅតំបន់ឆ្នេរ គឺជាជម្រករបស់មច្ឆាជាតិដែលមានសារៈសំខាន់បំផុត ជាអាយុជីវិតសម្រាប់ប្រជាពលរដ្ឋខ្មែររាប់លាននាក់ ដោយផ្តល់ស្បៀងអាហារ ជា ចំណូល និងការរស់នៅហើយគួបផ្សំនឹងអង្គរត្រីដែលជាផ្នែកមួយសំខាន់នៃសន្តិសុខស្បៀងបានផ្តល់ជា ប្រូតេអ៊ីន ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។ ទន្ទឹមនឹងនេះ ដីធ្លី គឺជាតម្រូវការចាំបាច់មិនអាចខ្វះបានរបស់មនុស្សគ្រប់រូប រួមទាំងប្រជាពលរដ្ឋនៅតំបន់ឆ្នេរដើម្បីមានលំនៅឋានសមរម្យ និងប្រកបមុខរបរកសិកម្មទ្រទ្រង់សេដ្ឋកិច្ចគ្រួសារ។ មនុស្សមានតម្រូវការជាច្រើនទៀតដែលអាចទ្រទ្រង់ពួកគេ អាចរស់នៅបានក្នុងភាពជាមនុស្ស ប្រកបដោយតម្លៃ និងសេចក្តីថ្លៃថ្នូរ ស្របតាមន័យបច្ចេកទេសហៅថា "សិទ្ធិមនុស្ស" ដូចជាសិទ្ធិទទួលការអប់រំ សេរីភាពបញ្ចេញមតិ សិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ។ល។ ក៏ប៉ុន្តែសិទ្ធិមនុស្សទាំងអស់នោះមិនអាចកើតមានបានឡើយសម្រាប់មនុស្ស ប្រសិនបើពុំមាន ដីធ្លី និងធនធានធម្មជាតិ។ ដូចនេះ ការកាន់កាប់គ្រប់គ្រងដីធ្លី និងធនធានធម្មជាតិនៅតំបន់ឆ្នេរប្រកបដោយសុវត្ថិភាព គឺជាសិទ្ធិមនុស្ស។

## ១.១. និយមន័យសិទ្ធិមនុស្ស

***តើអ្វីទៅជាសិទ្ធិ?*** សិទ្ធិគឺជាតម្រូវការចាំបាច់របស់មនុស្សគ្រប់រូប ប៉ុន្តែមានមូលដ្ឋាននៅលើ ៖

***សីលធម៌***
- ការគោរពចាស់ទុំ
- ការគោរពគ្នាទៅវិញទៅមក
- ការដឹងខុស ដឹងត្រូវ
- ការប្រព្រឹត្តតែអំពើល្អ

***ច្បាប់***
- ជាវិន័យសម្រាប់ថែរក្សាសណ្តាប់ធ្នាប់ ឬ របៀបរៀប រយ សន្តិសុខនិងយុត្តិធម៌ រវាងបុគ្គល និងបុគ្គល ដែលរស់នៅសង្គមជាមួយគ្នា ។
- មិនគោរពច្បាប់គឺមានទោស។

- ***ក្នុងន័យសាមញ្ញ ៖*** គឺយើងផ្សារភ្ជាប់ពាក្យ "សិទ្ធិ" (តម្រូវការចាំបាច់) និងពាក្យ "មនុស្ស" យើងបានមកនូវន័យ/ពាក្យពិសេសមួយ គឺ "សិទ្ធិមនុស្ស" ដែលប្រែថាជាតម្រូវការចាំបាច់របស់មនុស្ស ។
- ***ន័យក្នុងវិស័យសិទ្ធិមនុស្ស ៖*** សិទ្ធិមនុស្សគឺជាអ្វីៗដែលសំខាន់ចាំបាច់សំរាប់ការរស់រានមានជីវិតប្រកបដោយតម្លៃ និងសេចក្តី ថ្លៃថ្នូរក្នុងភាពជាមនុស្ស ។

## ១.២. ច្បាប់សិទ្ធិមនុស្សអន្តរជាតិ




***សិទ្ធិមនុស្សក្នុងន័យច្បាប់អន្តរជាតិ*** ៖ មិនមែនសិទ្ធិទាំងអស់សុទ្ធតែត្រូវបានចាត់ទុកថាជាសិទ្ធិមនុស្សទេ។ មានតែសិទ្ធិទាំងឡាយណាដែលយល់ព្រមគ្នាក្នុងចំណោមប្រទេសសមាជិកនៃ អ.ស.ប ថា ជាសិទ្ធិក្រោមការការពារនៃច្បាប់អន្តរជាតិប៉ុណ្ណោះ ដែលអាចចាត់ទុកយ៉ាងត្រឹមត្រូវ ថាជា សិទ្ធិមនុស្ស។ សិទ្ធិមនុស្សគឺផ្តោតទៅលើបណ្តាសិទ្ធិជាមូលដ្ឋានទាំងឡាយរបស់មនុស្ស ដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្សដែលមាន ៣០ មាត្រា អនុម័តដោយមហាសន្និបាតរបស់ អ.ស.ប នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។ អាចហៅថាជាបញ្ជីសិទ្ធិមនុស្សរបស់ អ.ស.ប។

**ធម្មនុញ្ញសិទ្ធិមនុស្សអន្តរជាតិ**

⇩

**សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស**

**កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងនយោបាយ**
កម្ពុជាផ្តល់សច្ចាប័ណ្ណថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩២

ច្បាប់សិទ្ធិមនុស្សអន្តរជាតិ

**កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**
កម្ពុជាផ្តល់សច្ចាប័ណ្ណថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩២

***សិទ្ធិមូលដ្ឋានរបស់មនុស្សមាន ៥***

- **សិទ្ធិពលរដ្ឋ** ៖ ទាក់ទងនឹងការរស់រានមានជីវិតរបស់បុគ្គល ដូចជា ពុំមានការធ្វើទារុណកម្មចំពោះជនណាម្នាក់ដោយឃោរឃៅអមនុស្សធម៌ ពុំមានការឃុំឃាំង ខុសច្បាប់ សិទ្ធិសេរីភាពបញ្ចេញមតិ ការរួមប្រជុំ សមភាពចំពោះមុខច្បាប់ ។ល។
- **សិទ្ធិនយោបាយ** ៖ ទាក់ទងការចូលរួមចំណែកក្នុងរដ្ឋាភិបាល ដូចជាសិទ្ធិបោះឆ្នោតឈរឈ្មោះជាបេក្ខជន បង្កើតគណបក្សនយោបាយ ចូលរួមគណបក្សនយោបាយ។

- **សិទ្ធិសេដ្ឋកិច្ច** ៖ ទាក់ទងនឹងសន្តិសុខ សុខមាលភាព ដូចជាសិទ្ធិមានការងារធ្វើ ប្រកបមុខរបរ មានផ្ទះសម្បែង ដីធ្លីស្នាក់ នៅសមរម្យ ។ល។
- **សិទ្ធិសង្គម** ៖ ទាក់ទងសិទ្ធិចូលរួមសម្ពន្ធក្នុងគ្រួសារនិង ការទទួលស្គាល់របស់សង្គមដូចជា សិទ្ធិរៀបអាពាហ៍ពិពាហ៍ ទទួលបានការថែទាំសុខភាព ទទួលការអប់រំ ។ល។
- **សិទ្ធិវប្បធម៌** ៖ ទាក់ទងនឹងសិទ្ធិសម្តែងមនោសញ្ចេតនា ដូចជា ភ្លេង របាំ សម្លៀកបំពាក់ ភាសា ។ល។

ការផ្សារភ្ជាប់បទដ្ឋានសិទ្ធិមនុស្សក្នុងច្បាប់ជាតិ (ច្បាប់កម្ពុជា) ត្រូវបានធ្វើឡើងតាមនីតិវិធី (វិធីតាមផ្លូវច្បាប់) ពីរយ៉ាង[1] ៖

**ទី១.** អនុលោម (យល់ព្រមតាម មិនទទឹងទាស់) កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស[2] ដែលបានបញ្ជាក់ពីការដាក់បញ្ចូលបទដ្ឋានសិទ្ធិមនុស្សនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

**ទី២.** មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានបញ្ចូលដោយផ្ទាល់នូវលិខិតុបករណ៍សំខាន់ៗមួយចំនួននៅក្នុងច្បាប់កម្ពុជា។

**ក-** សេចក្តីប្រកាសអំពីសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា

កិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ ១៩៩១ ដែលបញ្ជាក់ជាផ្លូវការនូវជម្លោះកម្ពុជាបានបង្កើតបទដ្ឋានសិទ្ធិ មនុស្សអន្តរជាតិជាមូលដ្ឋានមួយ សម្រាប់សន្តិភាពជា អមតៈនៅកម្ពុជា។ មាត្រា១៥ នៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមនៃជម្លោះកម្ពុជាចែងថា ៖

*"ជនគ្រប់រូបនៅកម្ពុជា និងជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងនៅកម្ពុជា ត្រូវមានសិទ្ធិ និងសេរីភាពដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដទៃទៀតដែលពាក់ ព័ន្ធ"* ។

**ខ-** សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ដែលបានធានាការពារដោយរដ្ឋធម្មនុញ្ញ

កិច្ចព្រមព្រៀងទីក្រុងប៉ារីសបានបញ្ចូលការប្តេជ្ញាចិត្ត ដ៏ជាក់លាក់ ក្នុងការផ្តល់សច្ចាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស អន្តរជាតិនានា ។ អាស្រ័យហេតុនេះ កម្ពុជាបានក្លាយជា ភាគីនៃសន្ធិសញ្ញានានា ឧទាហរណ៍ខ្លះៗ ដូចខាងមានក្រោមនេះ ៖

- អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍ (២៨ ធ្នូ ១៩៨៣)
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹង ស្ត្រីភេទ (១៥ វិច្ឆិកា ១៩៩២)
- អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តលើខ្លួន ឬទារុណម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬ បន្ថោកបន្ទាប (១៤ វិច្ឆិកា ១៩៩២) ។ល។

*ក្រុមប្រឹក្សាធម្មនុញ្ញគឺជាស្ថាប័នមួយដែលបានបង្កើតឡើង ដើម្បីធានាការគោរពរដ្ឋធម្មនុញ្ញ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញបានបញ្ជាក់ជាថ្មីអំពីការអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានានៅក្នុងច្បាប់កម្ពុជា ហើយបានរំលឹកថៅក្រមថា ការសម្រេចករណីរឿងផ្សេងៗ ចៅក្រមត្រូវយកច្បាប់កម្ពុជាទាំងអស់មកពិចារណា "រួមទាំងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល និងច្បាប់ឯទៀតដែលនៅជាធរមាន ព្រមទាំងអនុសញ្ញាអន្តរជាតិទាំងអស់ដែលកម្ពុជាទទួលស្គាល់....."* ។

---

[1] ច្បាប់សិទ្ធិមនុស្សម្ពុជា សេចក្តីប្រកាសសិទ្ធិមនុស្សក្នុងរដ្ឋមនុញ្ញកម្ពុជា និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលធានាការពារដោយរដ្ឋធម្មនុញ្ញ ដែលចងក្រងដោយការិយាល័យនៃឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ខែកញ្ញា ឆ្នាំ២០២១២។

[2] ដែលចុះហត្ថលេខាកាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ នៅទីក្រុងប៉ារីស ដើម្បីបញ្ចប់សង្គ្រាមស៊ីវិលខ្មែរ ដែលមាន១៨ ប្រទេសរួមទាំង កម្ពុជា មាន៤ភាគី គឺ ៖ រដ្ឋកម្ពុជា ហ៊ុនស៊ិនប៉ិច រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ របស់លោកតា សឺន សាន និងខ្មែរក្រហម ដែលរួមបញ្ចូលគ្នា បង្កើតជា ក្រុមប្រឹក្សាជាតិ" "ជាន់ខ្ពស់ ។

# ២. សុវត្ថិភាពកាន់កាប់ដីធ្លី និងធនធានធម្មជាតិនៅតំបន់ឆ្នេរ

សុវត្ថិភាពកាន់កាប់ដីធ្លី និងធនធានធម្មជាតិ[3]នៅតំបន់ឆ្នេរ គឺជាប្រធានបទសំខាន់មួយដែលសហគមន៍នេសាទនៅតំបន់ឆ្នេរគួរស្វែងយល់ពីនិយមន័យជាក់លាក់ ដោយផ្អែកទៅលើអំណះអំណាង ដែលអាចពន្យល់បានជាលក្ខណៈសាមញ្ញ និងអាចទទួលយកបានដោយភាគីពាក់ព័ន្ធ។ ទោះជាយ៉ាងណា ពុំទាន់មានការពន្យល់យ៉ាងទូលំទូលាយនៅឡើយទេ អំពីអត្ថន័យ "សុវត្ថិភាពកាន់កាប់ដីធ្លី និងធនធានធម្មជាតិនៅតំបន់ឆ្នេរ" នៅក្នុងបរិបទកម្ពុជា ដូច្នេះការពិភាក្សាស្វែងយល់លើប្រធានបទនេះ នឹងអាចបណ្តុះថ្នាលគំនិតរបស់ប្រជាសហគមន៍នេសាទនៅតំបន់ឆ្នេរគ្រប់ជំនាន់តទៅ អំពីការកាន់កាប់ដីធ្លី និងធនធានធម្មជាតិរបស់ខ្លួនប្រកបដោយសុវត្ថិភាព និងនិរន្តរភាព។

## ២.១. និយមន័យ

***តើសុវត្ថិភាពមានន័យដូចម្តេច?***




[3] តាមវាក្យស័ព្ទក្នុងឧបសម្ព័ន្ធនៃក្រមបរិស្ថាន និងធនធានធម្មជាតិ ធនធានធម្មជាតិ ៖ សំដៅដល់ចំណែកមួយនៃបរិស្ថានធម្មជាតិ មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូតគាម ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ និងធនធានជលផល។

*និយមន័យ សុវត្ថិភាពកាន់កាប់ដីធ្លី នៅក្នុងសៀវភៅ ស្តីអំពី "ដីធ្លី និងសិទ្ធិមនុស្ស មាត្រដ្ឋាន (ខ្នាតគំរូ) និងការអនុវត្ត" របស់ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស។*

សុវត្ថិភាពកាន់កាប់ដីធ្លី ៖ អាចពន្យល់បានថា ជាទំនាក់ទំនង រវាងបុគ្គល ក្រុមរបស់បុគ្គល ឬមនុស្សច្រើនគ្នា (ជាក្រុម) ទាក់ទងនឹងដីធ្លី។ ក្នុងន័យទូលាយ ប្រព័ន្ធ សុវត្ថិភាពកាន់កាប់ដីធ្លី អាចកំណត់បានថា ជាមនុស្ស (អ្នកណាក៏ដោយ) ដែលអាចកាន់កាប់ ប្រើប្រាស់ដីធ្លីក្នុងរយៈពេល និងលក្ខខណ្ឌចាំបាច់។ សុវត្ថិភាពកាន់កាប់ដីធ្លីត្រូវបានកំណត់ក្នុងច្បាប់ និងទំនៀមទម្លាប់។

កម្មសិទ្ធិដី/ប្លង់កម្មសិទ្ធិ ដែលទទួលស្គាល់ដោយច្បាប់ មិនមែនជាទម្រង់តែមួយគត់នៃសុវត្ថិភាពកាន់កាប់ដីធ្លីនោះទេ។ ទស្សនទាន/ផ្នត់គំនិតជាសកល សុវត្ថិភាព កាន់កាប់ដីធ្លី រួមមានទម្រង់ផ្សេងៗគ្នានៃសិទ្ធិកាន់កាប់ដីធ្លី ដូចជាការជួល ការកាន់កាប់ការប្រើប្រាស់ដីជាទូទៅ សុវត្ថិភាពកាន់កាប់ដីធ្លីរបស់ជនជាតិដើមភាគតិច ជាការប្រើប្រាស់ដីតាមរដូវកាល ឬការប្រើប្រាស់ដីសម្រាប់ប្រមូលធនធាន។

*ចំណុចត្រូវចងចាំ*

សុវត្ថិភាពកាន់កាប់ដីធ្លី ត្រូវបានផ្តល់នូវនិយមន័យច្បាស់លាស់ ដើម្បីទទួលស្គាល់ និងការពារសិទ្ធិកាន់កាប់ដីធ្លីរបស់បុគ្គល និង មនុស្សជាក្រុម ក្នុងករណីមានភាពប្រឈមជាក់លាក់ណាមួយ ឧទាហរណ៍ សិទ្ធិរបស់បុគ្គល ឬមនុស្សជាក្រុមដែលត្រូវបានការពាររួចផុតពីការបណ្តេញចេញដោយបង្ខំ។

## ២.២. សំយោគ

សរុបសេចក្តី ក្នុងនិយមន័យដែលបានរកឃើញទាំងប៉ុន្មាន ដូចបានបង្ហាញពីខាងដើមត្រូវបានកំណត់ជាទស្សនទាន ឬការផ្តល់គំនិត ការយល់ឃើញ ប្រហាក់ប្រហែលគ្នាថា ពាក្យ ***"សុវត្ថិភាព"*** គឺការរួចផុតពីហានិភ័យ/គ្រោះថ្នាក់នានាដែលកើតចេញពីអំពើហិង្សា ឬទង្វើដោយអចេតនា (លទ្ធផលដែលនឹងកើតមាន ឡើងដោយមិនបានដឹងជាមុន ឬបង្កឡើងដោយបុគ្គលដទៃទៀត មិនមែនជាខ្លួនឯង)។ សុវត្ថិភាព គឺរួមបញ្ចូលទាំងការរស់នៅដោយប្រសើរ មានសិទ្ធិ សេរីភាព រួចផុតពីការគំរាមកំហែង ការបង្ខិតបង្ខំ និងមានការការពារមិនឱ្យមានការបាត់បង់ គ្មានការបំផ្លិចបំផ្លាញ។ សុវត្ថិភាពកាន់កាប់ដីធ្លីក៏ត្រូវបានផ្តល់និយមន័យយ៉ាងទូលំទូលាយ នៅក្នុងសៀវភៅ/ឯកសារ ស្តីពី "ដីធ្លី និងសិទ្ធិមនុស្ស មាត្រដ្ឋាន និងការអនុវត្ត" របស់ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សខាងលើរួចមកហើយដែរ ដូច្នេះ ៖

- *និយមន័យ ដែលបានលើកឡើងខាងលើទាក់នឹងពាក្យ "សុវត្ថិភាព" និងសុវត្ថិភាពកាន់កាប់ដីធ្លី បានបង្ហាញអំពីទស្សនទានរួមគ្នាមួយនូវការធានាដល់ការកាន់កាប់ដីធ្លីរបស់មនុស្ស ប្រកបដោយសុវត្ថិភាព។ ក្នុងគោលគំនិតដាក់បន្ថែម ឬដាក់បញ្ចូលធនធានធម្មជាតិនៅតំបន់ឆ្នេរ រួមគ្នាទៅនឹងសុវត្ថិភាពកាន់កាប់ដីធ្លី គឺបានផ្តល់នូវអត្ថន័យពិសេសមួយបានមកដល់ "សុវត្ថិភាពកាន់កាប់ដីធ្លី និងធនធានធម្មជាតិនៅតំបន់ឆ្នេរ" ដែលមានខ្លឹមសារថា ប្រជាពលរដ្ឋមានសិទ្ធិកាន់កាប់ដីធ្លី និងធនធានធម្មជាតិនៅតំបន់ឆ្នេរប្រកបដោយសុត្ថិភាព ដោយមានសេរីភាពលើកឡើងអំពីការការពារ និងការដាក់ស្នើឡើងនូវគោលនយោបាយរួមមួយដែលធានាថាការកាន់កាប់របស់ពួកគាត់ គឺរួចផុតពីហានិភ័យនានា រួមទាំងការគំរាមកំហែង និងមានការការពារមិនឱ្យមានការបាត់បង់ បំផ្លិចបំផ្លាញ និងបណ្តេញចេញដោយបង្ខំ ដោយកំណត់នៅក្នុងច្បាប់ និងទំនៀមទម្លាប់ (ផ្សារភ្ជាប់នឹងសិទ្ធិធម្មនុរូប) ដែលនឹងលើកមកពិភាក្សាក្នុងមេរៀនបន្ទាប់។*

# ៣. ច្បាប់ភូមិបាល ឆ្នាំ២០០១

ច្បាប់ភូមិបាលបានប្រកាសប្រើនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។ ច្បាប់នេះមានគោលដៅ កំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាការពារសិទ្ធិនៃកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុស្របតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា។

នៅច្បាប់ភូមិបាលនេះ ក៏បានកំណត់បង្ហាញអំពីការធ្វើចំណាត់ថ្នាក់ដីលទ្ធកម្ម នៃកម្មសិទ្ធិ ភោគៈស្របតាមច្បាប់ និងដំណោះស្រាយដោយផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ផងដែរ ប្រសិនជាមានការដកហូតដោយរដ្ឋ។

## ៣.១ ការធ្វើចំណាត់ថ្នាក់ដីធ្លី

បើយោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ នៅក្នុងប្រទេសកម្ពុជា ដីត្រូវបានបែងចែកជាប្រភេទដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ ដីឯកជន(ដីរបស់បុគ្គលម្នាក់ ឬច្រើននាក់) ដីរបស់សហគមន៍ជនជាតិដើមភាគតិច និងដីរបស់វត្ត។

ប្រភេទដីនីមួយៗមានការកំណត់ច្បាស់ថា តើអ្នកណាខ្លះអាចកាន់កាប់បាន ហើយការកាន់កាប់នោះក្នុងគោលគោលបំណងអ្វី ។



### ៣.១.១. ដីសាធារណៈរបស់រដ្ឋ

#### ក. និយមន័យ

ដីសាធារណៈរបស់រដ្ឋ ជាដីសម្រាប់បំរើដល់ផលប្រយោជន៍សាធារណៈ។

#### ខ. ប្រភេទដីសាធារណៈរបស់រដ្ឋ

យោងតាមមាត្រា១៥ នៃច្បាប់ភូមិបាលបានចែងរៀបរាប់អំពីដី និងទ្រព្យដែលចាត់ចូលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមានដូចជា ៖

- ទ្រព្យទាំងឡាយដែលបង្ហាញនូវការកើតឡើងពីធម្មជាតិដូចជា ព្រៃឈើ ផ្លូវទឹក ដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន បឹងធម្មជាតិ ច្រាំងទន្លេដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន និងត្រើយសមុទ្រ។
- ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសំរាប់ប្រយោជន៍ទូទៅ ដូចជាកំពង់ផែ ផ្លូវដែក ស្ថានីយរថភ្លើង និងព្រលានយន្តហោះ។
- ទ្រព្យទាំងឡាយ ដែលត្រូវបានដាក់ឲ្យប្រើប្រាស់ជាសាធារណៈ តាមស្ថានភាពពី កំណើត ឬក្រោយពីការរៀបចំដូចជាផ្លូវថ្នល់ ផ្លូវលំ ផ្លូវរទេះ ផ្លូវដើរ សួនច្បារ និងឧទ្យានសាធារណៈ និងដីចំណីផ្លូវ។
- ទ្រព្យទាំងឡាយ ដែលត្រូវបានដាក់ឲ្យដំណើរការសេវាសាធារណៈ ដូចជា សាលារៀន ឬអគារសិក្សាសាធារណៈ អគាររដ្ឋបាល មន្ទីរពេទ្យសាធារណៈទាំងឡាយ ។
- ទ្រព្យទាំងឡាយដែលបង្កើតជាដែនបំរុងធម្មជាតិការពារដោយច្បាប់។
- បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ។
- អចលនវត្ថុជាព្រះរាជទ្រព្យដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស។ អចលនវត្ថុជាព្រះរាជទ្រព្យត្រូវបានចាត់ចែងដោយព្រះមហាក្សត្រកំពុងគ្រងរាជ្យ។
- ដីផ្សេងៗទៀត ដែលមានចរិតបំរើផលប្រយោជន៍សាធារណៈ និងមានមូលដ្ឋានច្បាប់កំណត់ហើយ ដូចជា ប្រឡាយបង្ហូរទឹកសម្រាប់ស្រោចស្រពស្រែចំការ ឬបង្ហូរទឹកដែលបានប្រើប្រាស់ហើយ (ក្នុងមាត្រា៤ នៃអនុក្រឹត្យការគ្រប់គ្រងដីរដ្ឋ)។

#### គ. សិទ្ធិលើដី/ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ

- ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចលក់ដូរបានឡើយ។
- កម្មសិទ្ធិនៃទ្រព្យសម្បត្តិទាំងនោះ មិនអាចកំណត់អាជ្ញាយុកាល ប៉ុន្តែអាចជាកម្មវត្ថុនៃការអនុញ្ញាតឱ្យកាន់កាប់ ឬប្រើប្រាស់ជាបណ្តោះអាសន្នមិនទៀងហើយដកហូតវិញបាន។

*<u>សំគាល់</u>៖ នៅពេលបាត់បង់ផលប្រយោជន៍សាធារណៈ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋអាចត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ តាមរយៈច្បាប់អនុបយោគ។*

## ៣.១.២. ដីឯកជនរបស់រដ្ឋ

### ក. និយមន័យ

- មិនមែនជាដីសាធារណៈរបស់រដ្ឋ (មាត្រា១៦)
- មិនមែនជាដីដែលកាន់កាប់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិឯកជន ឬសមូហភាព។
- ទ្រព្យនិទាយាទភាព (គ្មានទាយាទបន្ត) ទាំងអស់។
- ទ្រព្យដែលម្ចាស់ប្រគល់អោយរដ្ឋដោយស្ម័គ្រចិត្ត។
- ទ្រព្យដែលមិនអាចកំណត់បាននូវអត្តសញ្ញាណភោគី ឬកម្មសិទ្ធិករស្របច្បាប់។
- ដីសាធារណៈរបស់រដ្ឋនៅពេលបាត់បង់ផលប្រយោជន៍សាធារណៈ អាចចាត់បញ្ចូល ជាដីឯកជនរបស់រដ្ឋ ។

### ខ. សិទ្ធិលើដីឯកជនរបស់រដ្ឋ

ដី ឬទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ រដ្ឋ ឬស្ថាប័នរដ្ឋអាចមានសិទ្ធិយកទៅធ្វើជាកម្មវត្ថុនៃការលក់ ការដូរ ការជួល ការបែងចែក ឬការផ្ទេរសិទ្ធិតាមការកំណត់ដោយច្បាប់។

### គ. ការហាមឃាត់សិទ្ធិលើដីឯកជនរបស់រដ្ឋ

គ្មានការចូលទៅកាន់កាប់ ឬចាប់យកដីតាមទំនើងចិត្តណាមួយអាចកើតឡើងទៅលើដីឯកជនរបស់រដ្ឋ បានឡើយចាប់ពីច្បាប់នេះចូលជាធរមានពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។

ប៉ុន្តែដីទំនេរនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ អាចត្រូវបានបែងចែកទៅឲ្យបុគ្គល ដែលត្រូវការដីនោះក្នុង គោលដៅសង្គមកិច្ច។

## ៣.១.៣. ដីរបស់ឯកជន/បុគ្គល

### ក. និយមន័យ

ដីឯកជនជាដីកម្មសិទ្ធិ (អ្នកកាន់កាប់មានប័ណ្ណសម្គាល់កម្មសិទ្ធិស្របច្បាប់ជាផ្លូវការ) ឬ ដីភោគៈស្រប ច្បាប់ (អ្នកកាន់កាប់អាចបង្ហាញភស្តុតាងថាពួកគាត់បានរស់នៅលើដីនោះតាំង ពីមុនពេលច្បាប់ភូមិបាលចូលជា ធរមាននៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ និងបង្ហាញ ថាពួកគាត់បានបំពេញលក្ខខណ្ឌ៥ យ៉ាងអំពីភោគៈស្រប ច្បាប់)។

### ខ. សិទ្ធិលើដីឯកជន ឬបុគ្គល

ដីកម្មសិទ្ធិឯកជនអាចជាកម្មសិទ្ធិរបស់បុគ្គលម្នាក់ ក្រុមហ៊ុន ឬកម្មសិទ្ធិរួមដែលមានគ្នាច្រើនលើសពីមួយ នាក់ ឧទាហរណ៍ ប្តី និងប្រពន្ធ។ ហើយបុគ្គលដែលជាម្ចាស់កម្មសិទ្ធិលើដីនេះមានសិទ្ធិដូចជា សិទ្ធិប្រើប្រាស់ សិទ្ធិ អាស្រ័យផល និងសិទ្ធិចាត់ចែងនៅលើដី។

*<u>ចំណាំ</u> ៖ នៅក្នុងប្រភេទនៃការបែងចែកចំណាត់ថ្នាក់ដីក៏មានរាប់បញ្ចូលទាំងដី ដែលគ្រប់គ្រង ដោយ សហគមន៍ជនជាតិដើមភាគតិច និងដីដែលគ្រប់គ្រង ដោយវត្តដែរ។*

## ៣.២. លទ្ធកម្មនៃកម្មសិទ្ធិ

*លទ្ធកម្ម* គឺការបានឡើងជាភោគី ឬជាកម្មសិទ្ធិករនៃវត្ថុណា ដោយការងារបស់ខ្លួនក្តី ដោយទិញក្តី ដោយដូរក្តី ដោយសន្តតិកម្មក្តី (សន្តតិកម្ម គឺការផ្ទេរតាមច្បាប់នូវទ្រព្យសម្បត្តិរបស់អ្នកស្លាប់ទៅឲ្យអ្នករស់)។

## ៣.២.១. សិទ្ធិធម្មានុរូប

### ក. និយមន័យ




*ធម្មានុរូប* មានន័យថា "ភាពស្របច្បាប់"។ បើយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ ១៩៦៧ គឺជាអ្វីដែលមានគុណភាពតាមផ្លូវច្បាប់។ ឧទាហរណ៍ ៖ ចៅហ្វាយស្រុកជាអាជ្ញាធរធម្មានុរូប។ កូនដែលកើតពីឪពុក-ម្តាយដែលមានខាន់ស្លា ហៅថាកូនធម្មានុរូប ឬកូន មានខាន់ស្លា។ បើយោងតាមវចនានុក្រម អង្គការមូលនិធិអាស៊ី (ទំព័រ ២៣៨) ធម្មានុរូប គឺជាអ្វីដែលធ្វើឡើងដោយពេញលក្ខណៈតាមផ្លូវច្បាប់ ត្រូវតាមច្បាប់ ទទួលស្គាល់ដោយច្បាប់ ឬស្របច្បាប់។

សិទ្ធិធម្មានុរូប ជាសិទ្ធិស្របច្បាប់របស់បុគ្គល/ប្រជាពលរដ្ឋ ដែលបានកាន់កាប់លើដីធ្លី/ទឹកតាមទំនៀមទម្លាប់ប្រពៃណី[4]យូរឆ្នាំ នៅលើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដូចជាដែននេសាទ គម្របព្រៃឈើ និងតំបន់ការពារ។ ឧទាហរណ៍ ៖ ដើមច្បោះយកជ័រទឹកដាក់ស្តែងគឺនៅក្នុងព្រៃ (តាមច្បាប់ភូមិបាល ឆ្នាំ២០០១ ព្រៃឈើជាសម្បត្តិសាធារណៈរបស់រដ្ឋ) តែពលរដ្ឋបានកាន់កាប់អាស្រ័យផលលើដើមច្បោះនោះជាយូរមកហើយ ដែលបានដឹងឮជាសាធារណៈដោយអ្នកជិតខាង និងអាជ្ញាធរមូលដ្ឋានផងដែរ។ ឧទាហរណ៍ ៖ ការនេសាទជាលក្ខណៈគ្រួសារនៅលើ បឹងធម្មជាតិ ត្រើយសមុទ្រ (តាមច្បាប់ភូមិបាល ឆ្នាំ២០០១ កំណត់ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ) ប៉ុន្តែប្រជានេសាទបានប្រកបមុខរបរនេសាទតាមទំនៀមទម្លាប់ប្រពៃណីជាយូរឆ្នាំមកហើយដែរ ដែលបានដឹងឮជាសាធារណៈដោយអ្នកជិតខាង និងអាជ្ញាធរមូលដ្ឋាន។

### ខ. គោលបំណង

បង្ហាញដោយសង្ខេបនៅថ្នាក់គោលនយោបាយ[5] ក្នុងវិស័យដីធ្លី និងជលផលប្រៀបធៀបជាមួយគោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីអភិបាលកិច្ច ប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដី ជលផល និងព្រៃឈើ ហៅកាត់ថា "វីជីជីធី" ដើម្បីឆ្លុះបញ្ចាំង និងកំណត់អត្តសញ្ញាណរបស់អ្នកកាន់កាប់ធម្មានុរូបក្នុងវិស័យដីធ្លី និងជលផល។

> ***គោលការណ៍ វីជីជីធី*** គឺជាគោលការណ៍ស្ម័គ្រចិត្ត ត្រូវបានបង្កើតឡើងដោយអង្គការស្បៀង និងកសិកម្មរបស់អង្គការសហប្រជាជាតិ (FAO) កាលពី ឆ្នាំ២០១២ បំពេញមុខងារជា ឯកសារយោងមួយ និងផ្តល់ការណែនាំ កែលម្អអភិបាលកិច្ចលើការកាន់កាប់ ដីធ្លី ជលផល និងព្រៃឈើ ដោយមានគោលដៅរួមសម្រេចឱ្យបាននូវសន្តិសុខស្បៀងសម្រាប់មនុស្សគ្រប់រូប។

[4] នៅក្នុងគោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដី ជលផលនិងព្រៃឈើ ហៅកាត់ថា "វីជីជីធី"

[5] គឺជាផែនការចង្អុលបង្ហាញរបស់ស្ថាប័នមួយ ឬរដ្ឋាភិបាលនឹងធ្វើ និងអាចសម្រេចបានសម្រាប់សង្គមទាំងមូល។ គោលនយោបាយគឺជាឯកសារផែនការមួយ តែមិនមែនជាច្បាប់ទេ តែគោលនយោបាយទាំងនេះអាចជាការផ្តួចផ្តើមគំនិតសម្រាប់បង្កើតច្បាប់ថ្មី។

## គ. ការកំណត់អត្តសញ្ញាណរបស់អ្នកកាន់កាប់ធម្មានុរូបក្នុងវិស័យដីធ្លី និងជលផល

នៅក្នុងគោលការណ៍ វីជីជីធី បានកំណត់អំពី "ការកាន់កាប់ដីដោយធម្មានុរូប" និង "សិទ្ធិធម្មានុរូបទាំងអស់" ថានៅពេលធ្វើច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តជាតិ រដ្ឋត្រូវគោរពដោយ ៖

១) កំណត់អត្តសញ្ញាណអ្នកកាន់កាប់ធម្មានុរូបដោយធ្វើការកត់ត្រាក្នុងបញ្ជី

២) ការពារសិទ្ធិធម្មានុរូបរបស់អ្នកកាន់កាប់

៣) សម្របសម្រួលឱ្យអ្នកកាន់កាប់ធម្មានុរូបដោយមិនមានការបន្ទុចបង្អាក់

៤) ក្នុងករណីមានការបំពានសិទ្ធិធម្មានុរូបលើដីធ្លីនោះ រដ្ឋត្រូវមានយន្តការប្រកបដោយប្រសិទ្ធិភាពឱ្យម្ចាស់សិទ្ធិធម្មានុរូបរកយុត្តិធម៌តាមច្បាប់ ផុតពីការគំរាមកំហែងឬអំពើពុករលួយទាំងឡាយ។

តាមច្បាប់ភូមិបាល ឆ្នាំ២០០១ បុគ្គលគ្រប់រូបមានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិដីរបស់ខ្លួន បន្ទាប់ពីបានបំពេញការកាប់កាប់ដីដោយស្របច្បាប់ (ហៅថាភោគៈ) មុនថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ រយៈពេល ៥ ឆ្នាំ យ៉ាងតិច និងកាន់កាប់ពិតប្រាកដ គ្មានហិង្សា គេដឹងឮជាសាធារណៈ គ្មានការអាក់ខាន និងដោយសុចរិត។ ទោះជាយ៉ាងណា មិនទាន់មានប្រព័ន្ធចុះបញ្ជី ភោគៈ ជាផ្លូវការនៅក្នុងសៀវភៅគោលបញ្ជីសុរិយោដីនៅឡើយទេ។ អ្នកកាន់កាប់ធម្មានុរូប ក៏មានសណ្ឋានដូចគ្នានេះដែរ គឺកាន់កាប់ អាស្រ័យផលយ៉ាងពិតប្រាកដ គ្មានហិង្សា គេដឹងឮជាសាធារណៈ គ្មានខកខាន និងដោយសុចរិត។ ប៉ុន្តែអ្នកកាន់កាប់ធម្មានុរូប មិនទាន់ត្រូវបានចេញលិខិតទទួលស្គាល់ការកាន់កាប់ ការកត់ត្រាទុកឬចុះបញ្ជីដោយអាជ្ញាធរមូលដ្ឋាន ឬស្ថាប័នសាធារណៈនៅឡើយ។

ច្បាប់ស្តីពីជលផលជាធរមាននៃព្រះរាជាណាចក្រកម្ពុជា មានវិសាលភាពអនុវត្តលើរាល់ដែននេសាទទាំងអស់ដែលកំណត់ក្នុងជំពូក ៣ នៃច្បាប់នេះ និងបានចែងថា រដ្ឋជានាសិទ្ធិប្រើប្រាស់ជាប្រពៃណីនូវធនធានជលផលនៅក្នុងដែននេសាទក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងច្បាប់ស្តីពីតំបន់ការពារធម្មជាតិក៏បានធានាសិទ្ធិទាំងនេះដែរ។ ធនធានជលផល ត្រូវបានអនុញ្ញាតឱ្យធ្វើការនេសាទជា លក្ខណៈគ្រួសារនៅគ្រប់ពេលវេលា និងដែននេសាទ ដោយប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ។ ទោះជាយ៉ាងណា ក្របខ័ណ្ឌគតិយុត្តជាធរមានមិនចែងច្បាស់អំពី "សិទ្ធិធម្មានុរូបលើដែនជលផល ឬជលផល" នៃអ្នកកាន់កាប់សិទ្ធិប្រើប្រាស់ដូចមាននៅក្នុងគោលការណ៍ វីជីជីធី ឡើយ និងមិនមានការចុះបញ្ជីសិទ្ធិប្រើប្រាស់ ឬសិទ្ធិអាស្រ័យផលលើជលផលទេ ហើយក៏មិនមានលិខិតសម្គាល់អ្វីមួយ ចេញឱ្យអ្នកកាន់កាប់សិទ្ធិធម្មានុរូបដែរ។ ហើយក៏ពុំមានយន្តការដោះស្រាយនៅពេលដែលអ្នកកាន់កាប់សិទ្ធិធម្មានុរូបរងផលប៉ះពាល់ ដកហូត ឬបំពាន ដែរ។ កិច្ចព្រមព្រៀងសហគមន៍នេសាទមានរយៈពេល ៣ឆ្នាំ តែអាចបន្តបាន។ រដ្ឋមន្ត្រីក្រសួងកសិកម្ម អាចលុបចោលនៃកិច្ចព្រមព្រៀងនោះបាន សម្រាប់ប្រយោជន៍សាធារណៈ។

ហេតុនេះ ទស្សនទាននៃគោលការណ៍ **វីជីជីធី** ក្នុងវិស័យដីធ្លី និងជលផល គឺមានតម្លៃសមរម្យបំផុតក្នុងការដាក់បញ្ចូលក្នុងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីឱ្យមានការទទួលស្គាល់ ការធានា និងការពារសិទ្ធិអ្នកកាន់កាប់ធម្មានុរូប។

## ៣.២.២ ភោគៈត្រឹមត្រូវតាមច្បាប់

### ក. តើភោគៈជាអ្វី?

គឺជាសភាពការណ៍មួយដែលមានន័យថា កិរិយាកាន់កាប់នូវវត្ថុណាមួយយ៉ាងផ្ដាច់មុខតែម្នាក់ឯង និងបំពេញចំពោះវត្ថុនោះនូវកិច្ចការទាំងឡាយដូចដែលកម្មសិទ្ធិករបានបំពេញហើយដែរ។ មានន័យថាដើម្បីមានភោគៈ បុគ្គលដែលជាអ្នកកាន់កាប់ត្រូវបង្ហាញថា ខ្លួនកំពុងកាន់កាប់ដី ខ្លួនបានបំពេញភារៈជាកម្មសិទ្ធិករ ហើយមានបំណងចង់ក្លាយជាកម្មសិទ្ធិករ (តាមច្បាប់ភូមិបាលឆ្នាំ១៩៩២)។

- តាមច្បាប់ភូមិបាល ឆ្នាំ២០០១ ៖ ភោគៈគឺជាសិទ្ធិដែលជនម្នាក់ៗមានលើទ្រព្យណាមួយជាបណ្ដោះអាសន្នមិនស៊ប់ជារបស់ខ្លួនមែនទែន។

  ឧទាហរណ៍ ៖ ដីមានប្លង់ជាកម្មសិទ្ធិ ឯដីមិនទាន់មានប្លង់សុរិយោដី ជាដីភោគៈ។

**សំគាល់៖ កម្មសិទ្ធិ និងភោគៈជាស្ថានភាពពីរខុសគ្នា៖**

- **ភោគៈ ៖ ជាស្ថានភាពកាន់កាប់ដោយយកសភាពការណ៍កាន់កាប់ជាសំអាង**
- **កម្មសិទ្ធិ៖ ជាស្ថានភាពគតិយុត្តិដោយយកច្បាប់ជាសំអាង**

### ខ. តើភោគីជាអ្វី?

ភោគី គឺជាអ្នកទទួលបានភោគៈ។

### គ. តើភោគៈយ៉ាងម៉េចដែលអាចប្រែក្លាយទៅជាកម្មសិទ្ធិស្ថាពរបាន?

- បានអាស្រ័យផលនៃភោគៈដោយសន្តិវិធី (ភោគៈត្រឹមត្រូវតាមច្បាប់)។
- បានកាន់កាប់កន្លងមកដោយមិនមានការជំទាស់ ចាប់ពីរយៈពេល ៥ឆ្នាំ យ៉ាងតិចគិតមកដល់កាលបរិច្ឆេទនៃការប្រកាសឲ្យប្រើច្បាប់នេះ។

### ឃ. តើមានលក្ខណៈអ្វីខ្លះដើម្បីបានភោគៈស្របច្បាប់?

- ការកាន់កាប់ដោយគ្មានហិង្សា (សន្តិវិធី ឬសន្តិភាព) គឺថាភោគៈដែលបានមកដោយហិង្សាមិនចាត់ទុកជាភោគៈត្រឹមត្រូវតាមច្បាប់ឡើយ។ ប៉ុន្តែបើកាលណាគេប្រើហិង្សាក្នុងពេលមានតតិយជនឥតសិទ្ធិសោះមកដណ្ដើមនោះ ហិង្សានេះគ្មានឥទ្ធិពលអ្វីទៅលើភោគៈដែលគេបានដោយសន្តិភាពតាំងពីដើមមកនោះទេ។
- ការកាន់កាប់ដោយសុចរិតគឺថា ភោគីមិនបានដឹងពីសិទ្ធិជាយថាហេតុរបស់តតិយជនលើវត្ថុដែលខ្លួនកំពុងកាន់កាប់នោះសោះ។
- ការកាន់កាប់ដោយពិតប្រាកដ (ច្បាប់ពីដើមប្រើពាក្យ "ឥតព្រលាំ") គឺថាភោគីនោះកាន់កាប់ដោយខ្លួនឯងក្ដី ឲ្យអ្នកដទៃធ្វើឲ្យក្ដី ត្រូវកាន់កាប់ឲ្យឃើញថាការនោះប្រាកដជាធ្វើដើម្បីខ្លួនក្នុងគោលបំណងខ្លួនជាភោគីយ៉ាងផ្ដាច់មុខ កុំឲ្យឃើញថាការណ៍ដែលធ្វើនោះ គឺធ្វើដោយសារសិទ្ធិណាមួយផ្សេងទៀតវិញ។ ប្រសិនបើភោគីពិតប្រាកដមិនចេញមុខ មានន័យថាគាត់នៅពីក្រោយភោគីមិន

ពិតប្រាកដ ភោគីនោះមិនអាចទាមទារប័ណ្ណភោគៈ ធ្វើលទ្ធកម្មទៅជាកម្មសិទ្ធិបានឡើយ (ភោគៈនោះត្រូវចាត់ទុកជាមោឃៈ)។

- ការកាន់កាប់ដោយការដឹងឮជាសាធារណៈ គឺថាភោគីត្រូវកាន់កាប់ដោយឥតលាក់ បិទបាំងពីអ្នកទាំងពួងដែលចង់តវ៉ាអំពីសិទ្ធិរបស់ខ្លួនលើវត្ថុនោះ និងបានដឹងឮឃើញមិនខាន។ (បានឃើញថាមិនអាក់ខាន)។
- ការកាន់កាប់ដោយគ្មានការអាក់ខាន (ច្បាប់ពីដើមប្រើពាក្យ "ជានិរន្តរ៍") គឺថាភោគីត្រូវធ្វើនូវកិច្ចការផងទាំងពួងតាមធម្មតា ជាប្រក្រតីក្នុងរយៈពេលចាំបាច់ នៃការទាមទារលទ្ធកម្មកម្មសិទ្ធិ។ ការអាក់ខាន ក្នុងរយៈពេលខ្លី ឬបោះបង់ទុកឲ្យនៅទំនេរដើម្បីឲ្យមានដីជាតិឡើងវិញមិនមែនជាឧបសគ្គដល់លទ្ធកម្មកម្មសិទ្ធិនោះទេ។

> ***<u>ចំណាំ</u> ៖***
>
> - ***ការចូលកាន់កាប់ភោគៈ ត្រូវបញ្ចប់ ចាប់ពីច្បាប់ភូមិបាលចូលជាធរមាននៅថ្ងៃទី៣០ ខែ សីហា ឆ្នាំ ២០០១។***

## ង. សិទ្ធិលើដីភោគៈ

តើភោគីមានសិទ្ធិអ្វីខ្លះលើដីរបស់ខ្លួន? ភោគីមានសិទ្ធិលើដីប្រហែលនឹងកម្មសិទ្ធិករដែរគឺ ៖




## ច. ការដកហូតដីភោគៈដោយរដ្ឋ

ក្នុងករណីបើមានការដកហូតដីភោគៈដោយអាជ្ញាធរណាមួយ ដោយប្រើអំណាចរំលោភ ឬដោយហិង្សា ម្ចាស់ដីភោគៈ (ភោគី) មានសិទ្ធិប្ដឹងទាមទារដីត្រឡប់មកវិញក្នុងរយៈពេល ៣ឆ្នាំ ចាប់ពីថ្ងៃដែលរដ្ឋប្រកាសដកហូត។ ដីភោគៈដែលរដ្ឋដកហូតនោះត្រូវទុកក្នុងការកាន់កាប់ដោយរដ្ឋ ហើយមិនអាចជាកម្មវត្ថុនៃការកាន់កាប់ថ្មីបានឡើយ បើគ្មានបណ្ដឹងទាមទារពីភោគីស្របច្បាប់នៃដីនោះ (មាត្រា ៣៣)។ ចំពោះដីដែលកាន់កាប់ដោយភោគីស្របច្បាប់ នៅពេលមានការដកហូតដោយរដ្ឋដើម្បីបំរើផលប្រយោជន៍សាធារណៈ រដ្ឋត្រូវធ្វើការផ្ដល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។

# ៤. សម្បទានដី

## ៤.១. តើសម្បទានដីជាអ្វី?

បើយោងតាមច្បាប់ភូមិបាលឆ្នាំ ២០០១ សម្បទានដីគឺជាការប្រគល់ដីជាកម្មសិទ្ធិឯកជនរបស់រដ្ឋដោយអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋដើម្បីទៅអោយរូបវន្តបុគ្គល ឬនីតិបុគ្គល ឬក្រុមមនុស្សដើម្បីកាន់កាប់ និងប្រើប្រាស់តាមកាលកំណត់នៃច្បាប់។

បន្ថែមពីនេះ រដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យចំនួន ២ ស្តីអំពីសម្បទានដី ៖

អនុក្រឹត្យលេខ ១៩ ស្តីអំពីសម្បទានដីសង្គមកិច្ចមានដូចជា ដីលំនៅដ្ឋាន និងដីកសិកម្ម។



អនុក្រឹត្យលេខ ១៤៦ ស្តីអំពីសម្បទានដីសេដ្ឋកិច្ច ៖ ការប្រគល់ដីទៅអោយវិនិយោគទុនដែលតម្រូវអោយអ្នកវិនិយោគទុននោះបង់ប្រាក់ជូនរដ្ឋ។




មានសម្បទានជាច្រើនទៀតដែលមិនស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ភូមិបាល



សម្បទានរ៉ែ | សម្បទានកំពង់ផែ | សម្បទានព្រលានយន្តហោះ | សម្បទានរៀបចំតំបន់ឧស្សាហកម្ម | សម្បទាននេសាទ

## ៤.២. សម្បទានដីសង្គមកិច្ច

សម្បទានដីសង្គមកិច្ចគឺជាការផ្តល់ដីជាកម្មសិទ្ធិឯកជនរបស់រដ្ឋដោយឥតគិតថ្លៃសម្រាប់ការសាងសង់លំនៅដ្ឋានឬសំរាប់ធ្វើកសិកម្ម



គ្រួសារក្រីក្រ



គ្រួសារផ្លាស់លំនៅដោយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ



គ្រួសាររងគ្រោះដោយគ្រោះធម្មជាតិ



ក្រុមគ្រួសារដែលធ្វើមាតុភូមិនិវត្តន៍ យោធិនរំសាយ និងគ្រួសារយុទ្ធជនពលីពិការ




## ៤.៣. សម្បទានដីសេដ្ឋកិច្ច



## ៤.៤. តើអ្វីតំបន់សេដ្ឋកិច្ចពិសេស?



ច្បាប់កម្ពុជាបានកំណត់ តំបន់សេដ្ឋកិច្ចពិសេសថាជាមជ្ឈមណ្ឌលពិសេសសម្រាប់អភិវឌ្ឍន៍ក្នុងវិស័យសេដ្ឋកិច្ច ដែលប្រមូលផ្តុំនូវសកម្មភាពឧស្សាហកម្ម និងសកម្មភាពពាក់ព័ន្ធដទៃទៀត ហើយអាចរាប់បញ្ចូលតំបន់ឧស្សាហកម្មទូទៅ ឬតំបន់ផលិតកែច្នៃសម្រាប់នាំចេញ។ តំបន់សេដ្ឋកិច្ចពិសេសនីមួយៗ មានមណ្ឌលផលិតកម្ម និងអាចមានមណ្ឌលពាណិជ្ជកម្មសេរី មណ្ឌលសេវាកម្ម មណ្ឌលលំនៅដ្ឋាន និងមណ្ឌលទេសចរណ៍។[6]





តំបន់សេដ្ឋកិច្ចពិសេស អាចមានទម្រង់ផ្សេងៗគ្នា ដូចជាតំបន់ផលិតកែច្នៃនាំចេញ ឬកំពង់ផែសេរីស្ថិតនៅក្នុងទីតាំង ដែលស្ថានភាពក្នុងទីតាំងនោះមានដូចជាហេដ្ឋារចនាសម្ព័ន្ធមិនទាន់ល្អ ដែលអាចបង្អាក់ដល់ការវិនិយោគផងដែរ។[7] គឺជាតំបន់ ដែលមានការអនុញ្ញាតទទួលបានការអនុគ្រោះដោយមានបទប្បញ្ញត្តិ ជាអាទិភាព ដូចជាការលើកលែងពន្ធលើប្រាក់ចំណេញ និងពន្ធនាំចូលក៏ដូចជាមជ្ឈមណ្ឌលការិយាល័យច្រកចេញចូលតែមួយដែលមានតំណាងមកពីនាយកដ្ឋានផ្សេងៗគ្នារបស់រដ្ឋាភិបាល ដើម្បីបំពេញតម្រូវការផ្នែករដ្ឋបាលទាំងអស់សម្រាប់សកម្មភាពដោយផ្ទាល់នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។[8]

### ៤.៤.១. គោលបំណងនៃការបង្កើតតំបន់សេដ្ឋកិច្ចពិសេស



ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ រដ្ឋាភិបាលកម្ពុជាមានគោលបំណងកៀរគរធនធានមនុស្ស ហិរញ្ញវត្ថុ និងស្ថាប័នធនធានដើម្បីជួយដល់ការបង្កើតឧស្សាហកម្មថ្មី[10] ។ ការកំណត់នេះនាំឱ្យមានការបង្កើត និងការពង្រឹងតំបន់សេដ្ឋកិច្ចពិសេស ដើម្បីទាក់ទាញវិនិយោគទុនបរទេស ជំរុញការផ្ទេរបច្ចេកវិទ្យានិងពង្រីកទីផ្សារនាំចេញ។

ក្នុងរបាយការណ៍រដ្ឋាភិបាលឆ្នាំ២០១២ ស្តីអំពីគោលនយោបាយដីធ្លីបានណែនាំថា ការអភិវឌ្ឍក្នុងតំបន់សេដ្ឋកិច្ចពិសេសគួរផ្សារភ្ជាប់ទៅនឹងគោលនយោបាយលំនៅដ្ឋាន ដើម្បីបញ្ចៀសការធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើនិងជានាផលប្រយោជន៍នៃការអភិវឌ្ឍសេដ្ឋកិច្ច ប្រកបដោយសមធម៌ក្នុងចំណោមទីតាំងភូមិសាស្ត្រក្នុងតំបន់។[9]

---

[6] អនុក្រឹត្យលេខ ១៤៨ (មាត្រា ២)

[7] ដូចប្រភពខាងលើ

[8] អនុក្រឹត្យ លេខ ១៤៨ (មាត្រា ៦៦)

[9] អង្គការទិន្នន័យអំពីការអភិវឌ្ឍ

## ៤.៤.២. ស្ថាប័នទទួលខុសត្រូវលើតំបន់សេដ្ឋកិច្ចពិសេស

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ("ក.អ.ក") ដែលមានសមាសភាពចូលរួមពីទេសរដ្ឋមន្ត្រីមកពីបណ្តាស្ថាប័នរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធ ហើយមាននាយករដ្ឋមន្ត្រីជាប្រធាន មានភារកិច្ចក្នុងការស្តារការអភិវឌ្ឍ និងត្រួតពិនិត្យសកម្មភាពវិនិយោគ ហើយជាទូទៅទទួលខុសត្រូវចំពោះការបង្កើតនិងប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេស។ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ("គ.ស.ព") ដែលជាអង្គភាពមួយក្នុងចំណោមអង្គភាពទាំងបួនដែលជាសមាជិករបស់ ក.អ.ក ទទួលបន្ទុកអភិវឌ្ឍន៍និងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជា។ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ជាអ្នកគ្រប់គ្រងប្រតិបត្តិការរបស់តំបន់សេដ្ឋកិច្ចពិសេស និងត្រូវដាក់របាយការណ៍សង្ខេប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិរបស់ ក.អ.ក។ គ.ស.ព ត្រូវបានបង្កើតឡើងដោយតំណាងមកពីស្ថាប័នរដ្ឋាភិបាល ហើយមានបែកចែកជា ៤ នាយកដ្ឋានដូចជា ផ្នែកគោលនយោបាយនិងផែនការ ផ្នែកប្រតិបត្តិការ និងគ្រប់គ្រង ផ្នែកវិភាគគម្រោង និងចុះបញ្ជី និងផ្នែករដ្ឋបាល។[10]

## ៤.៤.៣. លក្ខខណ្ឌដើម្បីទទួលបានតំបន់សេដ្ឋកិច្ចពិសេស

ដើម្បីទទួលបានការអនុញ្ញាត តំបន់សេដ្ឋកិច្ចពិសេស ត្រូវធ្វើតាមលក្ខខណ្ឌដូចខាងក្រោម ៖

- ទីតាំងត្រូវមានទំហំយ៉ាងហោចណាស់ ៥០ ហិកតាឡើងទៅ ហើយព័ទ្ធជុំវិញទៅដោយរបង។
- ត្រូវមានមណ្ឌលផលិតកម្ម និងអាចមានមណ្ឌលតំបន់ពាណិជ្ជកម្មសេរី មណ្ឌលសេវាកម្ម មណ្ឌលលំនៅដ្ឋាន និងមណ្ឌលទេសចរណ៍។
- តំបន់នេះតម្រូវអោយមានហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ អគារការិយាល័យ ទឹក ប្រព័ន្ធអគ្គីសនី និងប្រព័ន្ធលូ វិធានការការពារបរិស្ថាន។
- តំបន់សេដ្ឋកិច្ចពិសេសត្រូវគោរពតាមការណែនាំរបស់ក្រសួង ឬស្ថាប័នពាក់ព័ន្ធ។ នៅពេលដែលតំបន់សេដ្ឋកិច្ចពិសេសត្រូវបានទទួលការអនុញ្ញាតិឲ្យប្រតិបត្តិការនោះ អនុក្រឹត្យមួយនឹងត្រូវបានអនុម័តដើម្បីកំណត់ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងព្រំប្រទល់ខណ្ឌសីមានៃតំបន់នោះ។[11]



[10] សលាកប័ត្រព័ត៌មាន ៖ តំបន់សេដ្ឋកិច្ចពិសេស និងសិទ្ធិមនុស្សនៅកម្ពុជា របស់ ម.ស.ម.ក

[11] អនុក្រឹត្យលេខ ១៤៨ មាត្រា ៣៣

## ៤.៤.៤. យន្តការដាក់ពាក្យបណ្តឹងទាក់ទងតំបន់សេដ្ឋកិច្ចពិសេស

ទោះជាយ៉ាងណា ពុំទាន់មានយន្តការប្តឹងតវ៉ាឬផ្តល់ព័ត៌មានប្រកបដោយប្រសិទ្ធភាពណាមួយ ដែលសហគមន៍រងផលប៉ះពាល់ដោយសារតំបន់សេដ្ឋកិច្ចពិសេស អាចរាយការណ៍អំពីការរំលោភបំពានលើសិទ្ធិមនុស្ស។ នេះផ្ទុយនឹងកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាថារាល់ការរំលោភសិទ្ធិមនុស្សត្រូវបានធ្វើការស៊ើបអង្កេតឱ្យបានត្រឹមត្រូវ និងដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាពឡើយ។




តំបន់សេដ្ឋកិច្ចពិសេសអាចត្រូវបានផ្តល់ឱ្យវិនិយោគិននៅលើដីធ្លី និងនៅលើទឹក (តំបន់ឆ្នេរ) ដែលជាទីនេសាទរបស់សហគមន៍នេសាទនៅតំបន់ឆ្នេរ។ យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៥ ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារប្តឹងតវ៉ាឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយ បណ្តឹងតវ៉ានិងសំណងជួសជុលការខូចខាតគឺជាសមត្ថកិច្ចរបស់តុលាការ។ ហេតុនេះ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារតំបន់សេដ្ឋកិច្ចពិសេស អាចមានសិទ្ធិដាក់ពាក្យបណ្តឹងតាមរយៈយន្តការបណ្តឹងផ្សេងគ្នាដូចខាងក្រោម ៖

### ក. ទំនាស់នៅលើដីធ្លី



## ១.ក្រុមប្រឹក្សាឃុំសង្កាត់

ក្នុងករណីមានទំនាស់កើតឡើងក្នុងតំបន់របស់លោកអ្នក ដំបូងគឺអ្នកអាចដាក់បណ្ដឹងទៅក្រុមប្រឹក្សាឃុំសង្កាត់ដែលមានតួនាទីជាអ្នកសម្រុះសម្រួលនៅថ្នាក់មូលដ្ឋានមុនពេលករណីនោះអាចត្រូវបញ្ជូនបន្តទៅថ្នាក់លើ (ដូចជាគណៈកម្មការសុរិយោដីជាដើម)



## ២.គណៈកម្មការសុរិយោដី

គណៈកម្មការសុរិយោដីមានបេសកកម្មដោះស្រាយវិវាទទាក់ទងនឹងអចលវត្ថុដែលមិនទាន់ចុះបញ្ជីសុរិយោដី។



គណៈកម្មការនេះមានបែងចែកថ្នាក់ស្រុកខណ្ឌ ថ្នាក់ខេត្តក្រុង និងថ្នាក់ជាតិ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ → គណៈកម្មការសុរិយោដីថ្នាក់ខេត្តក្រុង → គណៈកម្មការសុរិយោដីថ្នាក់ជាតិ

## ៣.គណៈកម្មការរដ្ឋបាល

គណៈកម្មការរដ្ឋបាលត្រូវបានបង្កើតឡើងដើម្បីដឹកនាំការចុះបញ្ជីជាប្រព័ន្ធនៅក្នុងតំបន់វិនិច្ឆ័យ។ ភារកិច្ចមួយនៃគណៈកម្មការនេះគឺធ្វើការដោះស្រាយវិវាទដីធ្លីដែលកើតមាននៅក្នុងអំឡុងពេលនៃការចុះបញ្ជីជាលក្ខណៈជាប្រព័ន្ធ។




## ៤.អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីគឺជាយន្តការថ្នាក់ជាតិបំពេញមុខងារបន្ថែមដល់គណៈកម្មការសុរិយោដី។ អាជ្ញាធរនេះនឹងត្រូវបានផ្ដល់សិទ្ធិត្រួតពិនិត្យលើករណីទំនាស់ដីធ្លីនានាដែលផុតពីភារកិច្ចរបស់គណៈកម្មការសុរិយោដី។



## ៥. តុលាការ



តុលាការមានសមត្ថកិច្ចដោះស្រាយទំនាស់ដីណាដែលបានចុះបញ្ជីនិងដីដែលបានផ្ដល់ប័ណ្ណកម្មសិទ្ធិរួចហើយ។ ប៉ុន្តែតុលាការក៏មានសមត្ថកិច្ចដោះស្រាយរាល់វិវាទដីទាំងអស់រួមទាំងដីមិនបានចុះបញ្ជី ដែលភាគីវិវាទមិនបានយល់ព្រមតាមសេចក្ដីសម្រេចរបស់គណៈកម្មការសុរិយោដីផងដែរ។



បន្ថែមទៅលើយន្តការដែលបានរៀបរាប់ខាងលើ ប្រជាពលរដ្ឋអាចសុំជួយអន្តរាគមន៍ផ្ទាល់ពីក្រសួង

## ខ. ទំនាស់នៅលើផ្ទៃទឹក/ដែននេសាទ

***ច្បាប់ជលផល***

***មាត្រា ៩ ៖***

- ដែននេសាទជាទ្រព្យសម្បត្តិរបស់រដ្ឋ។ ដែននេសាទត្រូវកំណត់ដោយអនុក្រឹត្យ។
- រាល់ការប្រើប្រាស់ដែននេសាទដើម្បីគោលបំណងក្រៅវិស័យជលផល ត្រូវមានការសម្រេចពីរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

***មាត្រា ២៨ ៖ ហាមឃាត់*** ការពង្រីកផ្ទៃដីកសិកម្ម ឬការប្រើប្រាស់ដីក្នុងគោលបំណងផ្សេងៗ ក្រៅពីកិច្ចអភិវឌ្ឍន៍ វិស័យជលផលនៅក្នុងតំបន់លិចទឹកដែលត្រូវការពារស្របតាមប្បញ្ញត្តិនៃច្បាប់នេះ។ ហាមការផ្តល់កម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ដីធ្លីនៅក្នុងតំបន់លិចទឹកដែលត្រូវការពារ។ ការកាប់ ការឆ្ការ ការគាស់ ការរាន ការឈូសឆាយ ការដុត ឬការហ៊ុមព័ទ្ធកាន់កាប់ព្រៃលិចទឹក និងព្រៃកោងកាង។ល។

***មាត្រា ៧២ ៖***

- (វាក្យខណ្ឌ២) មន្ត្រីរដ្ឋបាលជលផល មានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតរាល់បទល្មើសជលផល និងចងក្រងសំណុំរឿងប្តឹងទៅតុលាការ។

ក្នុងករណីមានបទល្មើសដូចមានចែងក្នុងមាត្រា ២៨ នៃច្បាប់ជលផល ប្រជានេសាទ/សហគមន៍នេសាទ អាចរាយការណ៍ទៅមន្ត្រីរដ្ឋបាលជលផលដើម្បីចាត់វិធានការតាមសមត្ថកិច្ចរបស់ខ្លួនក្នុងនាមមន្ត្រីនគរបាលយុត្តិធម៌គ្រប់គ្រងក្នុងដែនជលផល និងនេសាទ។




ផលប៉ះពាល់ដោយគម្រោងអភិវឌ្ឍន៍ ប្រ.ព អាចមានសិទ្ធិដាក់បណ្តឹង ឬលិខិតអន្តរាគមន៍ទៅ

***គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា***

**សមាសភាព ៖** នាយករដ្ឋមន្ត្រី ជាប្រធានកិត្តិយស រដ្ឋមន្ត្រីក្រសួងដែនដីជាប្រធាន រដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាអនុប្រធាន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ជាអនុប្រធានអចិន្ត្រៃយ៍ និងសមាសភាពពី ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងស្ថាប័នពាក់ព័ន្ធដទៃទៀតរួមទាំងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាផងដែរជាសមាជិក។ តួនាទីសំខាន់មួយក្នុងចំណោមតួនាទីដទៃទៀតរបស់គណៈកម្មាធិការនេះ គឺ ៖ ពិនិត្យ បង្ការ និងចាត់វិធានការចាំបាច់ ដើម្បីទប់ស្កាត់រាល់សកម្មភាព **(អសកម្ម)** ទាំងឡាយដែលអាចប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិនៅតំបន់ឆ្នេរ។

**រដ្ឋបាលថ្នាក់ក្រោមជាតិ ៖** ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុកខណ្ឌ និងរដ្ឋបាលឃុំសង្កាត់។ តួនាទីមួយក្នុងចំណោមតួនាទីដទៃទៀតរបស់ ក្រុមប្រឹក្សា និងគណៈអភិបាល គឺ ***ចេញដីកា និងសេចក្តីសម្រេចដើម្បីបំរើផលប្រយោជន៍ប្រជាពលរដ្ឋ ឧ. ដូចជា ដីកាការពារ និងការថែរក្សាបរិស្ថាន និងធនធានធម្មជាតិ សេចក្តីសម្រេចទទួលស្គាល់ សហគមន៍មូលដ្ឋាន សេចក្តីសម្រេចស្តីពីការបញ្ឈប់អំពើល្មើសផ្សេងៗ ។ល។***

# ៥. ច្បាប់ជលផល

ជំហានដំបូង យើងត្រូវយល់ដឹងថាតើអ្វីជាធនធានជលផលទឹកប្រៃ? ក្នុងមាត្រា៤ នៃច្បាប់ស្តីពី ជលផលនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា៖ “ធនធានជលផលមានសរីរាង្គទឹកសាប និងសមុទ្រ ជាសត្វ និងរុក្ខជាតិមានជីវិត ជាអាទិ៍ សប្បីសត្វ មច្ឆាជាតិ ថលជលិកសត្វ បាណកសត្វ ឧរង្គសត្វ ចនិកសត្វ សត្វឥតឆ្អឹងកងផ្សេងទៀតដែលបង្កកំណើតនៅក្នុងទឹក ប្លង់តុង សារាយ ស្មៅសមុទ្រ ផ្កាថ្ម ព្រៃលិចទឹក ព្រមទាំងព្រៃកោងកាងជាដើម”។

## ៥.១. តើអ្វីទៅជាសហគមន៍នេសាទ?

អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ (មាត្រា៦) បានកំណត់និយមន័យថា សហគមន៍នេសាទជារូបវន្តបុគ្គលមួយក្រុមមានសញ្ជាតិខ្មែររស់នៅក្នុងឬក្បែរដែននេសាទ មានគំនិតផ្តួចផ្តើមដោយស្ម័គ្រចិត្ត បង្កើតឡើងដើម្បីបង្កើនជីវភាពរស់នៅរបស់ខ្លួនតាមរយៈការប្រើប្រាស់ និងកែច្នៃធនធានជលផលប្រកបដោយនិរន្តរភាព សំដៅរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងកាត់បន្ថយភាពក្រីក្រ។ នៅក្នុងអនុក្រឹត្យដដែលថែមទាំងបានបញ្ជាក់ថា សហគមន៍នេសាទសំដៅដល់ក្រុមប្រជាប្រជាពលរដ្ឋខ្មែរដែលរស់នៅក្នុងភូមិមួយ ឬច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលបានយល់ព្រមសហការគ្នាចូលរួមដោយស្ម័គ្រចិត្តក្នុងការការពារសិទ្ធិ ព្រមទាំងផលប្រយោជន៍ប្រជាពលរដ្ឋខ្មែរស្របតាមលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផល។

យោងតាមនិយមន័យខាងលើ យើងអាចនិយាយបានថាប្រជាពលរដ្ឋខ្មែរទាំងពីរភេទរស់នៅអចិន្ត្រៃយ៍ ក្នុងភូមិឃុំដែននេសាទនោះស្ថិតនៅ យល់ព្រមសហការគ្នាដោយស្ម័គ្រចិត្តដើម្បីគ្រប់គ្រង អភិរក្ស អភិវឌ្ឍ និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព។

**គោលបំណងនៃការបង្កើតសហគមន៍នេសាទគឺដើម្បីកែលម្អជីវភាពរស់នៅ (មាត្រា២)។**

### ៥.១.១. គោលបំណងនៃការបង្កើតសហគមន៍នេសាទ

បើយើងយោងតាមខ្លឹមសារនៃព្រះរាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទ (មាត្រា១)និង អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ (មាត្រា៦)និងប្រកាសស្តីពីគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍នេសាទ (មាត្រា ៥)បានកំណត់គោលបំណងសំខាន់ៗក្នុងការបង្កើតសហគមន៍នេសាទដូចខាងក្រោម៖

- ចូលរួមគ្រប់គ្រង

- ចូលរួមអភិរក្ស
- ប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព និង
- បង្កើនជីវភាពរស់នៅ។

សរុបសេចក្តីមក ការស្ម័គ្រចិត្តសហការគ្នាបង្កើតសហគមន៍នេសាទក្នុងគោលបំណងចូលរួមគ្រប់គ្រង អភិ រក្ស ប្រើប្រាស់ជលផលប្រកបដោយចីរភាព ការពារសិទ្ធិ និងផលប្រយោជន៍ប្រជាពលរដ្ឋខ្មែរ និងដើម្បីបង្កើន ជីវភាព រស់នៅឲ្យកាន់តែល្អប្រសើរ។

## ៥.២. កិច្ចព្រមព្រៀងសហគមន៍នេសាទ

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍នេសាទ គឺជាកិច្ចព្រមព្រៀងតាមលក្ខណៈច្បាប់ ដោយរដ្ឋបាល ជលផល ក្នុងការផ្ទេរដែននេសាទទៅឲ្យសហគមន៍នេសាទគ្រប់គ្រងប្រកដោយនិរន្តរភាពក្នុងរយៈពេល៣ឆ្នាំ។ នៅក្នុងកិច្ចព្រមព្រៀងមានបញ្ជាក់អំពីប្រភេទឧបករណ៍នេសាទ តួនាទីរបស់ខណ្ឌរដ្ឋបាលជលផលក្នុងការគាំទ្រ ស គមន៍នេសាទ និងនីតិវិធីរាយការណ៍អំពីការបំពាននានា។

ដើម្បីឲ្យកិច្ចព្រមព្រៀងសហគមន៍នេសាទមានសុពលភាព ត្រូវមានភាគីពីរចុះហត្ថលេខាទទួលស្គាល់ គឺនាយ ខណ្ឌរដ្ឋបាលជលផល និងគណៈកម្មការសហគមន៍នេសាទ ហើយក៏ត្រូវមានហត្ថលេខាទទួលដឹងឮពីមេឃុំ/ចៅ សង្កាត់ផងដែរ។

ចំណុចសំខាន់ៗដែលត្រូវមាននៅក្នុងកិច្ចព្រមព្រៀងសហគមន៍នេសាទគួរបញ្ចូលនូវធាតុសំខាន់ៗមួយ ចំនួនៈ

- តួនាទី និងការទទួលខុសត្រូវរបស់ភាគីចុះកិច្ចព្រមព្រៀង
- ទីកន្លែង និងទំហំដែននេសាទ
- រយៈពេលគ្រប់គ្រង និងប្រើប្រាស់កន្លែងសហគមន៍នេសាទ
- លក្ខខណ្ឌនៃការគ្រប់គ្រង និងប្រើប្រាស់កន្លែងនេសាទសហគមន៍
- លក្ខខណ្ឌនៃការប្រើប្រាស់ឧបករណ៍នេសាទ
- លក្ខខណ្ឌនៃវិសោធនកម្ម និងការបញ្ចប់កិច្ចព្រមព្រៀង។

កិច្ចព្រមព្រៀងសហគមន៍នេសាទត្រូវតម្កល់ទុកនៅទីស្នាក់ការសហគមន៍នេសាទ សាលាឃុំ រដ្ឋបាល ជលផល សាលាខេត្ត/ក្រុង រដ្ឋបាលជលផលថ្នាក់កណ្តាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថា ប័នពាក់ព័ន្ធផ្សេងទៀត (មាត្រា ២០)។ សុពលភាពនៃកិច្ចព្រមព្រៀងសហគមន៍មិនត្រូវលើសពីរយៈពេល ៣ឆ្នាំ ទេ គិតចាប់ពីការឯកភាពពីនាយខណ្ឌរដ្ឋបាលជលផល។ ដើម្បីបន្តកិច្ចព្រមព្រៀងសហគមន៍នេសាទសាជាថ្មី គណៈកម្មការត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរទៅខណ្ឌរដ្ឋបាលជលផលរយៈពេលពេញ ៦ខែ មុនពេលកិច្ច ព្រមព្រៀងផុតសុពលភាព។ ខណ្ឌរដ្ឋបាលជលផលត្រូវជូនដំណឹងពីការអនុញ្ញាតទៅសហគមន៍នេសាទក្នុងរយៈ ពេល៣០ថ្ងៃមុនថ្ងៃផុតសុពលភាពកិច្ចព្រមព្រៀង បើមិនមានការជូនដំណឹងក្នុងរយៈពេល ៣០ថ្ងៃទេ កិច្ចព្រម ព្រៀងត្រូវបានបន្តដោយស្វ័យប្រវត្តិ។

កិច្ចព្រមព្រៀងសហគមន៍នេសាទ ក៏អាចរំលាយមុនពេលផុតសុពលភាពបានដែរបើសិនមានស្ថានភាពណាមួយឬច្រើនក្នុងចំណោមស្ថានភាពដូចខាងក្រោម៖

- ការឯកភាពគ្នារវាងភាគីទាំងអស់ជាលាយលក្ខណ៍អក្សរ
- ការព្រមព្រៀងគ្នាក្នុងគណៈកម្មការសហគមន៍នេសាទ និងមានការឯកភាព ២៣ ពីសមាជិក/
- ការមិនអនុវត្ត ឬអនុវត្តរំលោភធ្ងន់ធ្ងរលើលក្ខខណ្ឌកិច្ចព្រមព្រៀងកន្លែងនេសាទ និងបទប្បញ្ញត្តិនានាដែលមិនធានានិរន្តរភាពធនធានជលផល
- ការយល់ឃើញរបស់រាជរដ្ឋាភិបាលនូវគោលបំណងផ្សេងមួយទៀត ដែលផ្តល់ប្រយោជន៍សាធារណៈ និង សង្គមចំពោះប្រទេសកម្ពុជាច្រើនជាង។

## ៥.៣. ផែនការគ្រប់គ្រងសហគមន៍នេសាទ

ផែនការគ្រប់គ្រងកន្លែង នេសាទសហគមន៍គឺចង់សំដៅដល់ឯកសារដែលបានរៀបចំឡើងដោយសហគមន៍នេសាទ និងមានការឯកភាពពីរដ្ឋបាលជលផលថ្នាក់កណ្តាល ដោយមានការវាយតម្លៃហេតុប៉ះពាល់សង្គម និងបរិស្ថាន និងបញ្ជាក់លម្អិតពីនីតិវិធី បទបញ្ជា និងវិធានការពាក់ព័ន្ធ និងការរៀបចំប្រើប្រាស់កន្លែងនេសាទសហគមន៍ដោយនិរន្តរភាព។

ផែនការគ្រប់គ្រងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដោយគណៈកម្មការសហគមន៍នេសាទដោយមានជំនួបច្ចេកទេសពីខណ្ឌរដ្ឋបាលជលផលសាមី ដោយផ្អែកតាមគម្រូផែនការគ្រប់គ្រងដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៤ នៃសេចក្តីប្រកាសពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ។ ការធ្វើផែនការនេះមានដំណាក់កាលដូចខាងក្រោម៖

- ប្រមូលព័ត៌មាន៖ គណៈកម្មការត្រូវប្រមូលព័ត៌មានទាក់ទងនឹងស្ថានភាពសេដ្ឋកិច្ច សង្គម ស្ថានភាពនៃការនេសាទ លក្ខណៈនៃដែននេសាទ សកម្មភាពពាក់ព័ន្ធនឹងការនេសាទ ស្ថានភាពកសិកម្ម និងបញ្ហាដែលកើតមាននៅក្នុងសហគមន៍នេសាទឲ្យបានច្បាស់លាស់។
- ពិគ្រោះយោបល់៖ គណៈកម្មការត្រូវរៀបចំការប្រជុំជាមួយសមាជិក និងអ្នកពាក់ព័ន្ធដើម្បីបង្ហាញពីព័ត៌មានដែលប្រមូលបាន និងធ្វើផែនការរួមគ្នា។
- អនុម័តផែនការដោយមហាសន្និបាត បន្ទាប់ពីពិគ្រោះយោបល់ហើយ ដាក់បញ្ចូលនូវគំនិតយោបល់ទៅក្នុងផែនការ ហើយដាក់ជូនមហាសន្និបាតដើម្បីសម្រេច។
- សម្រេចលើផែនការដោយរដ្ឋបាលជលផលថ្នាក់កណ្តាលក្រោយមហាសន្និបាតអនុម័ត តំណាងគណៈកម្មការត្រូវចុះហត្ថលេខា និងដាក់ស្នើទៅរដ្ឋបាលជលផលថ្នាក់កណ្តាលតាមរយៈក្រុមប្រឹក្សាឃុំ/សង្កាត់ និងសមត្ថកិច្ចរដ្ឋបាលជលដើម្បីពិនិត្យ និងសម្រេច។ ក្រោយពេលសម្រេចលើផែនការហើយ រដ្ឋបាលជលផលថ្នាក់កណ្តាលត្រូវប្រថាប់ត្រាគ្រប់សន្លឹកនៃផែនការ។ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍មានសុពលភាពរយៈពេល៣ឆ្នាំ ស្មើនឹងសុពលភាពនៃកិច្ចព្រមព្រៀងដែរ។

## ៥.៤. តួនាទី ភារកិច្ច សិទ្ធិរបស់សហគមន៍នេសាទ និងសិទ្ធិរបស់សមាជិក

សហគមន៍នេសាទត្រូវបំពេញតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ចូលរួមគ្រប់គ្រង និងអភិរក្សធនធានជលផលស្របតាមលក្ខន្តិកៈ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនិងវិស័យជលផល
- គោរពតាមការណែនាំរបស់រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ចូលរួមបង្កើតកន្លែងអភិរក្សក្នុងកន្លែងនេសាទសហគមន៍ ថែរក្សា ការពារ និងដាំដុះព្រៃលិចទឹក និងព្រៃកោងកាង ស្មៅសមុទ្រ ស្តារព្រែក និងបឹងដើម្បីកែលម្អប្រព័ន្ធអេកូឡូស៊ី និងបរិស្ថានជលផលឡើងវិញ
- ធានាឲ្យសមាជិកទាំងអស់ក្នុងសហគមន៍នេសាទមានសិទ្ធិស្មើគ្នាលើការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាពដូចមានចែងក្នុងលក្ខន្តិកៈ
- អនុវត្តលក្ខន្តិកៈសហគមន៍នេសាទ និងធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយខណ្ឌរដ្ឋបាលជលផលដើម្បីគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព
- រក្សាទុកឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងសហគមន៍។

## ៥.៥. បទល្មើសជលផល និងទោសប្បញ្ញត្តិ

### ៥.៥.១. និយមន័យ

បទល្មើសជលផល ត្រូវបានកំណត់ន័យតាមមាត្រា ៧២ នៃច្បាប់ស្តីពីជលផលនៃព្រះរាជាណាចក្រកម្ពុជា ជាបទល្មើសព្រហ្មទណ្ឌដែលមានចរិតដោយឡែក។ គេអាចបកស្រាយបានថា បទល្មើសជលផល គឺជាបទល្មើសទាំងឡាយណាដែលពាក់ព័ន្ធនឹងធនធានជលផល អ្នកប្រព្រឹត្តបទល្មើសទាញយកធនធានជលផលដោយមិនបានអនុវត្តតាមច្បាប់ជលផលនិងច្បាប់ពាក់ព័ន្ធដទៃទៀត។ ឧទាហរណ៍ អ្នកប្រព្រឹត្តបទល្មើសដោយប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ធ្វើការនេសាទក្នុងដែនអភិរក្ស ធ្វើការនេសាទនៅរដូវហាមឃាត់ ដឹកជញ្ជូនផលនៃជលផលដោយគ្មានលិខិតអនុញ្ញាតជាដើម ទាំងនេះជាដើមត្រូវបានចាត់ទុកថាជាបទល្មើសជលផល។ខាងក្រោមនេះជាតារាងឧបករណ៍នេសាទតាមប្រកាសលេខ ៣១៩ ប្រកាសស្តីពីការកំណត់ប្រភេទ ឧបករណ៍នេសាទ ក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុង៣ ប្រភេទ៖ នោះគេបានបែងចែកឧបករណ៍នេសាទជា



### ៥.៥.២. បទល្មើសជលផល និងទោសប្បញ្ញត្តិ

បទល្មើសជលផលត្រូវបានចាត់ជា ៣ថ្នាក់គឺ បទល្មើសថ្នាក់ទី១ បទល្មើសថ្នាក់ទី២ និងបទល្មើសថ្នាក់ទី៣ ។

- បទល្មើសថ្នាក់ទី១ ត្រូវផ្តន្ទាទោសចាប់ពីបី (៣) ឆ្នាំទៅ ប្រាំ (៥) ឆ្នាំ និងត្រូវរឹបអូសយកវត្ថុតាងមកទុកជាសម្បត្តិរដ្ឋ ឬបំផ្លាញចោល និងដកហូតកិច្ចព្រមព្រៀង ឬលិខិតអនុញ្ញាត។
  - កាប់ឆ្ការគាស់រាន ឈូសឆាយព្រៃលិចទឹក និងព្រៃកោងកាង ឬហ៊ុមព័ទ្ធកាន់កាប់ព្រៃលិចទឹក ឬព្រៃកោង កាង
  - បង្កឲ្យភ្លើងឆេះ ឬដុតព្រៃលិចទឹក និងព្រៃកោងកាង
  - ចាក់ចោល បោះចោល បង្ហូរ បាចពង្រាយសារជាតុពុល ឬប្រព្រឹត្តសកម្មភាពធ្វើឲ្យពុល ឬបង្កគ្រោះថ្នាក់ ដល់វារីសត្វ និងវារីរុក្ខជាតិនៅក្នុងដែននេសាទ
  - នេសាទដោយឧបករណ៍បូម បាច ពង្រីកផ្ទៃកណាមួយនៃដែននេសាទ បង្កមហន្តរាយដល់ធនធានជល ផល
  - នេសាទដោយឧបករណ៍ទំនើប ឬឧបករណ៍នេសាទបង្កើតថ្មី ឬរបៀបនេសាទបែបថ្មី ឬឧបករណ៍នេសាទដែលគ្មានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលនាំមកនូវការបំផ្លាញមច្ឆាជាតិ ធនធានជលផល និងប្រព័ន្ធអេកូឡូស៊ីជលផល
  - នេសាទជាលក្ខណៈឧស្សាហកម្មក្នុងរដូវបិទនេសាទ
  - នេសាទជាលក្ខណៈឧស្សាហកម្មក្នុងកន្លែងអភិរក្សជលផល
  - ធ្វើទំនប់កាត់ ឬលុបទន្លេ ស្ទឹង ព្រែក អូរ បឹង ត្រពាំង ប្រឡាយ អាងទឹក និងអាងធម្មជាតិដែលអាចបង្កមហន្តរាយដល់ធនធានជលផលដោយគ្មានការសិក្សាវាយតម្លៃពី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  - បំផ្លាញស្មៅសមុទ្រ ឬផ្កាថ្ម និងធ្វើឲ្យអន្តរាយដល់ប្រព័ន្ធអេកូឡូស៊ី
  - សាងសង់ឡ សិប្បកម្ម មូលដ្ឋានកែច្នៃ និងរោងចក្រគ្រប់ប្រភេទដែលប្រើប្រាស់វត្ថុធាតុដើមជាប្រភេទឈើ ព្រៃលិចទឹក និងព្រៃកោងកាង
  - បំផ្លិចបំផ្លាញ ឬធ្វើឲ្យខូចខាតអន្លង់ជ្រៅៗដែលជាជម្រក ឬកន្លែងពងកូនរបស់វារីសត្វ។

ជនណាប្រព្រឹត្តបទ ល្មើសជលផលចំណុចទី៤ ដល់ចំណុចទី ៨ នៅពេលយប់ ត្រូវផ្តន្ទាទោសទ្វេដងនៃបទល្មើសជលផលថ្នាក់ ទី១នៃមាត្រា ៩៨ នេះ។ ជនណាប្រព្រឹត្តល្មើសច្បាប់ជលផលចំណុចទី១នេះចាប់ពីពីរដងឡើងទៅ ត្រូវផ្តន្ទាទោសទ្វេដងនៃបទល្មើសជលផលថ្នាក់ទី១នេះ។

- បទល្មើសថ្នាក់ទី២ ត្រូវផ្តន្ទាទោសពីមួយ (១) ទៅបី (៣) ឆ្នាំ និងពិន័យជាប្រាក់ពីប្រាំ (៥) លានរៀលទៅហាសិប (៥០) លានរៀល និងត្រូវរឹបអូសវត្ថុតាងមកទុកជាសម្បត្តិរដ្ឋ ឬបំផ្លាញចោល ៖
  - បំផ្លាញ លាក់បាំង លក់ ឬលួចវត្ថុតាងបទល្មើសជលផល

- ផ្លាស់ប្តូរ រំកិល ឬដឹកកប់បង្គោលព្រំប្រទល់នៃតំបន់គ្រប់គ្រងជលផល
- ធ្វើឲ្យខូចខាត ឬបំផ្លាញចោលទ្រព្យសម្បត្តិរបស់រដ្ឋនៅក្នុងដែននេសាទ
- នេសាទជាលក្ខណៈសិប្បកម្មក្នុងកន្លែងអភិរក្សជលផល
- នេសាទដោយអួនអូសទឹកសាប និងឈិបយន្ត
- ជីកប្រឡាយ រណ្តៅ ឬស្រះទ្រង់ទ្រាយធំ ឬសាងសង់សំណង់ថ្មីនានា ឬបូមទឹកដែលអាចបង្កមហន្តរាយ ដល់ធនធានជលផលដោយគ្មានការសិក្សាវាយតម្លៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ប្រើឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ សម្រាប់នេសាទជាលក្ខណៈសិប្បកម្ម ឬឧស្សាហកម្ម
- សកម្មភាពដទៃទៀតនៅក្នុងដែននេសាទ ដែលបង្កអន្តរាយដល់ប្រភពធនធានជលផល
- ប្រើខ្សែចងគ្រប់ប្រភេទ និងមធ្យោបាយផ្សេងទៀតដែលបង្កលក្ខណៈឲ្យត្រីផ្អើល
- នេសាទដោយប្រើទំនប់រួមផ្សំដោយឧបករណ៍នេសាទគ្រប់ប្រភេទដែលបង្កមហន្តរាយដល់ធនធានជល ផល
- នេសាទដោយប្រើលប ឬរ៉ាវក្រៅតំបន់កំណត់
- ផលិត ទិញ លក់ រក្សាទុកឧបករណ៍ឆក់ ឬឧបករណ៍ស្បៃមុងគ្រប់ប្រភេទ
- ដាំឈូកក្នុងឡូត៍នេសាទ
- ដាក់សម្រាស់ ឬមធ្យោបាយផ្សេងទៀតធ្វើឲ្យត្រី ឬវារីសត្វគុំ
- លក់ ដោះដូរ ជួល ធ្វើអំណោយ ប្រវាស់ បែងចែក ឬផ្ទេរកន្លែងនេសាទសហគមន៍។
- ជនណាប្រព្រឹត្តបទល្មើសជលផលថ្នាក់ទី២ ចំណុចទី៤ និងចំណុចទី៥ នៅពេលយប់ ត្រូវផ្តន្ទាទោសក្រោមបទ ល្មើសជលផលថ្នាក់ទី១នៃច្បាប់នេះ។

ជនណាប្រព្រឹត្តបទល្មើសជលផលថ្នាក់ទី២នៃមាត្រា ៩៩ និង ១០០ នេះចាប់ពីពីរដងឡើងទៅត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី១នៃច្បាប់នេះ។

- បទល្មើសថ្នាក់ទី៣ ផ្តន្ទាទោសដាក់ពន្ធនាគារចាប់ពី ១ខែ ទៅ ១ឆ្នាំ និងពិន័យជាប្រាក់ពី ១លាន ទៅ ៥លានរៀល វត្ថុតាងទាំងអស់អាចត្រូវរឹបអូសដាក់ជាសម្បត្តិរដ្ឋ ឬបំផ្លាញចោលៈ
    - កាប់បំផ្លាញដើមឈើព្រៃលិចទឹក និងព្រៃកោងកាង ឬគាស់រំលើងប្រមូលគល់ឈើព្រៃលិចទឹក និងព្រៃកោងកាង
    - ពង្រីកផ្ទៃដីកសិកម្ម ឬប្រើប្រាស់ដីក្នុងបំណងផ្សេងៗក្រៅពីកិច្ចអភិវឌ្ឍវិស័យជលផលនៅក្នុងតំបន់លិចទឹក ដែលត្រូវការពារ
    - ពង្រីកផ្ទៃដីស្រែចម្ការ ឬស្រែអំបិលក្នុងដែននេសាទដោយគ្មានការអនុញ្ញាត
    - ស្ថាបនាផ្លូវសាធារណៈ ដាក់តាំងមូលដ្ឋានសំណង់ ឬលំនៅឋានគ្រប់ប្រភេទនៅក្នុងដែននេសាទ
    - ដាំឈូកជាលក្ខណៈអាជីវកម្ម ឬពាណិជ្ជកម្មក្នុងតំបន់គ្រប់គ្រងជលផល
    - ដឹកជញ្ជូនសម្រាស់

- ផលិត ទិញ លក់ ដឹកជញ្ជូន រក្សាទុកឧបករណ៍នេសាទឈិបយន្ត ឬអួនអូសទឹកសាប
- នេសាទជាលក្ខណៈសិប្បកម្មក្នុងរដូវបិទនេសាទ
- នេសាទជាលក្ខណៈគ្រួសារក្នុងកន្លែងអភិរក្សជលផល
- នេសាទដោយប្រើច្បូក មងកាំង ឬមងពស់ថ្លានគ្រប់ប្រភេទ
- នេសាទដោយប្រើមង ឬអួនគ្រប់ប្រភេទដែលមានក្រឡាតូចជាងមួយសង់ទីម៉ែត្រកន្លះ
- នេសាទដោយប្រើមង ឬអួនគ្រប់ប្រភេទ ដែលមានក្រឡាតូចជាងមួយសង់ទីម៉ែត្រកន្លះ
- នេសាទដោយប្រើព្រួលគ្រប់ប្រភេទ ដែលមានចន្លោះពីត្រៀមមួយទៅត្រៀមមួយតូចជាង១សង់ទីម៉ែត្រ កន្លះ
- ទិញ លក់ កែច្នៃ ធ្វើសន្និសីទ និងដឹកជញ្ជូនផល ផលិតផលជលផល ដែលបានមកពីការធ្វើនេសាទខុស ច្បាប់ ឬដោយប្រើឧបករណ៍នេសាទខុសច្បាប់។

ជនណាប្រព្រឹត្តបទល្មើសថ្នាក់ទី៣ ចំណុចទី៨ ដល់ចំណុចទី១៣ នៅពេលយប់ ត្រូវផ្តន្ទានទោសក្រោមបទល្មើស ជលផលថ្នាក់ទី២នៃមាត្រា ៩៩ នៃច្បាប់នេះ។ ជនណាប្រព្រឹត្តបទល្មើសថ្នាក់ទី៣ ចាប់ពីពីរ ដង (២) ឡើងទៅ ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី២ នៃមាត្រា៩៩ នៃច្បាប់នេះ។

## ៥.៥.៣. ដំណោះស្រាយវិវាទ

ជាការពិតណាស់វិវាទតែងតែកើតមានជាប្រចាំនៅគ្រប់កន្លែង ហើយមានសណ្ឋានខុសៗគ្នា។ វិវាទខ្លះធំ វិវាទខ្លះតូច វិវាទខ្លះចាប់ផ្តើមពីតូចទៅធំ វិវាទខ្លះចាប់ផ្តើមពីធំមកតូច។ ការគ្រប់គ្រងវិវាទបានគឺជាការធានានូវ និរន្តភាពនៃភាពសុខដុមរមនានៅក្នុងសហគមន៍នេសាទរបស់អ្នក ហើយវាក៏បង្ហាញពីភាពរឹងមាំ និងការយល់ដឹងពីការគ្រប់គ្រងនិងដោះស្រាយវិវាទស្របតាមប្រភេទ និងទំហំនៃវិវាទផងដែរ។

### ក. នៅក្នុងផែនការគ្រប់គ្រងសហគមន៍គេត្រូវគិតគូរទុកជាមុនអំពីការដោះស្រាយវិវាទ ៖

- វិវាទក្នុងសហគមន៍នេសាទ
- វិវាទរវាងសមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋ
- វិវាទរវាងសហគមន៍នេសាទជាមួយអ្នកមកពីខាងក្រៅ។

### ខ. យន្តការដោះស្រាយវិវាទគួររួមបញ្ចូលនូវ ៖

- ការដោះស្រាយវិវាទដំបូងៗ (ពេលដែលភាគីទាំងអស់ត្រៀមនឹងដោះស្រាយ)
- វិវាទធំៗ (ពេលដែលភាគីទាំងអស់មិនឯកភាពគ្នា)។

### គ. ក្នុងករណីវិវាទនីមួយៗគេគួរកំណត់នូវ ៖

- អ្នកណាជាអ្នកដោះស្រាយ?
- អ្នកណាជាអ្នកសម្រេចអាជ្ញាកាត់ក្នុងករណីមិនឯកភាពគ្នា?

  យោងតាមប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ (ជំពូកទី ១១ ប្រការ ៣៣) គូសបញ្ជាក់ថា វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទត្រូវដោះស្រាយដូចតទៅ ៖

- គណៈកម្មការសហគមន៍នេសាទត្រូវសម្របសម្រួល និងដោះស្រាយរាល់វិវាទដែលកើតឡើងនៅក្នុងសហគមន៍នេសាទរបស់ខ្លួន
- ក្នុងករណីដែលគណៈកម្មការសហគមន៍នេសាទដោះស្រាយវិវាទពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះទៅរដ្ឋបាលជលផលដើម្បីដោះស្រាយ ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងមន្ត្រីពាក់ព័ន្ធតាមការចាំបាច់
- ក្នុងករណីដែលវិវាទនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និងរដ្ឋបាលជលត្រូវតែបញ្ជូនសំណុំរឿងទៅតុលាការខេត្ត/ក្រុងសាមី ដើម្បីដោះស្រាយតាមច្បាប់។

ការដាក់យន្តការដោះស្រាយវិវាទទៅក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងជួយកសាងទំនុកចិត្ត និងជៀសវាងវិវាទដែលនឹងត្រូវចំណាយពេលវេលា និងថវិកាក្នុងដំណើរការអនុវត្តផែនការ។ សហគមន៍នេសាទដែលរួមបញ្ចូលយន្តការគ្រប់គ្រងវិវាទ រមែងទទួលបានជោគជ័យច្រើនក្នុងការសម្រេចគោលបំណងនៃការគ្រប់គ្រង គោលដៅបរិស្ថាន និងសង្គមច្រើនជាងសហគមន៍នេសាទដែលមិនមានយន្តការគ្រប់គ្រងវិវាទ។

# ៦. ក្រមបរិស្ថាន និងធនធានធម្មជាតិ

## ៦.១. ការប្រកាសឱ្យប្រើ

ក្រមបរិស្ថាន និងធនធានធម្មជាតិ ត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ដោយព្រះរាជក្រមរបស់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី (នស/រកម/០៦២៣/ ០០៧) ដែលមានសេចក្តីដូចខាងក្រោម ៖

ក្រមបរិស្ថាន និងធនធានធម្មជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៤ ហើយដែលមានសេក្តីទាំងស្រុងដូចតទៅ៖ (ខ្លឹមសារទាំងអស់ដូចមានចែងនៅក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ)។

## ៦.២. គោលបំណង ការអនុវត្ត និងនិរាករណ៍

### ➢ គោលបំណង

យោងតាម**មាត្រា១** នៃក្រមបរិស្ថាន និងធនធានធម្មជាតិ ៖ ក្រមនេះកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរពនិងប្រតិបត្តិតាមក្នុងការពង្រឹងធ្វើទំនើបកម្ម ធ្វើឱ្យមានសង្គតិភាព និងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងលើកិច្ចគាំពារបរិស្ថាន ការអភិរក្ស និងស្តារឡើងវិញនូវធនធានធម្មជាតិ ជីវៈចម្រុះ មុខងារប្រព័ន្ធអេកូឡូស៊ី ដើម្បីការរស់នៅនិងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ➢ ការអនុវត្ត

យោងតាម**មាត្រា៨៦៥** នៃក្រមបរិស្ថាន និងធនធានធម្មជាតិ ៖ ក្រមនេះត្រូវយកទៅអនុវត្តក្នុងរយៈពេល ១ (មួយ)ឆ្នាំ ក្រោយការចូលជាធរមាននៃក្រមនេះ។ ក្រសួងបរិស្ថានបានរៀបចំពិធីប្រកាសដាក់ក្រមនេះប្រើប្រាស់ជាផ្លូវការកាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤។[12]

### ➢ និរាករណ៍

យោងតាម **មាត្រា៨៦៤** នៃក្រមបរិស្ថាន និងធនធានធម្មជាតិ ៖

**១-** ត្រូវបាត់បង់អានុភាពចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត ចំពោះច្បាប់និងបទប្បញ្ញត្តិពីមុនពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ដែលបានកំណត់ដូចខាងក្រោម៖

**ក-**ច្បាប់ស្តីពីកិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.១២៩៦.៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦។

---

[12] ហ្វេសប៊ុកផេករបស់ក្រសួងបរិស្ថានថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ ក្រសួងបរិស្ថានដាក់ឱ្យប្រើប្រាស់ក្ - ...Ministry of Environment | Facebook

**ខ**-ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៨/ ០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨។

**គ**-ច្បាប់ស្តីពីជីវសុវត្ថិភាព ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៨/០០៦ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨។

**២**- បទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតដែលមានអានុភាពនៅពេលក្រមនេះ ត្រូវបានអនុវត្តហើយផ្ទុយនឹងបទប្បញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកថាគ្មានអនុភាពត្រឹមទំហំដែលផ្ទុយនឹងក្រមនេះត្រូវបានអនុវត្ត។

**៣**-ប៉ុន្តែបទប្បញ្ញត្តិដែលកំណត់អំពីបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ក្នុងកថាខណ្ឌទី១ និងទី២ ខាងលើនេះ ត្រូវបន្តមានអានុភាពអនុវត្តក្រោយការអនុវត្តនៃក្រមនេះ ចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តមុនពេលក្រមនេះត្រូវបានអនុវត្ត។

**៤**-រាល់បទប្បញ្ញត្តិនៃក្រមនេះត្រូវយកមកអនុវត្ត  កាលណាពុំមានវិធានដោយឡែកចែងដោយច្បាប់ពិសេស។

## ៦.៣. តំបន់ការពារធនធានធម្មជាតិ

យោងតាមឧសម្ព័ន្ធនៃក្រមបរិស្ថាន និងធនធានធម្មជាតិ សទ្ទានុក្រម (ត ថ ទ) តំបន់ការពារធម្មជាតិ សំដៅដល់តំបន់នៃដែនដីសម្បត្តិសាធារណៈរបស់រដ្ឋ រួមមាន ដែនដីគោក ឬដែនទឹក រួមទាំងឆ្នេរសមុទ្រ និងសមុទ្រស្ថិតនៅក្នុងតំបន់ដែលទទួលស្គាល់ដោយបទប្បញ្ញត្តិនៃច្បាប់ ឬតំបន់ដែលបង្កើតថ្មី ក្នុងដែនសមត្ថកិច្ចរបស់ក្រសួងស្ថាប័នទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ។ តំបន់ទាំងនោះមានសារៈសំខាន់ទាំងផ្នែករូបសាស្ត្រ និងផ្នែកជីវសាស្ត្រដែលតម្រូវឱ្យមានការគ្រប់គ្រងតាមច្បាប់ក្នុងបំណងការពារ និងថែទាំជីវៈចម្រុះ ធនធានធម្មជាតិ និងធនធានវប្បធម៌ ហើយត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាពគ្រប់ជំនាន់ ដើម្បីផលប្រយោជន៍បរិស្ថាន សង្គម និងសេដ្ឋកិច្ច។

## ៦.៤. ប្រភេទនៃតំបន់ការពារធម្មជាតិ

នៅក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ **មាត្រា៣៥៩** បានកំណត់នូវតំបន់ការពារធម្មជាតិដូចខាងក្រោម៖

ក- ឧទ្យានជាតិ។

ខ- ឧទ្យានជាតិសមុទ្រ។

គ- ដែនជម្រកសត្វព្រៃ។





ឃ- តំបន់ការពារទេសភាព។

ង- តំបន់ប្រើប្រាស់ច្រើនយ៉ាង។

ច- តំបន់រ៉ាមសារ។ [13]

ឆ- តំបន់ស្នូលនៃបបនីយជីវមណ្ឌល។

ជ- តំបន់បេតិកភណ្ឌធម្មជាតិ។

---

[13] តំបន់រ៉ាមសារ គឺតំបន់ដីសើមដែលគេចាត់ទុកថាជាតំបន់ដែលមានសារៈសំខាន់ខាងផ្នែកប្រព័ន្ធអេកូឡូស៊ី ឬជីវៈចម្រុះជាលក្ខណៈអន្តរជាតិ។

ឈ- ប្រភេទតំបន់ការពារធម្មជាតិផ្សេងទៀត។

## ៦.៥. ការកំណត់ និងការចាត់ចែងតំបន់គ្រប់គ្រង

ក្រមបរិស្ថាន និងធនធម្មជាតិ **មាត្រា៣៦៤ ៖** ការបែងចែកតំបន់គ្រប់គ្រងបានកំណត់ដូចខាងក្រោម ៖

**ក. តំបន់ស្នូល ៖** គឺជាតំបន់គ្រប់គ្រង ដែលមានតម្លៃខ្ពស់សម្រាប់ការអភិរក្សប្រភេទសត្វ រុក្ខជាតិដែលកម្រជិតផុតពូជ ទទួលរងគ្រោះថ្នាក់ គំរាមកំហែង ទីតាំងសត្វព្រៃបន្តពូជ និងប្រព័ន្ធអេកូឡូស៊ីផុយស្រួយ។ការចេញចូលតំបន់នេះត្រូវហាមឃាត់ លើកលែងតែមន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិដែលមានភារកិច្ច និងអ្នកសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រធម្មជាតិក្នុងគោលបំណងការពារ និងអភិរក្ស ធនធានធម្មជាតិ ជីវៈចម្រុះ និងបរិស្ថានដែលត្រូវមានការអនុញ្ញាតជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ និងលើកលែងតែមានការចាំបាច់ក្នុងវិស័យសន្តិសុខ និងការពារជាតិ។



**ខ. តំបន់អភិរក្ស ៖** គឺជាតំបន់គ្រប់គ្រងស្ថិតនៅជាប់នឹងតំបន់ស្នូល ដែលមានតម្លៃខាងអភិរក្ស ធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី តំបន់ទីជម្រាល និងតំបន់ដែលមានលក្ខណៈទេសភាពធម្មជាតិ។ ការចេញចូលតំបន់នេះត្រូវមានការអនុញ្ញាតជាមុនពីមន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលទទួលខុសត្រូវនៅនឹងកន្លែង លើកលែងតែមានការចាំបាច់ក្នុងវិស័យសន្តិសុខ និងការពារជាតិ។ ការប្រើប្រាស់អនុផលធនធានធម្មជាតិក្នុងតំបន់នេះសម្រាប់ជីវភាពសហគមន៍មូលដ្ឋាន ដែលមិនប៉ះពាល់ខ្លាំងដល់ជីវចម្រុះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ។

**គ. តំបន់ប្រើប្រាស់ដោយចីរភាព ៖** គឺជាតំបន់គ្រប់គ្រងដែលមានតម្លៃសេដ្ឋកិច្ចបម្រើដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការគ្រប់គ្រង ការអភិវឌ្ឍតំបន់ការពារធម្មជាតិផ្ទាល់ និងចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។ រាជរដ្ឋាភិបាលអាចអនុញ្ញាតឱ្យមានការអភិវឌ្ឍដោយជានា និរន្តរភាព ជីវៈចម្រុះក្នុងតំបន់នេះតាមការស្នើសុំរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋាន ដោយអនុលោមតាមនីតិវិធីច្បាប់។



**ឃ. តំបន់សហគមន៍ ៖** គឺជាតំបន់គ្រប់គ្រងបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍មូលដ្ឋានដែលមានសកម្មភាពស្រាប់ មានជាអាទិ៍ លំនៅឋាន ស្រែ ចម្ការ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។ការផ្ដល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចនវត្ថុ ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីនៅក្នុងតំបន់នេះត្រូវមានការបញ្ជាក់យល់ព្រម

ជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ៦.៦. សិទ្ធិចូលរួមចូលរួមផ្តល់មតិរបស់បុគ្គលដែលរងផលប៉ះពាល់



ក្រមបរិស្ថាន និងធនធានធម្មជាតិ **មាត្រា១១ ៖** បុគ្គលដែលអាចទទួលរងផលប៉ះពាល់ដោយផ្ទាល់ ឬប្រយោលដោយសារការធ្វើសេចក្តីសម្រេចណាមួយទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិចូលរួមផ្តល់មតិយោបល់ឱ្យទាន់ពេលវេលា បន្ទាប់ពីទទួលបបានព័ត៌មានតាមរយៈដំណើរការចូលរួមពីភាគីពាក់ព័ន្ធដោយមានតម្លាភាព និងគណនេយ្យភាពមុនពេលដែលសេចក្តីសម្រេចនោះត្រូវបានធ្វើឡើង។

## ៦.៧. សិទ្ធិទទួលបានព័ត៌មានអំពីបរិស្ថាន និងធនធានធម្មជាតិ

ក្រមបរិស្ថាន និងធនធានធម្មជាតិ **មាត្រា១២ ៖**

១-បុគ្គលមានសិទ្ធិទទួលបានព័ត៌មានទាក់ទង និងបរិស្ថាននិងធនធានធម្មជាតិ។

២-រាល់ព័ត៌មានស្តីពីកិច្ចគាំពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជនដើម្បីបង្កើតឱកាសឱ្យបានច្រើនសម្រាប់ការចូលរួមជាសាធារណៈនៅក្នុងការធ្វើផែនការ និងការធ្វើសេចក្តីសម្រេចដែលបង្កផលប៉ះពាល់ដល់សង្គមនិ ងបរិស្ថាន។

៣-សិទ្ធិទទួលបានព័ត៌មានទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ។

## ៦.៨. សហគមន៍តំបន់ការពារធម្មជាតិ និងសិទ្ធិ

### ក. ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ



ក្រមបរិស្ថាន និងធនធានធម្មជាតិ **មាត្រា៣៧១** ស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិបានចែងថា ៖

១-ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ មានសមត្ថកិច្ចរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិក្នុងតំបន់ប្រើប្រាស់ដោយចីរភាពដោយស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

២-រដ្ឋបាលថ្នាក់ក្រោមជាតិ អាចផ្តួចផ្តើមសម្របសម្រួលគាំទ្រផ្តល់គោលការណ៍អនុញ្ញាត និងទទួលស្គាល់ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ បន្ទាប់ពីទទួលបានការយល់ព្រមពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ។

៣-រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសិក្សាពីលទ្ធភាពរៀបចំសហគមន៍តំបន់ការពារធម្មជាតិ កំណត់ទីតាំងច្បាស់លាស់ និងទំហំឱ្យបានសមស្រប ដោយមានការពិគ្រោះយោបល់ និងការសម្របសម្រួលជាមួយសហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធ។

៤-សហគមន៍តំបន់ការពារធម្មជាតិត្រូវចុះកិច្ចព្រមព្រៀងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយ និងកិច្ចព្រមព្រៀងនេះមានសុពលភាពមិនលើសពីរយៈពេល២៥(ម្ភៃប្រាំ)ឆ្នាំ។

៥-ក្នុងករណីដែលសហគមន៍តំបន់ការពារធម្មជាតិមិនអនុវត្តតាមកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ មានសិទ្ធិផ្អាកដំណើរការរបស់សហគមន៍តំបន់ការពារធម្មជាតិ ដើម្បីពិនិត្យ និងវាយតម្លៃឡើងវិញ។

៦-រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិលុបកិច្ចព្រមព្រៀងសហគមន៍តំបន់ការពារធម្មជាតិ បន្ទាប់ពីទទួល បានការយល់ព្រមពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្នុងករណីដែលសហគមន៍អនុវត្តផ្ទុយពីកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិ។

៧-ក្នុងករណីដែលពិនិត្យឃើញថា សហគមន៍តំបន់ការពារធម្មជាតិមិនបានអនុវត្តឱ្យបានត្រឹមត្រូវតាមកិច្ចព្រមព្រៀង ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិមានសិទ្ធិតម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិលុបកិច្ចព្រមព្រៀង។

៨-វិធានសម្រាប់ការបង្កើតនិងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

៩-គោលការណ៍ណែនាំស្តីពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ។

## ខ. ការចូលរួមរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ដោយលើកទឹកចិត្តទាំងសប្បុរសជន វិស័យឯកជន និងសង្គមស៊ីវិល

យោងតាមក្រមបរិស្ថាន និងធនធានធម្មជាតិ **មាត្រា៣៧៣** ស្តីពីការចូលរួមរៀបចំសហគមន៍តំបន់ការពារធម្មជាតិ បានចែងថា ៖ ***សប្បុរសជន វិស័យឯកជន និងសង្គមស៊ីវិល*** ត្រូវបានលើកទឹកចិត្តឱ្យចូលរួមគាំទ្រ និងសម្របសម្រួលក្នុងការរៀបចំ និងកិច្ចដំណើរការរបស់សហគមន៍តំបន់ការពារធម្មជាតិ។

## គ. ការចូលរួម និងសិទ្ធិរបស់សហគមន៍មូលដ្ឋាន សាធារណជន និង សង្គមស៊ីវិល

ក្រមបរិស្ថាន និងធនធានធម្មជាតិ **មាត្រា៣៦៨** ស្តីពីការចូលរួម បានចែងថា ៖ ***សហគមន៍មូលដ្ឋានសាធារណជន*** និង***សង្គមស៊ីវិល*** ត្រូវបានលើកទឹកចិត្តឱ្យមានការចូលរួមផ្តល់ និងទទួលយកព័ត៌មានទាក់ទងនឹងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍក្នុងតំបន់ការពារធម្មជាតិ។

ក្រមបរិស្ថាន និងធនធានធម្មជាតិ **មាត្រា៣៦៩** ស្តីពីសិទ្ធិប្រើប្រាស់ធនធានធម្មជាតិបានចែងថា ៖

១-រដ្ឋទទួលស្គាល់ និងធានាសិទ្ធប្រើប្រាស់ធនធានធម្មជាតិលក្ខណៈប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនារបស់សហគមន៍មូលដ្ឋានដែលរស់នៅក្នុងតំបន់ការពារធម្មជាតិ។

២-សិទ្ធប្រើប្រាស់ធនធានធម្មជាតិជាលក្ខណៈប្រពៃណី ទំនៀមទម្លាប់ តាមតម្រូវការរបស់សហគមន៍មូលដ្ឋានជាលក្ខណៈគ្រួសារ អាចប្រព្រឹត្តទៅបានក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់អភិរក្សដោយអនុវត្តទៅ

តាមគោលការណ៍ណែនាំ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ។

ក្រមបរិស្ថាន និងធនធានធម្មជាតិ **មាត្រា៣៧៥. ការចូលរួមការពារ អភិរក្ស និងស្តារធនធានធម្មជាតិ**

*ប្រជាពលរដ្ឋ ព្រះសង្ឃ សិស្សានុសិស្ស មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត និងបុគ្គលផ្សេងទៀត ជាអាទិ៍ មានករណីយកិច្ចចូលរួមការពារ អភិរក្ស និងស្តារធនធានធម្មជាតិឡើងវិញក្នុងតំបន់ការពារធម្មជាតិ។*

**សហគមន៍មូលដ្ឋាន ៖** យោងតាមឧសម្ព័ន្ធនៃក្រមបរិស្ថាន និងធនធានធម្មជាតិ សន្ទានុក្រម (ល វ ស) សំដៅដល់សហគមន៍ដែលជាជនជាតិដើមភាគតិច ឬមិនមែនជាជនជាតិដើមភាគតិច ដែលរស់នៅទីតាំងណាមួយជាក់លាក់ ហើយបានបង្កើត ឬចងក្រង ឬមិនបានចងក្រងជាសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ ឬសហគមន៍ផ្សេងទៀតដែលកំណត់ដោយច្បាប់។

## ឃ. ការប្រើប្រាស់ធនធានធម្មជាតិ

ក្រមបរិស្ថាន និងធនធានធម្មជាតិ **មាត្រា៣៧០** ស្តីពីការប្រើប្រាស់ធនធានធម្មជាតិបានចែងថា ៖

១-ការប្រើប្រាស់ធនធានធម្មជាតិស្របតាមបទប្បញ្ញត្តិនៃក្រមនេះ អាចប្រព្រឹត្តទៅបានតែក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍។ លក្ខខណ្ឌនេះមិនរារាំងចំពោះការប្រើប្រាស់អនុផលធនធានធម្មជាតិក្នុងតំបន់អភិរក្ស ដែលត្រូវបានអនុញ្ញាតតាម**មាត្រា៣៦៩**នៃក្រមនេះ។( សិទ្ធិប្រើប្រាស់ធនធានធម្មជាតិ )

២-ការប្រើប្រាស់ធនធានធម្មជាតិត្រូវអនុវត្តតាមផែនការគ្រប់គ្រង និងគោលការណ៍ណែនាំបច្ចេកទេសរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ ដើម្បីធានានិរន្តរភាពនៃធនធានធម្មជាតិក្នុងសហគមន៍តំបន់ការពារធម្មជាតិ។

## ង. សកម្មភាពហាមឃាត់សម្រាប់សហគមន៍តំបន់ការពារធម្មជាតិ

ក្រមបរិស្ថាន និងធនធានធម្មជាតិ **មាត្រា៣៧២** បានចែងថា ៖

១-សហគមន៍តំបន់ការពារធម្មជាតិ និងឬសមាជិកនៃសហគមន៍តំបន់ការពារធម្មជាតិ ពុំមានសិទ្ធិ/ កាប់គាស់ ឬឈូសឆាយដីព្រៃក្នុងសហគមន៍តំបន់ការពារធម្មជាតិ និងបង្វែរធ្វើជាដីកសិកម្ម ឬធ្វើជាកម្មសិទ្ធិបុគ្គល ឬលក់ ប្តូរ ជួល បញ្ចាំ ធ្វើអំណោយ ប្រវាស់ បែងចែក ដោះដូរ ឬធ្វើការផ្ទេរតំបន់គ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិឱ្យទៅបុគ្គលណាមួយបានឡើយ។

២-ការផ្តល់ដីសម្រាប់បង្កបង្កើនផលបន្ថែមជូនដល់សហគមន៍មូលដ្ឋាន ត្រូវបានកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ឬតាមសំណើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ។



## ៦.៩. ការហាមឃាត់សកម្មភាពបង្កផលប៉ះពាល់ដល់ធនធានធម្មជាតិ

ក្រមបរិស្ថាន និងធនធានធម្មជាតិ **មាត្រា៣៨៤** បានចែងថា ៖

តំបន់ការពារធម្មជាតិនីមួយៗ ត្រូវការពារទប់ស្កាត់ និងហាមឃាត់នៅរាល់សកម្មភាព កាប់គាស់ រុករានទន្ទ្រានដីព្រៃដោយរំលោភធ្វើអាជីវកម្ម បំពុលមជ្ឈដ្ឋានធនធានជីវៈចម្រុះ ភ្លើងឆេះព្រៃ ភ្លើងឆេះតំបន់ដីមមោក ***<u>ធ្វើកសិកម្មពនេចរ</u>*** នាំចូលជំងឺ សត្វល្អិតចង្រៃ និងប្រភេទរុក្ខជាតិ ឬសត្វរាតត្បាត ដែលធ្វើឱ្យខូចខាត ឬប៉ះពាល់ក្នុងតំបន់ការពារធម្មជាតិ និងសកម្មភាពហាមឃាត់មួយចំនួនទៀតដូចខាងក្រោម ៖

**ក**-ការរំកិល ដកចេញ បំផ្លាញគោលសីមា ឬសញ្ញាសម្គាល់ព្រំប្រទល់តំបន់ការពារធម្មជាតិ។

**ខ**-ការប្រើសិទ្ធិប្រើប្រាស់ធនធានធម្មជាតិខុសពីសិទ្ធិដែលបានទទួលស្គាល់ឬបានអនុញ្ញាតដោយច្បាប់។

**គ**-ការកាប់ ផ្តួល រំលំ គៀរ កាប់បំផ្លាញដើមឈើ បំពុល ឬគាស់រម្លើងគល់ឈើ។

**ឃ**-ការប្រមាញ់ ប្រមូលពង កូនសត្វព្រៃ និងសត្វស្លាបតាមគ្រប់រូបភាព។

**ង**-ការបំពុលទឹកគ្រប់រូបភាព ការដាក់ថ្នាំបំពុល ការប្រើសារធាតុគីមី ការចោលសំណល់រឹងរាវចូល ក្នុង ទឹក ឬលើដី ការប្រើប្រាស់ឧបករណ៍ឆក់។

**ច**-ការជួញដូរ ការដឹកជញ្ជូន ការស្តុក ការទិញ ការតាំងលក់សត្វព្រៃ សំណាកសត្វព្រៃគ្រប់ប្រភេទ ឬចិញ្ចឹមសត្វព្រៃសម្រាប់ការធ្វើពាណិជ្ជកម្ម និងរុក្ខជាតិព្រៃដោយគ្មានការអនុញ្ញាត។

**ឆ**-ការបំផ្លាញវាលស្មៅធម្មជាតិ រុក្ខជាតិនានា និងទីជម្រកសត្វព្រៃ។

**ជ**-ការលែងសត្វពាហនៈ និងបណ្តើរឆ្កែប្រមាញ់។

**ឈ**-ការនេសាទដែលផ្ទុយនឹងបញ្ញត្តិនៃក្រមនេះ ដែលធ្វើឱ្យខូចខាតដល់ធនធានធម្មជាតិទាំងក្នុងដែនសមុទ្រ និងដែនទឹកសាប ព្រៃលិចទឹក ព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ។

**ញ**-ការបង្កើតមូលដ្ឋាន និងកែច្នៃខ្លឹមចន្ទន៍ក្រស្នា ដើមម្រះព្រៅភ្នំ វល្លិមៀត ឬអនុផលធនធានធម្មជាតិ ហាមឃាត់ផ្សេងទៀត និងការធ្វើវារីវប្បកម្មទឹកសាប ទឹកប្រៃ ដែលផ្ទុយនឹងបញ្ញត្តិនៃក្រមនេះ និង បច្ចេកទេសដែលនាំដល់ការបំពុល ឬបំផ្លាញមជ្ឈដ្ឋានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី។

**ដ**-ការប្រើប្រាស់ឧបករណ៍នានាដែលបង្កការរំខានដោយសំឡេង រំញ័រ រលក និងផ្សេងដែលអាចបង្ក ការខូចខាតដល់ធនធានធម្មជាតិ និងកិច្ចគាំពារបរិស្ថានក្នុងតំបន់ស្នូល និងតំបន់អភិរក្ស។

**ឋ**-ការកម្ទេច ផ្លាស់ប្តូរ លុបបំបាត់ ឬធ្វើឱ្យខូចខាតស្លាកសញ្ញាគ្រប់ប្រភេទ។

**ឌ**-ការយកថ្ម គ្រួស ខ្សាច់ រ៉ែ ការគាស់ ឈូសឆាយ កកាយយកដី ដោយគ្មានការអនុញ្ញាត។

**ឍ**-ការចាក់លុបឬចាក់បំពេញដី ដែនទឹក ផ្លែវងទឹកភ្លៀង ផ្លូវទឹក បឹងធម្មជាតិ ដីសើម តំបន់ទំនាប ទឹកផុសក្រោមដី ឬអាងទឹក ដោយគ្មានការអនុញ្ញាត។

**ណ**-ការនាំចូលនូវណារយន្ត និងគ្រឿងចក្រផ្សេងៗដោយគ្មានការអនុញ្ញាត។

**ត**-ការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

**ថ**-ការធ្វើឱ្យរាំងស្ទះដល់លំហូរបរិស្ថាននៃបឹងបួ ទន្លេ ស្ទឹង អូរ ព្រែក ដោយ គ្មានការអនុញ្ញាត។

**ទ**-ការបោះបង្គោលហ៊ុមព័ទ្ធ ដាក់សញ្ញាសម្គាល់លើដីដែលជាទ្រព្យសម្បត្តិរដ្ឋក្នុងតំបន់ការពារធម្មជាតិ ក្នុងគោលបំណងកាន់កាប់ ដើម្បីធ្វើលទ្ធកម្មលើកម្មសិទ្ធិ។

ក្រមបរិស្ថាន និងធនធានធម្មជាតិ **មាត្រា៣៨៤ ស្តីអំពីការហាមឃាត់សិទ្ធិរបស់បុគ្គល** បានចែងថា ៖ បុគ្គលពុំមានសិទ្ធិផ្តល់ការអនុញ្ញាតទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី ឱ្យរានដីព្រៃ កាន់កាប់ដី កាប់ដើមឈើ ចាប់សត្វព្រៃគ្រប់ប្រភេទ ឬធ្វើសកម្មភាពគ្រប់យ៉ាង ដើម្បីប្រមូលផល អនុផលធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិដែលផ្ទុយនឹងបទប្បញ្ញត្តិនៃក្រមនេះ។

## ៦.១០. ការអប់រំ ការផ្សព្វផ្សាយ ការស្តារ និងការកែលម្អតំបន់ការពារធម្មជាតិ

មាត្រាមួយចំនួននៃក្រមបរិស្ថាន និងធនធានធម្មជាតិបានចែងអំពីការអប់រំ ការផ្សព្វផ្សាយ ការស្តារនិងការកែលម្អតំបន់ការពារធម្មជាតិ ដូចខាងក្រោម ៖

**មាត្រា៣៧៦. កម្មវិធីអប់រំផ្សព្វផ្សាយ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយតាមគ្រប់រូបភាពឱ្យបានទូលំទូលាយស្តីពីកិច្ចគាំពារ និងការអភិរក្សធនធានធម្មជាតិ ការស្តារ ការកែលម្អធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីដែលបានរេចរឹល និងបាត់បង់។

២- រៀងរាល់ឆ្នាំក្នុងទិវាបរិស្ថានជាតិ បរិស្ថានពិភពលោក និងទិវាអនុសញ្ញាអន្តរជាតិ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំសកម្មភាពស្តារធនធានជីវៈចម្រុះ និង ប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ការពារធម្មជាតិ ក្នុងគោលបំណងអប់រំ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានយល់ដឹងពីតម្លៃនៃតំបន់ការពារធម្មជាតិ និងលើកកម្ពស់ការចូលរួមក្នុងកិច្ចគាំពារនិងការអភិរក្សធនធានធម្មជាតិ។

៣ -*ទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោកត្រូវរៀបចំឡើងនៅថ្ងៃទី៥ ខែមិថុនា ជារៀងរាល់ឆ្នាំ* ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឬព្រះរាជតំណាងដោយមានការចូលរួមពីស្ថាប័នព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ស្ថានទូត មន្ត្រីរាជការថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ព្រះសង្ឃ ដៃគូអភិវឌ្ឍ និងសាធារណជន។ ព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ បង្ហាញនូវព្រះរាជហឫទ័យយកចិត្តទុក ដាក់លើកិច្ចគាំពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាពមានជាអាទិ៍ ការដាំដើមឈើ ការព្រលែងមច្ឆជាតិ និងសត្វព្រៃ និងព្រះរាជសកម្មភាពផ្សេងៗទៀតដែលផ្តល់ពហុឧត្តមប្រយោជន៍សម្រាប់មនុស្សជាតិនិងភពផែនដី។

**មាត្រា៣៧៧.** ការកែលម្អបរិស្ថានក្នុងតំបន់ការពារធម្មជាតិ

*ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើការស្តារ និងការកែលម្អបរិស្ថានលើតំបន់រេចរឹល ក្នុងតំបន់ការពារធម្មជាតិដោយសហការជាមួយសហគមន៍មូលដ្ឋាន សហគមន៍តំបន់ការពារធម្មជាតិ សប្បុរសជន វិស័យឯកជន និងសង្គមស៊ីវិល។*

## ៦.១១. ការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការគ្រប់គ្រងធនធានធម្មជាតិតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រ

ក្រមបរិស្ថាន និងធនធានធម្មជាតិបានកំណត់អំពីស្ថាប័នទទួលខុសត្រូវដូចខាងក្រោម ៖

### ក. ស្ថាប័នទទួលខុសត្រូវ

**មាត្រា៣៥០.** ក្រសួងស្ថាប័នទទួលខុសត្រូវ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវគ្រប់គ្រងតំបន់ការពារធម្មជាតិ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

២-តួនាទី ការទទួលខុសត្រូវ និងកិច្ចសហការជាក់លាក់របស់ក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

### ខ. ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ

**មាត្រា៣៥១.** តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ

១-ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ មានតួនាទីជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិនៅព្រះរាជាណាចក្រកម្ពុជា។

២-ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានភារកិច្ចដូចខាងក្រោម៖

ក-រៀបចំសេចក្តីព្រាងគោលនយោបាយជាតិ ផែនការយុទ្ធសាស្រ្តជាតិ ផែនការគ្រប់គ្រង លិខិតបទដ្ឋានគតិយុត្តនានា និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ។

ខ-សិក្សាវាយតម្លៃ និងកំណត់ព្រំប្រទល់ដែនតំបន់ការពារធម្មជាតិដើម្បីចុះបញ្ជីកា។

គ-រៀបចំផែនទីគម្របរុក្ខជាតិ ផែនទីទីជម្រាល និងផែនទីតំបន់ការពារធម្មជាតិនីមួយៗជាផ្លូវការ។

ឃ-លើកការស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយតាមតម្រូវការរបស់រាជរដ្ឋាភិបាល ឬអនុលោមតាមលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

ង-រៀបចំវាយតម្លៃ និងធ្វើចំណាត់ថ្នាក់ប្រភេទធនធានព្រៃឈើ ផលផល និងជីវៈចម្រុះក្នុងតំបន់ការពារធម្មជាតិ។

ច-សិក្សា ប្រមូល ចងក្រង បង្កើតមូលដ្ឋានទិន្នន័យព័ត៌មានស្តីពីធនធានព្រៃឈើ ផលផល និងជីវៈចម្រុះ។

ឆ-អប់រំផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជនក្នុងការចូលរួមថែរក្សា ការពារធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ។

ជ-ចាត់វិធានការដើម្បីត្រួតពិនិត្យ ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ និងកសាងសំណុំរឿងតាមនីតិវិធីជាធរមាន និងធ្វើជាអង្គភាពដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីទាមទារសំណងការខូចខាតនិងការជួសជុលស្តារការខូចខាតធនធានធម្មជាតិនៅចំពោះមុខតុលាការមានសមត្ថកិច្ច។

ឈ-អភិវឌ្ឍសមត្ថភាព និងគាំទ្របច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ។

ញ-ធ្វើអធិការកិច្ច តាមដាន និងវាយតម្លៃទៅលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ។

៣-ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវមានអង្គភាពជំនាញទទួលបន្ទុកតំបន់ការពារ ធម្មជាតិ ជាសេនាធិការសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ។ អង្គភាពជំនាញទទួលបន្ទុកតំបន់ការពារធម្មជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

## គ. រដ្ឋបាលថ្នាក់ក្រោមជាតិ

### មាត្រា ៣៩២. តួនាទីនិងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

១-រដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទី គ្រប់គ្រង អភិរក្សជីវៈចម្រុះ និងធានាការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ និងបទប្បញ្ញត្តិនៃក្រមនេះ។

២-រដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

ក-ធានាដល់ការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយនិរន្តរភាព និងបង្កើនការដាំស្តារព្រៃឈើឡើងវិញនៅលើដីព្រៃរេចរឹល ឬដីទំនេរ។

ខ-រៀបចំនិងអនុវត្តផែនការសកម្មភាពគ្រប់គ្រងតំបន់ការពារធម្មជាតិដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

គ-ចាត់វិធានការដើម្បីត្រួតពិនិត្យ ទប់ស្កាត់ ស្រាវជ្រាវ និងបង្ក្រាបបទល្មើសធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិ និងកសាងសំណុំរឿងទៅតុលាការតាមនីតិវិធីច្បាប់។

ឃ-ទប់ស្កាត់ និងចាត់វិធានការនូវរាល់សកម្មភាពដែលធ្វើឱ្យខូចខាត ឬប៉ះពាល់អវិជ្ជមានក្នុងតំបន់ការពារធម្មជាតិ ដែលបណ្តាលមកពីសកម្មភាពនានា មានជាអាទិ៍ ការកាប់គាស់ រុករាន ទន្ទ្រានដីព្រៃ លិចទឹកព្រៃកោងកាង ស្មៅសមុទ្រ ផ្កាថ្ម ការប្រមូលផល អនុផលព្រៃឈើ ជលផល ការបំពុលទឹក ការដាក់ថ្នាំបំពុលការប្រើប្រាស់សារធាតុគីមី ការចោលសំណល់រឹងរាវចូលក្នុងទឹក ឬលើដី ឬក្រោមដី ការប្រើប្រាស់ឧបករណ៍ធក់ ការបំពុលមជ្ឈដ្ឋានធនធានជីវៈចម្រុះ ភ្លើងឆេះព្រៃ ភ្លើងឆេះតំបន់ដី មមោក ***ការធ្វើកសិកម្មពនេចរ*** ការនាំចូលជំងឺសត្វល្អិតចង្រៃ និងប្រភេទសត្វ រុក្ខជាតិ ឬគ្រាប់រុក្ខជាតិរាតត្បាត។

ង-ត្រួតពិនិត្យលិខិតអនុញ្ញាត និងឯកសារផ្សេងៗដែលកំណត់ដោយក្រមនេះ។

ច-ត្រួតពិនិត្យរាល់ការនាំចេញ ការនាំចូលនូវប្រភេទសត្វ រុក្ខជាតិ គ្រាប់រុក្ខជាតិ និងសំណាកក្នុងតំបន់ការពារធម្មជាតិ។

ឆ-គាំទ្រការប្រើប្រាស់ធនធានធម្មជាតិជាលក្ខណៈប្រពៃណី ទំនៀមទម្លាប់របស់សហគមន៍មូលដ្ឋាននៅក្នុងតំបន់អភិរក្ស និងតំបន់ប្រើប្រាស់ដោយចីរភាព។

ជ-ផ្តល់គោលការណ៍អនុញ្ញាតនិងទទួលស្គាល់លើការបង្កើតសហគមន៍តំបន់ការពារធម្មជាតិនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនិងតំបន់សហគមន៍ ដែលទទួលបានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ។

ឈ-គ្រប់គ្រង និងអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ និងទេសចរណ៍ធម្មជាតិ។

ញ-អប់រំផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋអំពីសារៈសំខាន់នៃការគ្រប់គ្រងការអភិរក្សជីវចម្រុះ ក៏ដូចជាការស្តារប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិ និងការប្រើប្រាស់ធនធានធម្មជាតិប្រកប ដោយនិរន្តរភាព។

ដ-កៀរគរធនធានសម្រាប់គាំទ្រដល់កិច្ចគាំពារ ការអភិរក្ស និងការស្តារជីវៈចម្រុះ។

ឋ-ធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការជាតិ អង្គការអន្តរជាតិ ***អង្គការសង្គមស៊ីវិល និងសប្បុរសជន*** ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានធម្មជាតិ។

៣-រាជរដ្ឋាភិបាល ឬក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានសិទ្ធិផ្ទេរបន្ថែម ឬកែប្រែមុខងារដែលបានផ្ទេរផ្សេងទៀតពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

៤-ការបែងចែកមុខងារ តួនាទី និងភារកិច្ចជាក់លាក់ទៅឱ្យថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

៥-រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានអង្គភាពទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិដើម្បីជាសេនាធិការក្នុងការគ្រប់គ្រង និងការអភិរក្សធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៣៥៣. ការកម្រិតសិទ្ធិរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងករណីគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល**

**រដ្ឋបាលថ្នាក់ក្រោមជាតិមិនអាចសម្រេចលើកិច្ចការដូចខាងក្រោម ៖**

ក- ការអនុញ្ញាតឱ្យធ្វើការកាប់គាស់ រុករាន ឈូសឆាយ ឆ្ការដុតដីព្រៃ ដើម្បីសង់ផ្ទះ សង់តូប សង់រោង យកដីធ្វើជាកម្មសិទ្ធិ ឬដាំដំណាំកសិកម្មនៅក្នុងតំបន់ការពារធម្មជាតិ។

ខ-ការអនុញ្ញាតឱ្យសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តគ្រប់ប្រភេទនៅក្នុងតំបន់ការពារធម្មជាតិ។

គ-ការលក់ ជួល ផ្តល់ ឬផ្ទេរសិទ្ធិកាន់កាប់ដីនៅក្នុងតំបន់ការពារធម្មជាតិទោះបីមួយផ្នែក ឬទាំងមូលក្តី។

ឃ-ការអនុញ្ញាតឱ្យសិក្សារុករក ឬធ្វើអាជីវកម្មរ៉ែនិងថ្មគ្រប់ប្រភេទ និងដឹកកាយឬដកចេញ ឬចូលក្នុង តំបន់ការពារធម្មជាតិ។

ង-ការចេញលិខិតបញ្ជាក់ ឬអនុញ្ញាតទិញលក់ និងកាន់កាប់ដីគ្រប់ប្រភេទនៅតំបន់ការពារធម្មជាតិ។

ច-ការអនុញ្ញាតឱ្យធ្វើការដាំដុះនូវប្រភេទរុក្ខជាតិរាតត្បាត ឬប្រភេទរុក្ខជាតិចំណូលថ្មីរាតត្បាត ដែលមានសក្តានុពលបង្កការប៉ះពាល់ដល់កត្តាជីវសាស្ត្រនៃប្រភេទរុក្ខជាតិដើមក្នុងតំបន់ការពារធម្មជាតិ។

ឆ-ការប្រែក្លាយផ្នែកណាមួយនៃតំបន់ការពារធម្មជាតិឱ្យទៅជាដីលំនៅឋាន ឬភូមិ។

ជ-ការអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើ ក្នុងគោលបំណងមានលក្ខណៈសេដ្ឋកិច្ចក្នុងតំបន់ការពារធម្មជាតិ។

## ៦.១២. ការគ្រប់គ្រងជលផល

### ក. ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥៩៧. ស្ថាប័នទទួលខុសត្រូវ**

១-ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវលើការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផលស្ថិតក្នុងតំបន់ការពារធម្មជាតិ។

២-ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផលក្រៅតំបន់ការពារធម្មជាតិជាសមត្ថកិច្ចរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យជលផល។

### ខ. តួនាទី និងភារកិច្ច

**មាត្រា៥៩៨. តួនាទីនិងភារកិច្ច**

១-ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទី និងភារកិច្ចគ្រប់គ្រងការអភិរក្ស និងការអភិវឌ្ឍធនធានជលផលក្នុងតំបន់ការពារធម្មជាតិដូចខាងក្រោម៖

ក-រៀបចំសេចក្តីព្រាងគោលនយោបាយគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានជលផល ផែនការគ្រប់គ្រង ផែនការមេ និងផែនទីទិន្នន័យសម្រាប់គ្រប់គ្រងជលផល។

ខ-កំណត់ដែននេសាទដើម្បីអនុញ្ញាតឱ្យមានសកម្មភាពនេសាទនិងតំបន់ដែលត្រូវធ្វើការអភិរក្សធនធានជលផល។

គ-គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានជលផល ដើម្បីលើកកម្ពស់សន្តិសុខស្បៀង និងថែរក្សាមច្ឆជាតិសម្រាប់ឧត្តមប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជា។

ឃ-គ្រប់គ្រង និងកំណត់ឱ្យមានសកម្មភាពធ្វើវារីវប្បកម្ម។

ង-សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេសជលផល សេដ្ឋកិច្ច សង្គម និងបរិស្ថាន។

ច-សហការ និងចែករំលែកទិន្នន័យស្តីពីការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។

ឆ-អប់រំផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងរបស់*សាធារណជន*ក្នុងការចូលរួមថែរក្សាការពារជលផល។

ជ-ធ្វើអធិការកិច្ច តាមដាន និងវាយតម្លៃលើការគ្រប់គ្រងជលផល។

ឈ-ធ្វើការស្រាវជ្រាវ ស៊ើបអង្កេត និងចាត់វិធានការផ្លូវច្បាប់លើបទល្មើសជលផល កសាងសំណុំរឿង និងតាំងខ្លួនជាអង្គភាពដើមបណ្តឹងទៅតុលាការមានសមត្ថកិច្ច។

២-ក្រសួងស្ថាប័នទទួលបន្ទុកវិស័យជលផលមានសិទ្ធិអំណាចអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនស្របតាមក្រមនេះ ឬច្បាប់តាមវិស័យរបស់ខ្លួន។

៣-ការបែងចែកមុខងារ តួនាទី និងភារកិច្ចជាក់លាក់ទៅឱ្យថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ។

## គ. កិច្ចគាំពារនិងការអភិរក្សជលផល

**មាត្រា៦០០. ចំណាត់ថ្នាក់តំបន់គ្រប់គ្រងជលផល**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិត្រូវកំណត់តំបន់សម្រាប់ធ្វើកិច្ចគាំពារ និងការអភិរក្សធនធានជលផលក្នុងតំបន់ការពារធម្មជាតិស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងច្បាប់ពាក់ព័ន្ធតាមវិស័យផ្សេងទៀត ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង កិច្ចគាំពារ និងការអភិរក្សធនធានជលផល។

## ឃ. សកម្មភាពដែលត្រូវហាមឃាត់

**មាត្រា៦០១. សកម្មភាពហាមឃាត់ក្នុងកន្លែងអភិរក្សជលផលនៃតំបន់អភិរក្ស និងតំបន់ស្នូលក្នុងតំបន់ការពារធម្មជាតិ**

**ហាមឃាត់សកម្មភាពក្នុងតំបន់អភិរក្សជលផលដូចខាងក្រោម៖**

ក-ការធ្វើនេសាទគ្រប់ប្រភេទលើកលែងតែមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិង ធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ធ្វើការពិសោធន៍ សិក្សាស្រាវជ្រាវបច្ចេកទេស វិទ្យាសាស្ត្រ ជលផល។

ខ-ការធ្វើនាវាចរណ៍ឆ្លងកាត់ដោយរៀបចំឧបករណ៍នេសាទ ដែលមានលក្ខណៈប៉ុនប៉ងធ្វើការនេសាទ ឬសកម្មភាពផ្សេងទៀតដែលប៉ះពាល់ដល់ធនធានជលផល។

គ-ការប្រើប្រាស់ឧបករណ៍នេសាទ ឬសកម្មភាពផ្សេងទៀតដែលច្បាប់ស្ដីពីជលផលបានហាមឃាត់។

## ង. សកម្មភាពដែលត្រូវអនុញ្ញាត

**មាត្រា៦០២. សកម្មភាពដែលត្រូវមានការអនុញ្ញាតក្នុងកន្លែងអភិរក្សជលផលនៃតំបន់អភិរក្ស និងតំបន់ស្នូលក្នុងតំបន់ការពារធម្មជាតិ**

សកម្មភាពដែលអាចអនុញ្ញាតក្នុងកន្លែងអភិរក្សជលផលនៃតំបន់អភិរក្ស និងតំបន់ស្នូលក្នុងតំបន់ការពារធម្មជាតិមានដូចខាងក្រោម៖

ក-ការនេសាទនៅក្នុងកន្លែងអភិរក្សជលផលនៃតំបន់អភិរក្ស និងតំបន់ស្នូលដែលមិនប៉ះពាល់ដល់គោលដៅនៃការអភិរក្សធនធានជលផលអាចធ្វើបាន ដោយមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

ខ-ការគាស់ ការកកាយយកថ្ម ដីខ្សាច់ និងរ៉ែដែលមាននៅក្នុងកន្លែងអភិរក្សជលផលនៃតំបន់អភិរក្ស និងតំបន់ស្នូលអាចធ្វើបានដោយត្រូវមានការពិគ្រោះយោបល់ជាមុន និងសម្រេចរួមគ្នារវាងក្រសួងទទួលបន្ទុក

វិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានរ៉ែ។

**មាត្រា៦០៣. ការរៀបចំអេកូទេសចរណ៍ជលផល**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធបង្កើតតំបន់ទេសចរណ៍ជលផលនៅក្នុងតំបន់អភិរក្ស និងតំបន់ស្នូលនៃតំបន់ការពារធម្មជាតិ ដោយធ្វើការពិគ្រោះយោបល់ជាមួយក្រសួងទទួលបន្ទុកវិស័យជលផល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ច. ការគ្រប់គ្រងការនេសាទក្នុងតំបន់សហគមន៍ និងតំបន់ប្រើប្រាស់ដោយចីរភាព

**ច/១. សិទ្ធិប្រជាពលរដ្ឋ ៖**

**មាត្រា៦០៤. សិទ្ធិប្រជាពលរដ្ឋ**

ប្រជាពលរដ្ឋខ្មែរ ឬបុគ្គលដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយស្របច្បាប់មានសិទ្ធិធ្វើនេសាទ និងចូលរួមក្នុងសកម្មភាពពាក់ព័ន្ធនឹងការនេសាទនៅក្នុងតំបន់សហគមន៍ និងតំបន់ប្រើប្រាស់ដោយចីរភាពនៃតំបន់ការពារធម្មជាតិស្របតាមក្រមនេះ និងច្បាប់ស្តីពីជលផល។

**ច/២. ប្រភេទនៃការធ្វើនេសាទ ៖**

**មាត្រា៦០៥. ប្រភេទនៃការធ្វើនេសាទ**



១-ការធ្វើនេសាទត្រូវកំណត់ប្រភេទដូចខាងក្រោម៖

កការធ្វើនេសាទខ្នាតតូច។ -

ខការធ្វើនេសាទខ្នាតមធ្យម។ -

គការធ្វើនេសាទខ្នាតធំ។ -

២-ប្រភេទនៃការធ្វើនេសាទត្រូវកំណត់តាមប្រភេទឧបករណ៍នេសាទ និងនាវានេសាទ។ ប្រភេទឧបករណ៍នេសាទត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងស្ថាប័នទទួលបន្ទុកវិស័យជលផល។

**ច/៣. ការធ្វើនេសាទ ៖**

**មាត្រា៦០៦. ការធ្វើនេសាទ**

១-ក្រសួងស្ថាប័នទទួលបន្ទុកវិស័យជលផល ឬរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិចេញលិខិតអនុញ្ញាតឱ្យធ្វើការនេសាទ ឬការធ្វើអាជីវកម្មផល ផលិតផលជលផល ឬការធ្វើវារីវប្បកម្មស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងច្បាប់ស្តីពីជលផលនៅក្នុងតំបន់សហគមន៍ និងតំបន់ប្រើប្រាស់ដោយចីរភាព លើកលែងតែការអនុញ្ញាតទាំងនោះប៉ះពាល់ដល់គោលបំណងនៃការគ្រប់គ្រងតំបន់ទាំងនេះ។

២-នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងស្ថាប័នទទួលបន្ទុកវិស័យវិស័យជលផល។

## ៦.១៣. ទេសចរណ៍ធម្មជាតិ

### ក. ក្រសួងស្ថាប័នទទួលខុសត្រូវ

**មាត្រា៦០៧. ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើការសម្របសម្រួល និងសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យទេសចរណ៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងគម្រោងទេសចរណ៍ធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិ។

### ខ. តួនាទី និងភារកិច្ច

**មាត្រា៦០៨. តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

ក-រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការគ្រប់គ្រង ផែនការសកម្មភាពនិងគោលការណ៍ណែនាំបច្ចេកទេស សម្រាប់គ្រប់គ្រងគម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងគម្រោងអភិវឌ្ឍសហគមន៍ទេសចរណ៍ធម្មជាតិ។

ខ-សម្របសម្រួល និងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន ក្នុងការគ្រប់គ្រងគម្រោងវិនិយោគទេសចរណ៍ធម្មជាតិ។

គ-សិក្សា សម្របសម្រួល និងគ្រប់គ្រងគម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងគម្រោងអភិវឌ្ឍសហគមន៍ទេសចរណ៍ធម្មជាតិដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។

ឃ-សម្របសម្រួលការរៀបចំបង្កើត ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកញ្ចប់ទេសចរណ៍ធម្មជាតិ ដើម្បីទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិមកលេងកម្សាន្តនៅក្នុងតំបន់ការពារធម្មជាតិដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។

ង-សហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការសិក្សាកំណត់តំបន់ដែលមានសក្តានុពលក្នុងការអនុវត្តទេសចរណ៍ធម្មជាតិនៅក្នុងតំបន់ ការពារធម្មជាតិ។

ច-តាមដាន ត្រួតពិនិត្យ និងធ្វើអធិការកិច្ចលើការអនុវត្តអាជ្ញាបណ្ណ និងលិខិតអនុញ្ញាតរបស់ឧស្សាហកម្មទេសចរណ៍ធម្មជាតិ។

ឆ-អនុវត្តតួនាទី និងភារកិច្ចបន្ថែមទៀតស្របតាមបទប្បញ្ញត្តិច្បាប់ស្តីពីទេសចរណ៍។

### គ. កាតព្វកិច្ចរបស់គម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិ

**មាត្រា៦១០. កាតព្វកិច្ចរបស់ម្ចាស់គម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិ**

១-ម្ចាស់គម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិមានកាតព្វកិច្ចគាំពារ ថែរក្សាបរិស្ថាន គ្រប់គ្រង និងអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិស្របតាមអាជ្ញាបណ្ណ និងលិខិតអនុញ្ញាត។

២-ម្ចាស់គម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិ ត្រូវចូលរួមចំណែកក្នុងការដាំដើមឈើនៅក្នុងតំបន់ដែលទទួលបានការអនុញ្ញាត។

## ឃ. ការយកថ្លៃចូលទស្សនាសហគមន៍ទេសចរណ៍ធម្មជាតិ

**មាត្រា៦១៣.** ការយកថ្លៃចូលទស្សនាសហគមន៍ទេសចរណ៍ធម្មជាតិ

១-ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ *អាចយកថ្លៃចូលទស្សនាសហគមន៍ទេសចរណ៍ធម្មជាតិ* ដែលស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ ដើម្បីបម្រើគោលដៅការពារ និងអភិរក្សធនធានធម្មជាតិ។

២-កម្រៃសេវាចូលទស្សនាសហគមន៍ទេសចរណ៍ធម្មជាតិ ដែលស្ថិតនៅក្នុងតំបន់ការពារធម្មជាតិត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យទេសចរណ៍។

## ង. សកម្មភាពដែលត្រូវហាមឃាត់

**មាត្រា៦១៤.** សកម្មភាពហាមឃាត់

ហាមឃាត់រាល់សកម្មភាពរបស់គម្រោងអភិវឌ្ឍទេសចរណ៍ធម្មជាតិដូចខាងក្រោម៖

ក-បំពុល ឬកាប់បំផ្លាញធនធានធម្មជាតិនៅក្នុងតំបន់គម្រោងដែលទទួលបានការអនុញ្ញាត។

ខ-បំប្លែង ឬកែប្រែទ្រង់ទ្រាយដើមនៃតំបន់ ដែលបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់មុខងាររបស់តំបន់ការពារធម្មជាតិ។

គ- កាប់គាស់ ឈូសឆាយ និងកាប់រំលំដើមឈើក្នុងតំបន់គម្រោង លើកលែងតែមានការអនុញ្ញាតពីក្រសួងស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ។

ឃ- កាប់គាស់ ឬឈូសឆាយដីព្រៃក្នុងគោលបំណងបំប្លែងយកដីនោះមកធ្វើជាកម្មសិទ្ធិឯកជន។



## ៦.១៤. បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ



**មាត្រា៨៤៩.** បទល្មើសធនធានធម្មជាតិថ្នាក់ទី១ក្នុងតំបន់ការពារធម្មជាតិ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ)ខែ ទៅ ១ (មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០ (ដប់លាន)រៀល ទៅ១០០ ០០០ ០០០ (មួយរយលាន)រៀល ចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើណាមួយនៅក្នុងតំបន់ការពារធម្មជាតិ ដូចខាងក្រោម៖

**ក**-ការនាំចេញ ការនាំចូលគ្រប់ពូជរុក្ខជាតិ ការបង្កាត់ពូជប្រភេទសត្វ ប្រភេទរុក្ខជាតិរាតត្បាត ឬប្រភេទរុក្ខជាតិចំណូលថ្មីរាតត្បាត និងពូជមច្ឆជាតិគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

**ខ**-ធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចបង្កឱ្យមានភ្លើងឆេះព្រៃ ឬភ្លើងឆេះដើមមោក។

**គ**-ប្រើប្រាស់ឧបករណ៍នានា ដែលបង្កការរំខានដោយសំឡេង រំញ័រ រលក និងផ្សេងដែលអាចបង្កការខូចខាតដល់ធនធានធម្មជាតិ និងកិច្ចគាំពារបរិស្ថានក្នុងតំបន់ស្នូល និងតំបន់អភិរក្ស។

**ឃ**-ការរុករករ៉ែដោយគ្មានលិខិតអនុញ្ញាត។

**មាត្រា៨៥០.** បទល្មើសធនធានធម្មជាតិថ្នាក់ទី២ក្នុងតំបន់ការពារធម្មជាតិ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ ១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល ចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើណាមួយនៅក្នុងតំបន់ការពារធម្មជាតិដូចខាងក្រោម៖

**ក**-បង្កើតឡគ្រប់ប្រភេទឬបង្កើតមូលដ្ឋានកែច្នៃផលនិងអនុផលព្រៃឈើ រុក្ខជាតិព្រៃ និងធនធាន ធម្មជាតិគ្រប់ប្រភេទក្នុងតំបន់ស្នូល និងតំបន់អភិរក្ស។

**ខ**-បង្កើតមូលដ្ឋានសម្រាប់កែច្នៃខ្លឹមច័ន្ទន៍ក្រស្នា ម្រះពៅភ្នំ ឬវល្លិរមៀត ឬសម្រាប់ចម្រាញ់រុក្ខជាតិហាមឃាត់ផ្សេងទៀតក្នុងតំបន់ស្នូល និងតំបន់អភិរក្ស។

**គ**-កាប់ ផ្តួល រំលំ គៀរ ចងរឹត បំពុល ធ្វើឱ្យរបួស ធ្វើឱ្យខូចខាត គាស់រម្លើង រុករាន ឬបំផ្លាញព្រៃឈើ និងរុក្ខជាតិព្រៃដែលស្ថិតក្នុងចំណាត់ថ្នាក់ទី៥ និងទី៦ នៃចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ ដោយគ្មានការអនុញ្ញាត។

**ឃ**-ចាប់ដោយដាក់អន្ទាក់ ខ្នារ អង្គប់ បន្ទឹង លប់ បង្គ ឬដោយប្រមាញ់ដែលធ្វើឱ្យរបួស បំពុល សម្លាប់ ឬប្រមូលពង និងកូនសត្វព្រៃគ្រប់ប្រភេទ ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី៥ និងទី៦ នៃចំណាត់ថ្នាក់ប្រភេទសត្វព្រៃ ដោយគ្មានការអនុញ្ញាត។ *(ចំពោះប្រភេទសត្វចំណាត់ថ្នាក់ទី៥ និងទី៦ សូមមើលមាត្រា៨៤៦ នៃក្រមនេះ)*។

**ង**-ដឹកជញ្ជូន ប្រមូល ធ្វើសន្និធិ ឬប្រមូលសន្និធិផល និងអនុផលធនធានធម្មជាតិដោយគ្មានការអនុញ្ញាត។

**ច**-ប្រើប្រាស់អាវុធជាតិផ្ទុះ សារធាតុគីមី ថ្នាំពុល ឬឧបករណ៍ឆក់ ដែលធ្វើឱ្យខូចខាតឬបំពុលដល់ធនធានធម្មជាតិ។

ឆ-ជួញដូរសត្វព្រៃ ឬសំណាកសត្វព្រៃគ្រប់ប្រភេទ ឬចិញ្ចឹមសត្វព្រៃសម្រាប់ការធ្វើពាណិជ្ជកម្មដោយគ្មានការអនុញ្ញាត។

ជ-យាយី ឬបំផ្លាញជម្រកពង កូន កន្លែងបន្តពូជសត្វព្រៃ និងមច្ឆជាតិ។

ឈ-រំកិល ដកចេញ ឬបំផ្លាញគោលសីមា ឬសញ្ញាសម្គាល់ព្រំប្រទល់តំបន់ការពារធម្មជាតិ។

ញ-បំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

ដ-ចាក់លុប ឬចាក់បំពេញដី ដែនទឹក ផ្ទៃរងទឹកភ្លៀង ផ្លូវទឹក បឹងធម្មជាតិ ដីសើម តំបន់ទំនាប ទឹកផុសក្រោមដី ឬអាងទឹក ដោយគ្មានការអនុញ្ញាត។

ឋ-ធ្វើឱ្យរាំងស្ទះដល់លំហូរបរិស្ថាននៃបឹងបួ ទន្លេ ស្ទឹង អូរ ឬព្រែក ដោយគ្មានការអនុញ្ញាត។

ឌ-បោះបង្គោលហ៊ុមព័ទ្ធ ឬដាក់សញ្ញាសម្គាល់លើដីដែលជាទ្រព្យសម្បត្តិរដ្ឋក្នុងតំបន់ការពារធម្មជាតិក្នុងគោលបំណងកាន់កាប់ដើម្បីយកដីធ្វើជាកម្មសិទ្ធិ។

ឍ-នេសាទដែលផ្ទុយនឹងបទប្បញ្ញត្តិនៃក្រមនេះ ដែលធ្វើឱ្យខូចខាតដល់ធនធានធម្មជាតិ ទាំងក្នុងដែនសមុទ្រ និងដែនទឹកសាប ព្រៃលិចទឹក ព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ ក្នុងតំបន់ប្រើប្រាស់ ដោយចីរភាព និងតំបន់សហគមន៍មូលដ្ឋាន។

ណ-យកថ្ម គ្រួស ខ្សាច់ ឬរ៉ែ ឬការគាស់ ឈូសឆាយ ឬកកាយយកដី ដោយគ្មានការអនុញ្ញាត។

**មាត្រា៨៥១. បទល្មើសធនធានធម្មជាតិថ្នាក់ទី៣ក្នុងតំបន់ការពារធម្មជាតិ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ)ឆ្នាំទៅ ១០(ដប់)ឆ្នាំ ចំពោះបុគ្គលដែលប្រព្រឹត្តអំពើណាមួយនៅក្នុងតំបន់ការពារធម្មជាតិដូចខាងក្រោម៖

ក-នាំចូល ឬនាំចេញនូវប្រភេទសត្វ ឬគ្រាប់រុក្ខជាតិគ្រប់ប្រភេទ ដែលជាសត្វ ឬរុក្ខជាតិដែលស្ថិតក្នុងចំណាត់ថ្នាក់ទី២ ដល់ទី៤ នៃចំណាត់ថ្នាក់ប្រភេទសត្វព្រៃ និងរុក្ខជាតិព្រៃដោយគ្មានការអនុញ្ញាត។ *(ចំពោះប្រភេទសត្វចំណាត់ថ្នាក់ទី២ ដល់ទី៤ សូមមើលមាត្រា៥៤៦ និងចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ សូមមើលមាត្រា៥២០ នៃក្រមនេះ)*។

ខ-កាប់ ផ្តួល រំលំ គៀរ ចងរឹត បំពុល ធ្វើឱ្យរបួស ធ្វើឱ្យខូចខាត គាស់រម្លើង រុករាន ឬបំផ្លាញព្រៃឈើ និងរុក្ខជាតិព្រៃដែលស្ថិតក្នុងចំណាត់ថ្នាក់ទី២ ដល់ទី៤ នៃចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ។ *(ចំពោះរុក្ខជាតិព្រៃដែលស្ថិតក្នុង ចំណាត់ថ្នាក់ទី២ ដល់ទី៤ សូមមើលមាត្រា៥២០ នៃក្រមនេះ)*។

គ-បង្កឱ្យមានភ្លើងឆេះព្រៃ ឬភ្លើងឆេះដីមមោកដោយចេតនា។

ឃ-នេសាទដែលផ្ទុយនឹងបទប្បញ្ញត្តិនៃក្រមនេះ ដែលធ្វើឱ្យខូចខាតដល់ធនធានធម្មជាតិ ទាំងក្នុងដែនសមុទ្រ និងដែនទឹកសាប ព្រៃលិចទឹក ព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ ក្នុងតំបន់ស្នូល និងតំបន់អភិរក្ស។

ង-ចាប់ដោយដាក់អន្ទាក់ ខ្នារ អង្គប់ បន្ទឹង លប់ បង្កៃ ឬដោយដែលធ្វើឱ្យរបួស បំពុល សម្លាប់ ឬ ប្រមូលពង និងកូនសត្វព្រៃគ្រប់ប្រភេទតាមគ្រប់រូបភាព ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី២ ដល់ទី៤ នៃចំណាត់ថ្នាក់ប្រភេទសត្វព្រៃដោយគ្មានការអនុញ្ញាត។ *(ចំពោះប្រភេទសត្វចំណាត់ថ្នាក់ទី២ ដល់ទី៤ សូមមើលមាត្រា៥៤៦ នៃក្រមនេះ)*។

ច-កាប់គាស់ ឬរុករានដីព្រៃ ឬឆ្ការ ដុត ឬឈូសឆាយដីព្រៃ ដើម្បីយកដីធ្វើជាកម្មសិទ្ធិ

**មាត្រា៤៥២ .ការធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬស្រង់យកសម្បត្តិវប្បធម៌ក្រោមទឹកដោយចេតនា**

បុគ្គលដែលបង្កការខូចខាត ការបំផ្លិចបំផ្លាញ ឬការស្រង់យកសម្បត្តិវប្បធម៌ក្រោមទឹកដោយចេតនាដូចមានចែងក្នុងមាត្រា៤២៧( ការហាមឃាត់ចំពោះការធ្វើឱ្យខូចខាត ការស្រង់យក ឬបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ក្រោមទឹក )នៃក្រមនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ ០០០ (មួយរយលាន)រៀល ទៅ៥០០ ០០០ ០០០ (ប្រាំរយលាន)រៀល។

# ៧. ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

## ៧.១. ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ច្បាប់ជាតិមួយចំនួននៃប្រទេសកម្ពុជាបានផ្តល់កិច្ចការពារបរិស្ថាន និងលើកឡើងពីការប្រឹក្សាយោបល់ជាសាធារណៈ និងការគ្រប់គ្រប់គ្រងធនធានធម្មជាតិ។ មាត្រា៥៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបាន ចែងថា រដ្ឋមានទំនួលខុសត្រូវក្នុងការរក្សាការពារបរិស្ថាន ជាពិសេសកិច្ចការនេះកន្លងមក ត្រូវបានអនុវត្តដោយអនុលោមទៅតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធម្មជាតិឆ្នាំ១៩៩៦ ប៉ុន្តែច្បាប់នេះបាននីរាករណ៍ចាប់ពី ក្រមបរិស្ថាន និងធនធានធម្មជាតិ ដែលត្រូវបានប្រកាសឱ្យអនុវត្តក្នុងខែមិថុនា ឆ្នាំ២០២៤ តទៅ។

ដូចនេះការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមត្រូវអនុវត្តតាមក្រមបរិស្ថាន និងធនធានធម្មជាតិ។

### ក. គោលបំណងនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា ៦៤៩** ៖ មានគោលបំណងជានាប្រសិទ្ធិភាពនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងវិនិយោគទាំងសាធារណៈ និងឯកជន ដោយមានការចូលរួមជាសាធារណៈ សំដៅបង្ការ បញ្ចៀស ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងសង្គម ដែលបង្កឡើងដោយគម្រោងវិនិយោគ។

### ខ. ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

**មាត្រា ១៦** ៖ វិធានការនានានៃការកាត់បន្ថយឬទប់ស្កាត់ការខូចខាតបរិស្ថាន ត្រូវធ្វើឡើងមុនពេលការខូចខាតនោះកើតឡើង។ វិធានការនេះត្រូវធ្វើឡើងជាមុនដោយតម្រូវឱ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមប្រសើរជាងធ្វើការស្តារឬជុលជុលការខូចខាត។

***សេចក្តីពន្យល់ខ្លះៗនៅក្នុងបទដ្ឋានគតិយុត្តពាក់ព័ន្ធ មុនក្រមបរិស្ថាន និងធនធានធម្មជាតិ ត្រូវបាន អនុវត្ត ៖***

*១. ការវាយតម្លៃហេតុប៉ះពាល់សង្គម*

ការវាយតម្លៃហេតុប៉ះពាល់សង្គម មិនត្រូវបានបរិយាយយ៉ាងទូលំទូលាយនៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិនោះទេ ក៏ប៉ុន្តែនៅក្នុងការពន្យល់អំពីតួនាទី និងភារកិច្ចរបស់នាយកដ្ឋានវាយតម្លៃហតុប៉ះពាល់បរិស្ថានបានសេរសេរថា នាយកដ្ឋានវាយតម្លៃហតុប៉ះពាល់បរិស្ថានមានតួនាទី និងភារកិច្ចដូចជារៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការនិងថិកា លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំពាក់ព័ន្ធនឹងការវាយ

តម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម រៀបចំឯកសារស្ដីពីគោលការណ៍ណែនាំ និងលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃក្រុមហ៊ុនដែលស្នើសុំចុះបញ្ជីជាក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ជំរុញការបង់មូលនិធិទាយជ្ជទានបរិស្ថាន និងសង្គម ក៏ដូចជាសម្របសម្រួលជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីចុះអង្កេត តាមដាន និងពង្រឹងការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

នៅក្នុងមាត្រា៤ នៃអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ស្ដីពីសម្បទានដីសេដ្ឋកិច្ចបានបញ្ជាក់យ៉ាងច្បាស់ថា សម្បទានដីសេដ្ឋកិច្ចមួយអាចត្រូវបានផ្ដល់ឱ្យបាន លុះត្រាតែការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវបានធ្វើឡើងយ៉ាងពេញលេញ។

### ២. *ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម*

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម គឺជាដំណើរការដែលចំណាយពេលវេលាច្រើន និងរួមបញ្ចូលនូវជំហានជាច្រើនដូចជា ការត្រួតពិនិត្យបឋមរហូតដល់ការសិក្សានៅថ្នាក់មូលដ្ឋាន និងការកាត់បន្ថយផលប៉ះពាល់។[14] កិច្ចការទាំងនេះចាំបាច់ត្រូវមានការពិភាក្សាជាមួយនឹងភាគីពាក់ព័ន្ធក៏ដូចជាការបង្កើតផែនការគ្រប់គ្រងបរិស្ថាន និងសង្គមផងដែរ។[15]

## គ. តើអ្វីជាធនធានធម្មជាតិ?

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៥ អំពី***សេដ្ឋកិច្ច*** ក្នុងមាត្រា៥៩ និងនៅក្នុងឧបសម្ព័ន្ធនៃក្រមបរិស្ថាន និងធនធានធម្មជាតិ ***«សន្ទានុក្រម (ធ ន ប)»*** ធនធានធម្មជាតិសំដៅដល់ចំណែកណាមួយនៃបរិស្ថានធម្មជាតិមានជាអាទិ៍ ៖




---

[14] "រាល់ជំហានដែលតម្រូវទាំងអស់សម្រាប់ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម អាចរកមើលបាននៅក្នុង "ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម", *IFC,*ទំព័រ១,

[15] "ច្បាប់ស្ដីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៤ មាត្រា១, "តំបន់សេដ្ឋកិច្ចពិសេស និងការដេកយកអត្ថប្រយោជន៍ពីទន្លេមេគង្គ", *Focus on the Global South*, ខែកក្កដា ឆ្នាំ២០១៧ ទំព័រ១៦, កថាខណ្ឌទី២

## ឃ. ស្ថាប័នទទួលខុសត្រូវក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា ៦៤០ ៖** ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវលើការរៀបចំឱ្យមានការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រក្នុងក្របខ័ណ្ឌគោលនយោបាយ ផែនការ និងកម្មវិធីអភិវឌ្ឍរបស់រាជរដ្ឋាភិបាល។

**មាត្រា ៦៤១ ៖** តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក-កំណត់វិស័យអាទិភាពដែលតម្រូវឱ្យមានការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

ខ-ធ្វើការពិនិត្យនិងសម្រេចលើរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

គ-សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

ឃ-កំណត់គោលការណ៍ណែនាំសម្រាប់រៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

## ង. វិសាលភាពនៅក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ




**មាត្រា ៦៥០** *នៃក្រមនេះបានចែងថា ៖*

១-មាតិកានេះមានវិសាលភាពអនុវត្តលើការវាយតម្លៃហេតុប៉ះពាល់ពាល់បរិស្ថានលើរាល់គម្រោងវិនិយោគទាំងសាធារណៈ និងឯកជន មានជាអាទិ៍ គម្រោងស្នើសុំ គម្រោងមានស្រាប់ និងគម្រោងកំពុងដំណើរការដែលអាចបង្កហេតុប៉ះពាល់ដល់បរិស្ថាន សុខភាព សេដ្ឋកិច្ច សង្គម និងវប្បធម៌។

២-ក្នុងករណីដែលគម្រោងអភិវឌ្ឍអាចបង្កឱ្យមានហេតុប៉ះពាល់ឆ្លងដែនដល់បរិស្ថាន សុខភាព សេដ្ឋកិច្ច សង្គម និងវប្បធម៌ ម្ចាស់គម្រោងត្រូវធ្វើការសិក្សាបន្ថែមលើហេតុប៉ះពាល់បរិស្ថានឆ្លងដែន ដោយអនុលោមតាមច្បាប់ និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

## ច. គម្រោងលើកលែងក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា ៦៥១** *នៃក្រមនេះបានចែងថា ៖* ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមិនអនុវត្តចំពោះគម្រោងអភិវឌ្ឍឬសកម្មភាពរបស់រដ្ឋ ដែលបានសម្រេច ឬអនុម័តដោយរាជរដ្ឋាភិបាលឬរដ្ឋសភាហើយដែលចាត់ទុកជាគម្រោងចាំបាច់ និងបន្ទាន់ទាក់ទងនឹងសន្តិសុខជាតិ បូរណភាពទឹកដី អធិបតេយ្យភាពជាតិ ឬគ្រោះមហន្តរាយនានា។

## ឆ. ការពិគ្រោះយោបល់ជាមុនក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា៦៩១** *ការពិគ្រោះយោបល់ជាមុន*

១-កិច្ចដំណើរការចូលរួមជាសាធារណៈត្រូវធានាថាមានការពិគ្រោះយោបល់ជាមុនពីអ្នកទទួលរងផលប៉ះពាល់ ដោយសារគម្រោង ចំពោះវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលបានស្នើឡើងដោយផ្អែកលើការពិគ្រោះយោបល់ និងបន្ទាប់ពីទទួលបានព័ត៌មានជាមុន។

២-ក្នុងវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាននេះ ម្ចាស់គម្រោងត្រូវ៖

ក-កំណត់វិធានការនានាក្នុងការលើកកម្ពស់ជីវភាព និងជួយដល់អ្នកដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង។

ខ-ធានាថាអ្នកដែលទទួលរងផលប៉ះពាល់បានចូលរួម*ក្នុងការរៀបចំការផ្លាស់ទីលំនៅថ្មី*ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការផ្លាស់ទីលំនៅថ្មីឱ្យនៅត្រឹមកម្រិតអប្បបរមា និងធានាថាសំណងលើការបាត់បង់ ទ្រព្យសម្បត្តិត្រូវបាន*ដោះស្រាយដោយសមរម្យ ត្រឹមត្រូវ និងយុត្តិធម៌ជាមុនសិន* ហើយវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានមានលក្ខណៈត្រឹមត្រូវ។

៣-ក្នុងករណីដែលសហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់មិនយល់ស្រប ចំពោះវិធានការកាត់បន្ថយនានាដែលម្ចាស់គម្រោងបានស្នើខាងលើ *គម្រោងអភិវឌ្ឍនៅតែបន្តដដែល* តែម្ចាស់គម្រោងត្រូវកំណត់រកវិធានការកាត់បន្ថយហេតុប៉ះពាល់ផ្សេងទៀត ឬដោះស្រាយរាល់ហេតុប៉ះពាល់នោះដល់សហគមន៍មូលដ្ឋាន។

៤-នីតិវិធីនៃការដោះស្រាយសំណងដល់សហគមន៍មូលដ្ឋានដែលទទួលរងផលប៉ះពាល់ និងនីតិវិធីនៃ**ការផ្លាស់ប្តូរលំនៅថ្មី** ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ។

៥-បែបបទ និងនីតិវិធីនៃ**ការទូទាត់សំណងការខូចខាតដល់សហគមន៍មូលដ្ឋាន** ដែលទទួលរងផលប៉ះពាល់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៧.២. ការចូលរួមជាសាធារណៈក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

*រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៥ ៖* ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ *សេដ្ឋកិច្ច* សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិសេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានទទួលការពិនិត្យនិងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ។

### ក. គោលបំណងនៃការចូលរួមជាសាធារណៈ

***មាត្រា ៦៨៧*** *នៃក្រមបរិស្ថាន និងធនធានធម្មជាតិ បានចែងថា ៖*

១- គោលបំណងចម្បងនៃការចូលរួមជាសាធារណៈ ត្រូវធានាថាគ្រប់ភាគីពាក់ព័ន្ធត្រូវបានចូលរួមនៅក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ការរស់នៅប្រកបដោយចីរភាព និងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

២- នីតិវិធីនៃការចូលរួមជាសាធារណៈ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

### ខ. សិទ្ធិរបស់អ្នកចូលរួមជាសាធារណៈក្នុងការធ្វើសកម្មភាព

***មាត្រា ៦៨៨*** *នៃក្រមបរិស្ថាន និងធនធានធម្មជាតិ បានចែងថា ៖*

ភាគីពាក់ព័ន្ធដែលមានសិទ្ធិក្នុងការចូលរួមជាសាធារណៈអាចធ្វើសកម្មភាព ដូចខាងក្រោម៖

ក-រាយការណ៍ទៅអាជ្ញាធរពាក់ព័ន្ធនិងផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពឬការធ្វើសេចក្តីសម្រេចណាមួយ ដែលអាចនឹងមានផលប៉ះពាល់ទៅលើបរិស្ថាននិងធនធានធម្មជាតិ។

ខ-លើកសំណួរស្នើឱ្យមានការស្រាយបំភ្លឺ ធ្វើការតវ៉ា និងចូលរួមពិភាក្សាអំពីសកម្មភាព ឬសេចក្តីសម្រេចណាមួយដែលអាចបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាននិងធនធានធម្មជាតិ។

គ-ដាក់ពាក្យប្តឹងឬបណ្តឹងប្រឆាំងនឹងសេចក្តីសម្រេចស្របតាមយន្តការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិដូចមានចែងនៅក្នុងមាតិកាទី១( នីតិវិធីនៃការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ ) នៃគន្ថីទី៩នៃក្រមនេះ។

## គ.គន្ថីទី៩ នៃក្រមបរិស្ថាន និងធនធានធម្មជាតិ អំពីការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ



**មាត្រា៨០០** ***អំពីវិសាលភាព*** ៖ គន្ថីនេះមានវិសាលភាពអនុវត្តលើការដោះស្រាយវិវាទទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិទៅលើពាក្យប្តឹងឬការទាមទារដូចខាងក្រោម៖

ក-ទាមទារឱ្យសងសំណងការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

ខ-ទាមទារឱ្យស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិឡើងវិញ។

គ-ទាមទារឱ្យកំណត់វិធានការ ដើម្បីធានាថា នឹងមិនបង្កការបំពុលបរិស្ថាន ឬធនធានធម្មជាតិ ឬការធ្វើឱ្យខូចខាតបរិស្ថាន ឬធនធានធម្មជាតិសាជាថ្មីឡើងវិញ។

ឃ-ទាមទារឱ្យកំណត់វិធានការទប់ស្កាត់ផលប៉ះពាល់ជាអវិជ្ជមាន ដែលកើតមានចំពោះបរិស្ថានឬធនធានធម្មជាតិ។

**មាត្រា៨០១** ***អំពីគោលការណ៍ទូទៅនៃការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ*** ៖

១-ចំពោះការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទនោះទៅយន្តការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដើម្បីសម្រុះសម្រួលមុននឹងប្តឹងទៅតុលាការដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

២-ប៉ុន្តែបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ មិនរាំងដល់ការប្រើប្រាស់សិទ្ធិក្នុងការប្តឹងទៅតុលាការដោយផ្ទាល់នោះទេ។ ក្នុងករណីចាំបាច់ តុលាការដែលទទួលពាក្យបណ្តឹងទាក់ទងនឹងវិវាទបរិស្ថាននិងធនធានធម្មជាតិអាចបញ្ជូនសំណុំរឿងនេះទៅយន្តការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ ដើម្បីធ្វើការសម្រុះសម្រួលជាមុន។ ក្នុងករណីដែលពុំមានដំណោះស្រាយតាមការស្រុះស្រួលគ្នានៅចំពោះមុខយន្តការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ភាគីមានសិទ្ធិស្នើសុំឱ្យតុលាការដើម្បីបន្តអនុវត្តនីតិវិធីរបស់ខ្លួនស្របតាមច្បាប់និងនីតិវិធីជាធរមាន។

៣-ការសម្រុះសម្រួលដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ ដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើមិនត្រូវយកមកអនុវត្តឡើយចំពោះបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសដោយយោងតាមក្រមនេះ។

៤-ការសម្រុះសម្រួលដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ គឺមិនរាំងការអនុវត្តបទប្បញ្ញត្តិព្រហ្មទណ្ឌផ្សេងទៀត ប្រសិនបើអង្គហេតុដែលជាកម្មវត្ថុនៃការសម្រុះសម្រួលនេះបង្កើតបានជាបទល្មើសដែលត្រូវផ្តន្ទាទោសដោយយោងតាមក្រមនេះឬច្បាប់ព្រហ្មទណ្ឌជាធរមានដទៃទៀត។

***មាត្រា ៨០២ អំពីភាគីនៃវិវាទបរិស្ថាន និងធនធានធម្មជាតិ ភាគីដែលមានសិទ្ធិធ្វើបណ្តឹងបរិស្ថាននិងធនធានធម្មជាតិ មានដូចខាងក្រោម ៖***

ក-ភាគីដែលរងផលប៉ះពាល់ អាចធ្វើសកម្មភាពបណ្តឹង ដើម្បីទាមទារសំណងការខូចខាត ឬសំណងជំងឺចិត្ត។

ខ-ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិធ្វើសកម្មភាពបណ្តឹងដើម្បីទាមទារសំណងការខូចខាតបរិស្ថាន ឬធនធានធម្មជាតិ ឬស្តារបរិស្ថានឡើងវិញ ឬទប់ស្កាត់សកម្មភាពណាមួយដែលបង្កផលប៉ះពាល់ឬបំពុលបរិស្ថាន និងខូចខាតលើធនធានធម្មជាតិ។

គ-*សមាគម និងអង្គការ* ដែលបានចុះបញ្ជីស្របច្បាប់ និងទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ អាចធ្វើសកម្មភាពបណ្តឹងដើម្បីបញ្ឈប់ ឬទប់ស្កាត់សកម្មភាពណាមួយ ទាមទារសំណងការខូចខាតបរិស្ថាន ឬធនធានធម្មជាតិ ឬទាមទារសំណងការខូចខាតឬជំងឺចិត្តជូនជនរងគ្រោះ ឬសហគមន៍។ ប៉ុន្តែចំពោះការទាមទារសំណងការខូចខាត ឬជំងឺចិត្តជូនជនរងគ្រោះ ឬ**សហគមន៍ត្រូវមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវ**។

***មាត្រា ៨០៣ អំពីរចនាសម្ព័ន្ធគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ (យន្តការ) ៖***

១- គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ មានរចនាសម្ព័ន្ធដូចខាងក្រោម៖

ក-គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់ជាតិ។

ខ- គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់រាជធានី ខេត្ត។

២-ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់ជាតិ និងគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិថ្នាក់រាជធានី ខេត្ត ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ។

***មាត្រា ៨០៤ អំពីសមត្ថកិច្ចរបស់គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ ៖***

១-គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់ជាតិមានសមត្ថកិច្ចសម្រុះសម្រួលលើវិវាទបរិស្ថាននិងធនធានធម្មជាតិ ដែលភាគីណាមួយនៃវិវាទប្តឹងតវ៉ាមិនសុខចិត្តនឹងការសម្រុះសម្រួលរបស់គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិថ្នាក់រាជធានី ខេត្ត ឬក្នុងករណីដែលទទួលបណ្តឹងដោយផ្ទាល់ពីភាគីណាមួយនៃវិវាទ។

២-គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ថ្នាក់រាជធានី ខេត្ត មានសមត្ថកិច្ចសម្រុះសម្រួលលើវិវាទបរិស្ថាន និងធនធានធម្មជាតិ នៅក្នុងដែនសមត្ថកិច្ចរាជធានី ខេត្តរបស់ខ្លួន។

***មាត្រា ៨០៥ អំពីការសម្រុះសម្រួលវិវាទបរិស្ថាននិងធនធានធម្មជាតិ (នីតិវិធីដោះស្រាយវិវាទ) ៖***

១-ការសម្រុះសម្រួលវិវាទបរិស្ថាន និងធនធានធម្មជាតិត្រូវធ្វើដោយផ្អែកលើច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

២-បែបបទនិងនីតិវិធីនៃការសម្រុះសម្រួលវិវាទបរិស្ថាននិងធនធានធម្មជាតិដោយគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់ជាតិ និងគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ជាតិថ្នាក់រាជធានី ខេត្ត ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា ៨០៦** ***អំពីកិច្ចព្រមព្រៀងសះជា ៖***

១-កិច្ចព្រមព្រៀងសះជា ត្រូវធ្វើឡើងនៅចំពោះមុខគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់ជាតិ ឬថ្នាក់រាជធានី ខេត្ត និងត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយត្រូវឱ្យភាគីនៃវិវាទទាំងអស់ចុះហត្ថលេខា ឬផ្តិតម្រាមដៃ ព្រមទាំងចុះហត្ថលេខា ឬផ្តិតម្រាមដៃបញ្ជាក់លើកិច្ចព្រមព្រៀងសះជានោះ ដោយសមាជិកទាំងអស់នៃគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិថ្នាក់ជាតិ ឬថ្នាក់រាជធានី ខេត្ត។

២-កិច្ចព្រមព្រៀងសះជា ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវមានអានុភាពអនុវត្តដូចគ្នាទៅនឹង លិខិតអនុវត្ត លើកលែងតែកិច្ចព្រមព្រៀងនេះមានវិការៈ។

៣-កិច្ចព្រមព្រៀងសះជានេះមិនមែនជាឧបសគ្គសម្រាប់តតិយជនក្នុងការប្រើប្រាស់សិទ្ធិស្របច្បាប់ ដើម្បីការពារផលប្រយោជន៍របស់ខ្លួនឡើយ។

**មាត្រា ៨០៧** ***អំពីការប្តឹងបន្តក្នុងករណីមិនសះជា ៖***

ក្នុងករណីដែលការសម្រុះសម្រួលមិនសះជានៅថ្នាក់រាជធានី ខេត្ត ភាគីនៃវិវាទមានសិទ្ធិប្តឹងបន្តទៅគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិថ្នាក់ជាតិ ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃទទួលបានកំណត់ហេតុមិនសះជា។ ក្នុងករណីដែលការសម្រុះសម្រួលមិនសះជានៅថ្នាក់ជាតិ ភាគីនៃវិវាទ មានសិទ្ធិប្តឹងបន្តទៅតុលាការមានសមត្ថកិច្ច ដោយអនុវត្តស្របតាមច្បាប់ និងនីតិវិធីជាធរមាន។

### ឃ.គោលការណ៍ផ្សព្វផ្សាយជាសាធារណៈក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា៦៩៣** ***ការផ្សព្វផ្សាយជាសាធារណៈ***

១-ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវធានាថាព័ត៌មានពាក់ព័ន្ធនឹងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងឯកសារពាក់ព័ន្ធត្រូវបានផ្សព្វផ្សាយជាសាធារណៈ ហើយភាគីពាក់ព័ន្ធ និងសហគមន៍មូលដ្ឋានដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង អាចទទួលបានព័ត៌មានគ្រប់គ្រាន់ និងច្បាស់លាស់។

២-ម្ចាស់គម្រោងត្រូវធ្វើការផ្សព្វផ្សាយជាសារជារណៈ តាមរយៈគេហទំព័ររបស់ខ្លួនយ៉ាងហោចណាស់នូវឯកសារ ឬព័ត៌មានថតចម្លងនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងផែនការនៃគម្រោង ព្រមទាំងបណ្តាវិធានការកាត់បន្ថយហេតុប៉ះពាល់នៃគម្រោងដែលត្រូវបានស្នើឡើង។

៣-នីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ។

**មាត្រា៧១០** ***ការដាក់បង្ហាញព័ត៌មានឱ្យសាធារណជនអាចស្វែងរកបាន***

១-ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវ ធានាព័ត៌មានពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចដាក់បង្ហាញឱ្យសាធារណជនស្វែងរកបាន។

២-ទម្រង់បែបបទ និងនីតិវិធីនៃការដាក់បង្ហាញព័ត៌មាន ដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១ ខាងលើនេះត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

# ៨. ការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ និងការទប់ស្កាត់សកម្មភាពអសកម្ម

## ៨.១. សារាចរណែនាំស្ដីពីការអភិវឌ្ឍតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជា

នៅក្នុងឆ្នាំ២០១២ រាជរដ្ឋាភិបាលកម្ពុជាបានចេញសារាចរណែនាំស្ដីពីការអភិវឌ្ឍតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជាដើម្បីណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យអនុវត្តនូវគោលការណ៍គ្រប់គ្រង ប្រើប្រាស់ ថែរក្សា ការពារ និងអភិវឌ្ឍតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងនោះរួមបញ្ចូលនូវដែនកោះ ដែនគោក និងដែនទឹកដូចដែលមាននៅក្នុងសារាចរណែនាំនោះ។

យើងមិនអាចបដិសេធបានទេ ពីការវិវត្តមួយចំនួនដែលស្ដែងចេញនូវភាពវិជ្ជមានគួរឲ្យកត់សម្គាល់នៃតំបន់ឆ្នេរដែលមានសក្ដានុពលសេដ្ឋកិច្ច សង្គម និងវប្បធម៌។ ការណ៍នេះ អាចស្ដែងចេញនូវចេតនា និងការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រនៃខេត្តទាង៤ឲ្យកាន់តែមានប្រសិទ្ធភាព និងនិរន្តរភាព។ នៅក្នុងរបៀបវារៈនេះ គេសំឡឹងឃើញការអនុវត្តដែលមានភាពប្រទាក់ក្រឡាគ្នា និងជួយបំពេញគ្នាទៅវិញទៅមករបស់ស្ថាប័នចម្រុះដែលពាក់ព័ន្ធ ហើយពិតណាស់ បើដំណើរការនៃការគ្រប់គ្រងតំបន់ឆ្នេរប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព វានឹងពាំនាំនូវការរីកចម្រើនផ្នែកសេដ្ឋកិច្ចសង្គម ជាពិសេសគឺការធានាបាននូវនិរន្តរភាពនៃបរិស្ថាន។

### ៨.១.១. ឆ្នេរសមុទ្រ

តំបន់ឆ្នេរសមុទ្រសំដៅដល់តំបន់ដីគោកដែលស្ថិតនៅជាប់សមុទ្រ និងទទួលរងឥទ្ធិពលនៃសមុទ្រមាននៅខេត្តកំពត កោះកុង ក្រុងព្រះសីហនុ និងក្រុងកែប ដោយរួមបញ្ចូលទាំងបូរណភាពដែនសមុទ្រដែលលាតសន្ធឹងដល់ព្រំប្រទល់តំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់ព្រះរាជាណាចក្រកម្ពុជា។[16]

ឆ្នេរសមុទ្រនៃប្រទេសកម្ពុជាមានភាពសម្បូរបែបនៃជីវៈចម្រុះ ភាពប្រណីតនៃបរិស្ថានធម្មជាតិ តម្លៃអេកូឡូស៊ី សេដ្ឋកិច្ចសង្គម វប្បធម៌ និងប្រពៃណីក្នុងតំបន់ ព្រមទាំងភាពទាក់ទាញផ្នែកទេសចរណ៍។ ទោះជាបែបនេះក្ដី តំបន់ឆ្នេរនៃប្រទេសកម្ពុជាមិនទាន់មានការអភិវឌ្ឍខ្លាំងក្លានៅឡើយទេ។ តំបន់ឆ្នេរជាទីសម្រាប់ប្រជាជនក្នុងតំបន់អាចប្រកបរបរចិញ្ចឹមជីវិតដោយអាស្រ័យធនធាននានានៅតាមឆ្នេរសមុទ្រ។ តំបន់សមុទ្រ និងឆ្នេរ រួមបញ្ចូលទាំងនៅក្នុងសមុទ្រ និងនៅលើគោក រួមទាំងព្រៃកោងកាង ហើយលើកលែងទន្លេ និងបឹងបួរចេញ។ ឆ្នេរសមុទ្រត្រូវកំណត់ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតនៃទឹកសមុទ្រឡើងមកលើ រហូតដល់ខ្សែបន្ទាត់ហាមឃាត់ការកាន់កាប់ ឬសាងសង់នានាជាថ្ម ដី ឬខ្សាច់ដែលបានកំណត់ទុកជាតំបន់សម្រាប់ប្រើប្រាស់ជាសាធារណៈ និងត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។ ទំហំឆ្នេរសមុទ្រត្រូវបានកំណត់ដូចខាងក្រោម[17]៖

- ឆ្នេរជម្រាលត្រូវកំណត់យ៉ាងតិច៣០ម៉ែត្រចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតទៅខាងដីគោក
- ឆ្នេរចោតត្រូវកំណត់យ៉ាងតិច២០ម៉ែត្រចាប់ពីចំណុចកំពូលនៃផ្ទៃចោតមកខាងដីគោក។

[16] ឧបសម្ព័ន្ធនៃក្រមបរិស្ថាននិងធនធានធម្មជាតិ (សន្ធានុក្រម ត ថ ទ)

[17] សារាចរណែនាំស្ដីពីការអភិវឌ្ឍតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជា, ២០១២

ក្នុងករណីដែលស្ថានភាពទីតាំងជាក់ស្តែងនៃឆ្នេរជម្រាលមិនអាចកំណត់តាមទំហំខាងលើបាន ទំហំឆ្នេរសមុទ្រត្រូវកែច្នៃ ឬពង្រីកបន្ថែមដើម្បីបង្កើតជាឆ្នេរសម្រាប់ដើរលេងកម្សាន្តប្រសិនបើអាចធ្វើបាន។ សារាចរដដែលនេះក៏បានបញ្ជាក់បន្ថែមទៀតដែរថា នៅលើឆ្នេរសមុទ្រ អាចអនុញ្ញាតឲ្យដាក់ឆ័ត្រ កៅអី និងតុតូចៗតាមចំនួនសមស្រប ដែលអាចផ្លាស់ប្តូរទីតាំងបានសម្រាប់គោលដៅសម្រាកលម្ហែកាយ និងត្រូវរៀបចំដាក់តូបផ្ទាំងឆ្នេរសមុទ្រ ដោយបំពាក់សម្ភារៈនិងឧបករណ៍ចាំបាច់តាមតម្រូវការដើម្បីឃ្លាំមើលការការពារសុវត្ថិភាពជូនសាធារណជន និងទេសចរ។

## ៨.១.២. ដែនទឹកសមុទ្រ និងការនេសាទ

ការស្រាវជ្រាវថ្មីៗដែលយោងដោយអង្គការទិន្នន័យអំពីការអភិវឌ្ឍ បានប៉ាន់ប្រមាណថានៅក្នុងដែនសមុទ្រកម្ពុជា មានវត្តមាន ស្មៅសមុទ្រ ១០ប្រភេទ, ផ្កាថ្មរឹង ៧០ ប្រភេទ, ដើមកោងកាង ៣០ ប្រភេទ និងត្រី ៤៣៥ ប្រភេទ។[18] ដែនទឹកសមុទ្រសំដៅដល់ផ្ទៃទឹកខាងលើ និងក្នុងទឹក។ នៅក្នុងទឹកមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះគ្រប់ប្រភេទ។

ដែនទឹកសមុទ្រដែលមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះនានាដូចជាផ្កាថ្ម ត្រីធំតូចចម្រុះប្រភេទ និងរុក្ខជាតិសមុទ្រត្រូវគ្រប់គ្រង ការពារ អភិរក្ស និងអភិវឌ្ឍឲ្យបានត្រឹមត្រូវ មានប្រសិទ្ធភាព និងប្រកបដោយចីរភាព។ ចំពោះការនេសាទនៅក្នុងតំបន់ដែលមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះត្រូវហាមឃាត់ លើកលែងតែការនេសាទជាលក្ខណៈទេសចរណ៍ដោយប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ (ចំណុចទី៨ នៃសារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា)។

## ៨.២. គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរប្រទេសកម្ពុជា

គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យដែលឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ។ គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវ។

### ៨.២.១. សមាសភាព

សមាសភាពនៃគណៈកម្មាធិការនេះមានដូចខាងក្រោម ៖

- នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រធានកិត្តិយស
- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធាន
- រដ្ឋមន្ត្រីក្រសួងបរិស្ថាន ប្រធានកិត្តិយស
- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អនុប្រធានអចិន្ត្រៃយ៍
- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ០១ រូប សមាជិក

[18] អង្គការទិន្នន័យអំពីការអភិវឌ្ឍ https://opendevelopmentcambodia.net/km/topics/marine-and-coastal-areas/, ចូលអានថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០

- រដ្ឋលេខាធិការក្រសួងការពារជាតិ ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងផែនការ ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសុខាភិបាល ០១ រូប សមាជិក
- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
- អគ្គស្នងការនគរបាលជាតិ សមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- អភិបាលនៃគណៈអភិបាលខេត្តតំបន់ឆ្នេរសមុទ្រទាំង០៤ សមាជិក
- តំណាងគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ០១ រូប សមាជិក
- តំណាងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ០១ រូប សមាជិក
- តំណាងអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងបរិស្ថាន ០១ រូប សមាជិក
- តំណាងអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្មនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ០១ រូប សមាជិក
- អគ្គលេខាធិការ គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរប្រទេសកម្ពុជា សមាជិក។

### ៨.២.២. តួនាទី

គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា មានតួនាទីដូចខាងក្រោម ៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព កម្មវិធី និងគម្រោងផ្សេងៗដែលទាក់ទងនឹងការគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ
- រៀបចំបទដ្ឋានគតិយុត្ត និងគោលការណ៍ចាំបាច់នានា ដើម្បីធានាបាននូវការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍនៅតាមតំបន់ឆ្នេរសមុទ្រ ប្រកបដោយតម្លាភាពសមធម៌ និងនិរន្តរភាពបរិស្ថានពិនិត្យ បង្ការ និង ចាត់វិធានការចាំបាច់ ដើម្បីទប់ស្កាត់រាល់សកម្មភាពអសកម្មទាំងឡាយ ដែលអាចប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិនៅតាមតំបន់ឆ្នេរសមុទ្រ
- ពិនិត្យនិងវាយតម្លៃរាល់គម្រោងអភិវឌ្ឍនិងការអនុវត្តគម្រោងទាំងនេះនៅតាមតំបន់ឆ្នេរសមុទ្រឲ្យស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- ចូលរួមពិនិត្យនិង ផ្តល់មតិជូនស្ថាប័នមានសមត្ថកិច្ចចំពោះសំណើ សុំវិនិយោគដែលពាក់ព័ន្ធលើឆ្នេរសមុទ្រ ដី ចំណីឆ្នេរសមុទ្រ តំបន់រណប កោះ ដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ និងផ្ទៃទឹកដែលជាប់នឹងឆ្នេរសមុទ្រ

- ធ្វើសហការជាមួយនឹងក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក និងស្ថាប័នអន្តរជាតិពាក់ព័ន្ធនានាដើម្បីជំរុញការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- អប់រំបណ្តុះបណ្តាលធនធានមនុស្សដើម្បីឆ្លើយតប នឹងតម្រូវការក្នុងការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- ធ្វើសហការជាមួយក្រសួង ស្ថាប័ន ផ្នែកឯកជន និងភាគីពាក់ព័ន្ធទាំងអស់ដើម្បីសម្របសម្រួលការងារខាងលើឲ្យកាន់តែមានប្រសិទ្ធភាព
- រៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំរបស់គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

# ឯកសារយោង

១. ច្បាប់សិទ្ធិមនុស្សម្ពុជា សេចក្តីប្រកាសសិទ្ធិមនុស្សក្នុងរដ្ឋមនុញ្ញកម្ពុជា និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលជានាការពារដោយរដ្ឋធម្មនុញ្ញ ដែលចងក្រងដោយការិយាល័យនៃឧត្តមស្នងការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ខែកញ្ញា ឆ្នាំ២០២១២។

២. កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដែលចុះហត្ថលេខាកាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ នៅទីក្រុង ប៉ារីស ដើម្បីបញ្ចប់សង្គ្រាមស៊ីវិលខ្មែរ ដែលមាន១៨ ប្រទេសរួមទាំង កម្ពុជា មាន៤ភាគី គឺ ៖ រដ្ឋកម្ពុជា ហ៊ុនស៊ិនប៉ិចរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ របស់លោកតា សឺន សាន និងខ្មែរក្រហម ដែលរួមបញ្ចូលគ្នា បង្កើតជា "ក្រុមប្រឹក្សាជាតិជាន់ខ្ពស់" ។

៣. តាមវាក្យស័ព្ទក្នុងឧបសម្ព័ន្ធនៃក្រមបរិស្ថាន និងធនធានធម្មជាតិ ធនធានធម្មជាតិ ៖ សំដៅដល់ចំណែកមួយនៃបរិស្ថានធម្មជាតិមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគតាម ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ និងធនធានជលផល។

៤. នៅក្នុងគោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដីជលផលនិងព្រៃឈើ ហៅកាត់ថា"វីជីជីធី"។

៥. គឺជាផែនការចង្អុលបង្ហាញរបស់ស្ថាប័នមួយ ឬរដ្ឋាភិបាលនឹងធ្វើ និងអាចសម្រេចបានសម្រាប់សង្គមទាំងមូល។ គោលនយោបាយគឺជាឯកសារផែនការមួយ តែមិនមែនជាច្បាប់ទេ តែគោលនយោបាយទាំងនេះអាចជាការផ្តួចផ្តើមគំនិតសម្រាប់បង្កើតច្បាប់ថ្មី។ https://careers.uw.edu/blog/2019/10/13/law-vs-policy-whats-the-difference/

៦. អនុក្រឹត្យលេខ ១៤៨ (មាត្រា ២)

៧. អនុក្រឹត្យលេខ ១៤៨ (មាត្រា ២)

៨. អនុក្រឹត្យ លេខ ១៤៨ (មាត្រា ៦៦)

៩. អង្គការទិន្នន័យអំពីការអភិវឌ្ឍ https://opendevelopmentcambodia.net/km/topics/special-economic-zones/# return-note-75076-5

១០. សលាកប័ត្រព័ត៌មាន ៖ តំបន់សេដ្ឋកិច្ចពិសេស និងសិទ្ធិមនុស្សនៅកម្ពុជា របស់ ម.ស.ម.ក https://cchrcambodia.org/admin/media/factsheet/factsheet/khmer/20180927%20Factshhet_SEZ%20KHM%2010h13%20.pdf

១១. អនុក្រឹត្យលេខ ១៤៨ មាត្រា ៣៣។

១២. ហ្វេសប៊ុកផេករបស់ក្រសួងបរិស្ថានថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ ក្រសួងបរិស្ថានដាក់ឱ្យប្រើប្រាស់ក្ - ...Ministry of Environment | Facebook

១៣. តំបន់រ៉ាមសារ គឺតំបន់ដីសើមដែលគេចាត់ទុកថាជាតំបន់ដែលមានសារៈសំខាន់ខាងផ្នែកប្រព័ន្ធអេកូឡូស៊ី ឬជីវៈចម្រុះជាលក្ខណៈអន្តរជាតិ។

១៤. រាល់ជំហានដែលតម្រូវទាំងអស់សម្រាប់ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម អាចរកមើលបាន នៅក្នុង "ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម", IFC,ទំព័រ១,

១៥. "ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៤ មាត្រា១, "តំបន់សេដ្ឋកិច្ចពិសេស និងការ ដកយកអត្ថប្រយោជន៍ពីទន្លេមេគង្គ", Focus on the Global South, ខែកក្កដា ឆ្នាំ២០១៧ ទំព័រ១៦, កថាខណ្ឌ ទី២

១៦. ឧបសម្ព័ន្ធនៃក្រមបរិស្ថាននិងធនធានធម្មជាតិ (សន្ធានុក្រម ត ថ ទ)

១៧. សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជា, ២០១២

១៨. អង្គការទិន្នន័យអំពីការអភិវឌ្ឍ https://opendevelopmentcambodia.net/km/topics/marine-and-coastal-areas/ចូលអានថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០